# ការវាយតម្លៃលើឱកាសទទួលបាន ឥណទានរបស់សហគមន៍ជនជាតិដើម ភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដី សមូហភាពនៅកម្ពុជា

## សហគមន៍ជនជាតិដើមភាគតិច ក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ

ខែ តុលា ឆ្នាំ ២០១៨

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

សហការឧបត្ថម្ភមូលនិធិដោយ
សហភាពអឺរ៉ុប

សហភាពអឺរ៉ុប

សៀវភៅនេះត្រូវបានរៀបរៀង និងបោះពុម្ពផ្សព្វផ្សាយក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប ។
ទស្សនៈ និងបទបង្ហាញនានាក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធមនុស្ស (OHCHR) គឺវាមិនមែន
ជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ ។

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........................................................................................ 2

មាតិកា ........................................................................................ 3

ពាក្យកាត់ ......,,,,,,,........................................................................ 5

បញ្ជីតារាង ...,,,,,,,........................................................................ 5

១. សេចក្តីសង្ខេប ........................................................................................ 6

លទ្ធផលរកឃើញ ........................................................................................ 7

២. សេចក្តីផ្តើម ........................................................................................ 11

២.១ គោលបំណងនៃការសិក្សានេះ ........................................................................................ 11

២.២ វិធីសាស្រ្ត ........................................................................................ 13

៣. សាវតារ ........................................,,,,,,,........................................................ 18

៣.១ សហគមន៍ជនជាតិដើមភាគតិច និងសិទ្ធិដីធ្លីរបស់ពួកគេ ........................................ 18

៣.២ លទ្ធភាពទទួលបានឥណទាននៅតាមតំបន់ជនបទ ........................................ 20

៣.៣ បំណុល និងការជាប់បំណុលនៅកម្ពុជា ........................................ 22

៤. លទ្ធផលរកឃើញ ........................................................................................ 28

៤.១ សង្ខេបព័ត៌មានអំពីសហគមន៍ជនជាតិដើមភាគតិចដែលបានចុះទៅ ........................................ 28

៤.២ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់កម្ចីដល់សហគមន៍ជនជាតិដើមភាគតិច .. 35

៤.៣ លទ្ធភាពរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានសេវាហិរញ្ញវត្ថុ និងបំណុល ........... 38

៤.៤ ការទទួលបានសេវាហិរញ្ញវត្ថុសម្រាប់ស្រ្តី ........................................ 41

៤.៥ ហានិភ័យដែលនាំឱ្យមានបញ្ហាជាប់បំណុល ........................................ 42

៥. សេចក្តីសន្និដ្ឋាន ........................................................................................ 43

៥.១ អំពីស្ថានភាពក្នុងសហគមន៍ជនជាតិដើមភាគតិចពាក់ព័ន្ធនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាព ការប្រើប្រាស់ដី និងទំនាស់ដីធ្លី៖ ........................................ 43

៥.២ អំពីការផ្តល់កម្ចី ........................................................................................ 45

៥.៣ អំពីការជាប់បំណុល ........................................................................................ 47

៥.៤ អំពីហេដ្ឋារចនាសម្ព័ន្ធសង្គម ........................................................................................ 47

៦. អនុសាសន៍ ........................................................,,,,,,,............................ 48

៦.១ អនុសាសន៍ដល់រដ្ឋាភិបាលនៅថ្នាក់ជាតិ និងរដ្ឋបាលមូលដ្ឋាន ......48
៦.២ អនុសាសន៍ចំពោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ......49
៦.៣ អនុសាសន៍ចំពោះការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ......49
៦.៤ អនុសាសន៍ចំពោះអង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រដល់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសម្ងហាភាព និងការអភិវឌ្ឍសហាគមន៍ ......50
៦.៥ អនុសាសន៍ចំពោះសហាគមន៍ជនជាតិដើមភាគតិចទាំង ១០ ដែលត្រូវបានចុះទៅ ......50
ឧបសម្ព័ន្ធ ......51
**ឧបសម្ព័ន្ធទី ១ កម្រងសំណួរសម្រាប់កាសម្ភាសតាមខ្នងផ្ទះ ......52**
**ឧបសម្ព័ន្ធទី ២ គោលការណ៍ណែនាំស្តីពីការសម្ភាសក្នុងកិច្ចប្រជុំភូមិ/ការពិភាក្សាក្រុមគោលដៅ.60**
**ឧបសម្ព័ន្ធទី ៣ ការណែនាំសម្រាប់សម្ភាសក្នុងពេលជួបប្រជុំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ......64**
**ឧបសម្ព័ន្ធទី ៤ សង្ខេបទិន្នន័យអំពីប័ណ្ណកម្មសិទ្ធិដីសម្ងហាភាព ......67**
**ឧបសម្ព័ន្ធទី ៥ ទំហាំសំណាកគំរូ ......69**
**ឧបសម្ព័ន្ធទី ៦ ឯកសារយោង ......70**

# ពាក្យកាត់

| ពាក្យកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| CLT | COLLECTIVE LAND TITLE | ប័ណ្ណកម្មសិទ្ធដីសមូហភាព |
| IPC | INDIGENOUS PEOPLES' COMMUNITY | សហគមន៍ជនជាតិដើមភាគតិច |
| MDI | MICROFINANCE DEPOSIT-TAKING INSTITUTION | ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលវត្ថុបញ្ញាំ |
| MFI | MICROFINANCE INSTITUTION | ស្ថាប័នមីក្រូហិរញ្ញវត្ថុ |
| NGO | NON-GOVERNMENT ORGANISATION | អង្គការក្រៅរដ្ឋាភិបាល |
| UN-OHCHR | UNITED NATIONS OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS | ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| SLC | SOCIAL LAND CONCESSION | ដីសម្បទានសង្គមកិច្ច |

# បញ្ជីតារាង

តារាងទី ១ តារាងសង្ខេបបង្ហាញពីសហគមន៍ជនជាតិដើមភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព (គិតត្រឹមខែកញ្ញា ឆ្នាំ ២០១៧)
តារាងទី ២ សង្ខេបសហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានសិក្សា
តារាងទី ៣ ចំនួនប្រាក់កម្ចី ដែលមិនទាន់សង គិតជាមធ្យម
តារាងទី ៤ បំណុលដែលមិនទាន់សង គិតជាមធ្យមបែងចែកទៅតាមប្រភពកម្ចីក្នុងតំបន់ជនបទនៅកម្ពុជា (គិតជាភាគរយ)
តារាងទី ៥ សង្ខេបពីបន្ទុកបំណុលរបស់គ្រួសារក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំង ១៧
តារាងទី ៦ ចំនួនប្រាក់បំណុលគិតជាមធ្យមក្នុងមួយគ្រួសារ
តារាងទី ៧ សង្ខេបគោលនយោបាយស្តីពីការផ្តល់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានសម្ភាស
តារាងទី ៨ កម្រិតនៃការជាប់បំណុលរបស់គ្រួសារ ដែលត្រូវបានសម្ភាសក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលប្រើប្រាស់ជាសំណាកគំរូ

# ១. សេចក្តីសង្ខេប

សម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការទទួលបានសិទ្ធិកាន់កាប់ដីធ្លី និងធនធានរបស់ពួកគេបានជាប់លាប់ គឺជាលក្ខខណ្ឌដែលចាំបាច់ត្រូវតែមាន សម្រាប់សុខមាលភាពរយៈពេលវែងរបស់ពួកគេ និងជាបុរេលក្ខខណ្ឌ ដើម្បីឱ្យពួកគេអាចបន្តអត្ថិភាព ក្នុងនាមជាក្រុមមនុស្សពិសេស។ សិទ្ធិកាន់កាប់ដីធ្លី និងធនធានប្រកបដោយសុវត្ថិភាព គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិមនុស្សជាមូលដ្ឋានសំខាន់ៗជាងគេ របស់ជនជាតិដើមភាគតិច និងជាលក្ខណ្ឌដ៏សំខាន់មួយនៃការទទួលស្គាល់សិទ្ធិមនុស្សរបស់ពួកគេជាអន្តរជាតិ។

ប័ណ្ណកម្មសិទ្ធិដីសមូហភាព មានគោលបំណងផ្តល់សិទ្ធិកាន់កាប់ជាអចិន្ត្រៃយ៍ ដល់សហគមន៍ទាំងមូល ដោយហេតុថា ដីធ្លីដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ អាចលក់បានត្រឹមតែទៅឱ្យសមាជិកមកពីសហគមន៍តែមួយប៉ុណ្ណោះ។ ការតម្រូវបែបនេះផ្តល់នូវការការពារ ប៉ុន្តែក៏ជាការដាក់កំហិតមិនឱ្យយកប័ណ្ណកម្មសិទ្ធិដីធ្លីនេះទៅប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់ខ្ចីកម្ចី នាំឱ្យសហគមន៍ ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីបែបនេះ មានឱកាសតិចតួច ក្នុងការទទួលបានកម្ចី សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគេ។ មានការរាយការណ៍ថា គ្រឹះស្ថានហិរញ្ញវត្ថុមិនចង់ទទួលយកប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយដាក់ឈ្មោះភូមិទាំងមូលជាវត្ថុបញ្ចាំឡើយ ហើយគ្រឹះស្ថានទាំងនេះបានលើកឡើងពីបញ្ហាប្រឈមជាច្រើន ដែលធ្វើឱ្យពួកគេមិនអាចទទួលយកប័ណ្ណកម្មសិទ្ធិដីធ្លីដែលកាន់កាប់ជាសមូហភាពបាន ដូចជា អ្នកដែលគួរចុះបញ្ជីជាអ្នកទទួលកម្ចី (សហគមន៍ទាំងមូល គណៈកម្មការគ្រប់គ្រងសហគមន៍ មេភូមិ ឬបុគ្គល ឬក្រុមផ្សេងទៀតនៅក្នុងសហគមន៍) និងរបៀបដែលគ្រឹះស្ថានផ្តល់កម្ចី និងអាចទទួលបានប្រាក់របស់ខ្លួនមកវិញ ប្រសិនបើអ្នកខ្ចីកម្ចីខកខានមិនអាចសងកម្ចីវិញបាន ជាដើម។

ដើម្បីស្វែងយល់បន្ថែមលើការរាយការណ៍ថា សមាជិកសហគមន៍ជនជាតិដើមភាគតិច ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព អាចមានការលំបាកក្នុងការទទួលបានកម្ចី ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សបានរៀបចំឱ្យមានការស្រាវជ្រាវស៊ីជម្រៅមួយលើសហគមន៍ជនជាតិដើមភាគតិច ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព ដើម្បីធ្វើការប្រៀបធៀបកម្រិតនៃការទទួលបានឥណទានរបស់ពួកគេ ធៀបនឹងប្រជាពលរដ្ឋ ដែលនៅតាមភូមិជនបទទូទៅ នៅកម្ពុជា។

ការសិក្សានេះមានគោលបំណងដូចតទៅ៖

- ប្រៀបធៀបលទ្ធភាពទទួលបានឱកាសហិរញ្ញវត្ថុរបស់ជនជាតិដើមភាគតិច ដើម្បីអភិវឌ្ឍន៍ដីធ្លីរបស់ពួកគេ ដូចជាឱកាសទទួលបានកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ និងលទ្ធភាពបង្កើតក្រុមសន្សំ និងការខ្ចីប្រាក់ជាលក្ខណៈក្រៅផ្លូវការ ធៀបនឹងប្រជាពលរដ្ឋខ្មែរ ដែលរស់នៅតាមភូមិជនបទទូទៅ និងធ្វើការពិនិត្យ ក៏ដូចជាចងក្រងឯកសារអំពីគោលនយោបាយរបស់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីសមូហភាពជាវត្ថុបញ្ចាំ។

- ពិនិត្យលើស្ថានភាពសិទ្ធិរបស់ស្ត្រីជនជាតិដើមភាគតិច និងបញ្ហាប្រឈម ដែលពួកគេជួបប្រទះក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេ ជាពិសេសសិទ្ធិដែលពាក់ព័ន្ធនឹងការគាំទ្រដល់ជីវភាពរស់នៅ។

- កំណត់ពីឧបសគ្គផ្នែកសមត្ថភាព របស់សហគមន៍ជនជាតិដើមភាគតិចជាអ្នកទទួលផលកំពុងជួបប្រទះ ដែលជាកត្តាជាក់កំហិតដល់លទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានប្រយោជន៍ពេញលេញពីប្រាក់កម្ចី

- ផ្តល់អនុសាសន៍ជាក់លាក់ ដែលអាចយកទៅអនុវត្តបាន ដល់អ្នកពាក់ព័ន្ធសំខាន់ៗ ដែលមានតួនាទី ផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព។

ការសិក្សានេះត្រូវបានធ្វើឡើងចន្លោះពីខែ មិថុនា ដល់ខែ សីហា ឆ្នាំ ២០១៧។ ការសិក្សានេះត្រូវបានធ្វើឡើងផ្អែកទៅតាមការពិនិត្យល្អិតល្អន់លើឯកសារពាក់ព័ន្ធនានា និងការចុះប្រមូលព័ត៌មានដល់មូលដ្ឋានជាមួយសហគមន៍ជនជាតិដើមភាគតិចទាំងអស់ ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពកន្លងមក។ ការសម្ភាស និងការពិភាក្សាក្រុមគោលដៅត្រូវបានធ្វើឡើងជាមួយនឹងតំណាងសហគមន៍ជនជាតិដើមភាគតិច គ្រួសារនីមួយៗ ក៏ដូចជាអ្នកផ្តល់សេវាហិរញ្ញវត្ថុនានា។

ជារួម មានការចុះទៅកាន់សហគមន៍ជនជាតិភាគតិចចំនួន ១០។ ក្នុងគ្រប់សហគមន៍ជនជាតិភាគតិចទាំងអស់នេះ មានការរៀបចំការពិភាក្សាក្រុមជាមួយនឹងសមាជិកនៃគណៈកម្មការសហគមន៍ជនជាតិភាគតិច ក៏ដូចជាតំណាងភូមិ និងចាស់ព្រឹទ្ធាចារ្យ ក្នុងភូមិ។ លើសពីនេះ ក៏មានការសម្ភាសជាមួយប្រជាពលរដ្ឋ តាមខ្នងផ្ទះផងដែរ។

ជារួម ការសិក្សានេះមានគោលបំណងធ្វើការវាយតម្លៃលទ្ធភាពទទួលបានឥណទានរបស់សមាជិកសហគមន៍ជនជាតិភាគតិចដែលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ដោយសារតែទំហំសំណាកគំរូនៃគ្រួសារជនជាតិដើមភាគតិចដែលត្រូវបានសម្ភាស មានទំហំតូច[1] គេពុំអាចទាញជាសេចក្តីសន្និដ្ឋានអំពីអត្រានៃការជាប់បំណុលរបស់សហគមន៍ជនជាតិភាគតិចដែលត្រូវបានអង្កេតនេះ ដោយប្រើបច្ចេកទេសស្ថិតិឡើយ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកទៅតាមការពិភាក្សាក្រុម ការសម្ភាសតាមខ្នងផ្ទះ និងការសម្ភាសជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ដូចជាអ្នកចងការប្រាក់ឯកជន គេអាចផ្តល់ព័ត៌មានទូទៅខ្លះអំពីកម្រិតនៃការជាប់បំណុលរបស់សហគមន៍ជនជាតិភាគតិច ធៀបជាមួយនឹងប្រជាពលរដ្ឋខ្មែរទូទៅ។

## លទ្ធផលរកឃើញ

តំណាងមកពីការិយាល័យសាខារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សរុបចំនួន ១៩ ត្រូវបានសម្ភាស សម្រាប់ការសិក្សានេះ។ ខណៈពេលដែលពុំមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាមួយទទួលយកប័ណ្ណកម្មសិទ្ធិដីសមូហភាពជាវត្ថុបញ្ចាំ គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលត្រូវបានសម្ភាសទាំងអស់ សុទ្ធតែបានផ្តល់កម្ចីដល់សមាជិកនៃសហគមន៍ជនជាតិភាគ

[1] សរុបមានសហគមន៍ជនជាតិភាគតិចតែ ១៨ ប៉ុណ្ណោះ ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព គិតមកត្រឹមពេលធ្វើការសិក្សានេះ។

តិច។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនផ្តល់កម្ចីក្រោមគម្រោងទទួលខុសត្រូវជាក្រុម។ កម្ចីទាំងនេះត្រូវបានផ្តល់ដល់មនុស្សជាក្រុម ដោយក្នុងមួយក្រុមមានគ្នា ២-៦ នាក់។ សមាជិកក្រុមទាំងអស់ផ្តល់ការធានាដល់គ្នាទៅវិញទៅមក។ សមាជិកក្រុមពុំចាំបាច់ដាក់វត្ថុបញ្ចាំ ដូចជា ប័ណ្ណកម្មសិទ្ធិដីធ្លីនោះឡើយ ដែលគម្រោងបែបនេះ ផ្តល់លទ្ធភាពឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចអាចខ្ចីកម្ចីប្រភេទនេះបាន។ មានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនតូចតែប៉ុណ្ណោះ ដែលត្រូវការវត្ថុបញ្ចាំ (ប័ណ្ណកម្មសិទ្ធិដីធ្លី) ពីសមាជិកក្រុមយ៉ាងហោចណាស់ម្នាក់។ អត្រាការប្រាក់ គឺប្រហាក់ប្រហែលគ្នានឹងកម្ចីសម្រាប់បុគ្គលដែល ពោលគឺ ១,៥% ក្នុងមួយខែ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនបញ្ជាក់ពីការសងប្រាក់ទៀងទាត់ពេលវេលាក្នុងកម្រិតមួយខ្ពស់ពីសំណាក់សមាជិកសហគមន៍ជនជាតិដើមភាគតិច។ ជាទូទៅ សមាជិកសហគមន៍ជនជាតិភាគតិចត្រូវបានគេចាត់ទុកថាជាអតិថិជន "ដែលល្អ"។ ដោយសារតែការចុះសម្រុងគ្នាបានល្អក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច ដែលមកពីសហគមន៍ជាមួយគ្នា ការទទួលខុសត្រូវជាក្រុមបែបនេះត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាត់ទុកថាជាមធ្យោបាយមួយដ៏ល្អ។

ផ្អែកទៅតាមការពិភាក្សាក្រុមក្នុងភូមិតាមសហគមន៍ជនជាតិភាគតិច ដែលបានចុះទៅ ការសម្ភាសជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការសម្ភាសតាមខ្នងផ្ទះ សមាជិកសហគមន៍ជនជាតិភាគតិចប្រើប្រាស់ជម្រើសដូចខាងក្រោមដើម្បីទទួលបានឥណទាន (ទៅតាមលំដាប់លំដោយនៃសារៈសំខាន់)៖

- ធនាគារ / គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ក្រុមសន្សំភូមិ
- សាច់ញាតិ / មិត្តភក្តិ / អ្នកជិតខាង
- ឈ្មួញ
- អ្នកចងការប្រាក់ឯកជន

សម្រាប់ភូមិភាគច្រើន គ្រួសារដែលជាប់បំណុល ជាមធ្យម មានចន្លោះពី ៧០-៨០%។ ភូមិពន្ធជា គឺជាករណីលើកលែងមួយ ដោយសារតែមានអ្នកខ្ចីកម្ចីតិចតួចតែប៉ុណ្ណោះ ខណៈពេលដែលក្នុងភូមិពូត្រុំវិញមានការព្យាយាមកំហិតចំនួនប្រាក់កម្ចីជាឆ្នាំណាស់មកហើយ តាមរយៈការចែករំលែកព័ត៌មានដោយគណៈកម្មការសហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែ ឥឡូវនេះ ភូមិនេះកំពុងស្ថិតនៅក្រោមសម្ពាធដ៏ខ្លាំងក្លាពីភ្នាក់ងារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ដូចដែលទីប្រឹក្សាបានឃើញផ្ទាល់ភ្នែក)។ ជារួម ស្រដៀងគ្នាជាមួយនឹងតំបន់ដទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ការជាប់បំណុលមានការកើនឡើង។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានយុទ្ធសាស្ត្រមួយ គឺបង្កើនចំនួនប្រាក់កម្ចី បន្ទាប់ពីអ្នកខ្ចីបានទូទាត់កម្ចីកន្លងមកអស់រួចមក។ អ្នកជាប់បំណុលភាគច្រើន នៅតែជាអតិថិជនលើកដំបូងជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប៉ុន្តែពួកគេមួយចំនួន គឺជាអ្នកខ្ចីលើកទី ២ ឬលើកទី ៣ រួចទៅហើយ ហើយចំនួនប្រាក់ដែលពួកគេខ្ចី ក៏មានការកើនឡើងច្រើនជាងមុនផងដែរ។ បទបញ្ញាដែលកំណត់អត្រាការប្រាក់អតិបរមាត្រឹម ១,៥% ក្នុងមួយខែ ធ្វើឱ្យគ្រួសារនៅជនបទកាន់តែមានលទ្ធភាពខ្ចីកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចទាំង ១០ មានសហគមន៍ចំនួន ៨ ដែលមានក្រុមសន្សំភូមិ យ៉ាងហោចណាស់មួយក្រុម។ ក្រុមសន្សំភូមិទាំងអស់សុទ្ធតែកំពុងផ្តល់កម្ចីដល់សមាជិករបស់ខ្លួន ហើយនៅក្នុងករណីមួយចំនួន ក៏មានការផ្តល់ប្រាក់កម្ចីដល់អ្នកដែលមិនមែនជាសមាជិក ក្នុងអត្រាការប្រាក់ខ្ពស់ផងដែរ។ អត្រាការប្រាក់ធម្មតាគឺ ២% សម្រាប់សមាជិក និង ៣% សម្រាប់អ្នកដែលមិនមែនជាសមាជិក។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីភាគច្រើន ប្រាក់ដែលដាក់សន្សំ គឺមិនគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងសំណើខ្ចីកម្ចីរបស់សមាជិកក្រុមឡើយ។

ប្រជាពលរដ្ឋបានលើកឡើងថា នៅក្នុងករណីបន្ទាន់ ពួកគេខ្ចីកម្ចីក្នុងទំហំតូចៗ ពីសាច់ញាតិ អ្នកជិតខាង ឬមិត្តភក្តិរបស់ពួកគេ។

ការខ្ចីកម្ចីភាគច្រើន ត្រូវបានធ្វើឡើង ដោយប្តី និងប្រពន្ធរួមគ្នា បើទោះបីជាភាគច្រើន ប្តីគឺជាអ្នកចុះហត្ថលេខាជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយ៉ាងណាក៏ដោយ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ផ្តល់កម្ចីឱ្យអតិថិជនទាំងស្រីទាំងប្រុស។ ពុំមានការសង្កេតឃើញថា មានការរើសអើងចំពោះស្ត្រីឡើយ។ លើសពីនេះក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាស មានកម្ចីក្រុមមួយចំនួនត្រូវបានខ្ចីដោយក្រុមដែលមានសមាជិកសុទ្ធតែជាស្ត្រី។ កម្ចីភាគច្រើនដែលបានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍដី ទិញឧបករណ៍ គ្រាប់ពូជ ជី និងថ្នាំពុលកសិកម្ម។ លើសពីនេះប្រជាពលរដ្ឋជាច្រើនគ្រួសារក៏រាយការណ៍ថា បានខ្ចីកម្ចីដើម្បីសង់ផ្ទះ និងរ៉ាប់រងការបន្តការសិក្សារបស់កូនៗផងដែរ។ កម្ចីពីក្រុមសន្សំភូមិ ច្រើនតែត្រូវបានប្រើប្រាស់សម្រាប់គោលបំណងទូទៅនៅក្នុងគ្រួសារ។

ជាទូទៅ ពុំមានការរកឃើញសញ្ញាដែលបញ្ជាក់ថា ស្ត្រីទទួលរងការចាញ់ប្រៀបក្នុងការទទួលបានឥណទាននោះឡើយ។ ស្ត្រីចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សាក្រុម និងក្នុងការសម្ភាសជាលក្ខណៈបុគ្គល ដោយពួកគេបានលើកឡើងជាចំហ អំពីទស្សនៈយល់ឃើញ និងបទពិសោធន៍របស់ពួកគេ។

ផ្អែកទៅតាមលទ្ធផលរកឃើញនេះ មានការទាញនូវសេចក្តីសន្និដ្ឋានជាច្រើនជុំវិញ៖

- ស្ថានភាពក្នុងសហគមន៍ជនជាតិដើមភាគតិចពាក់ព័ន្ធនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាព ការប្រើប្រាស់ដីធ្លី និងទំនាស់ដីធ្លី
- ការផ្តល់កម្ចី
- ការជាប់បំណុល
- ហេដ្ឋារចនាសម្ព័ន្ធសង្គម

លើសពីនេះ ការសិក្សានេះក៏ផ្តល់អនុសាសន៍ដល់

- រដ្ឋាភិបាលជាតិ និងរដ្ឋបាលមូលដ្ឋាន
- ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ការិយាល័យឧត្តមស្នងការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំព្រះរាជាណាចក្រកម្ពុជា

- អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការគាំទ្រដល់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព និងការអភិវឌ្ឍសហគមន៍
- សហគមន៍ជនជាតិដើមភាគតិចទាំង ១០ សហគមន៍ ដែលបានចុះជួប

# ២. សេចក្ដីផ្ដើម

## ២.១ គោលបំណងនៃការសិក្សានេះ

សម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការទទួលបានសិទ្ធិកាន់កាប់ដីធ្លី និងធនធានរបស់ ពួកគេបានជាប់លាប់ គឺជាលក្ខខណ្ឌដែលចាំបាច់ត្រូវតែមានសម្រាប់សុខមាលភាពរយៈពេលវែងរបស់ពួកគេ និងជាបុរេលក្ខខណ្ឌដើម្បីឱ្យពួកគេអាចបន្តអត្ថិភាពក្នុងនាមជាក្រុមមនុស្សពិសេស។ សិទ្ធិកាន់កាប់ដីធ្លី និងធនធានប្រកបដោយសុវត្ថិភាព គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិមនុស្សជាមូលដ្ឋានសំខាន់ៗជាងគេរបស់ជនជាតិដើមភាគតិច និងជាលក្ខណៈដ៏សំខាន់មួយនៃការទទួលស្គាល់សិទ្ធិមនុស្សរបស់ពួកគេជាអន្តរជាតិ។

នៅកម្ពុជា ច្បាប់ភូមិបាលឆ្នាំ ២០០១ គឺជាក្របខ័ណ្ឌគតិយុត្តិសំខាន់ជាងគេសម្រាប់ផ្ដល់កម្មសិទ្ធិជាប្រពៃណីជាផ្លូវការ ដល់ជនជាតិដើមភាគតិច តាមរយៈការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ច្បាប់ភូមិបាលទទួលស្គាល់ការគ្រប់គ្រងដីជាសមូហភាពរបស់ជនជាតិដើមភាគតិច និងភាពចាំបាច់ក្នុងការការពារសិទ្ធិរបស់ពួកគេ ដើម្បីរក្សាបែបផែននៃការរស់នៅជាប្រពៃណីរបស់ពួកគេ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការប្រើប្រាស់ដីធ្លី និងធនធាននានាទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់ពួកគេ។ គិតត្រឹមខែ កញ្ញា ឆ្នាំ ២០១៧ នេះ មានជនជាតិដើមភាគតិចចំនួន ១៨ សហគមន៍នៅកម្ពុជាបានទទួលប័ណ្ណកម្មដីសមូហភាព។[2]

ដំណើរការ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិសហគមន៍មានលក្ខណៈស្មុគស្មាញ និងចំណាយច្រើន។ ការប៉ាន់ប្រមាណមួយចំនួន[3] បង្ហាញថាចំណាយសរុប ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិមួយប័ណ្ណអាចចំណាយអស់រហូតដល់ ៧០.០០០ ដុល្លារ ក្នុងមួយសហគមន៍។ ក្នុងការអនុវត្តជាក់ស្ដែង មានន័យថា សហគមន៍ត្រូវពឹងអាស្រ័យទាំងស្រុងលើការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយ ដើម្បីឱ្យពួកគេអាចទទួលបានសិទ្ធិកាន់កាប់ដីជាសមូហភាពរបស់ពួកគេជាផ្លូវការបាន។ ពាក់ព័ន្ធជាមួយនឹងរយៈពេលវិញ ការប៉ាន់ប្រមាណនានា[4] បង្ហាញថា សហគមន៍ជនជាតិដើមភាគតិចត្រូវការពេលជាមធ្យមជិតបួនឆ្នាំ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពមួយ។ ដោយសារដំណើរការត្រូវការពេលយូរ សមាជិកសហគមន៍ជនជាតិដើមភាគតិចជាច្រើនបានដកខ្លួនពីដំណើរការនេះ ទាំងមុនពេលឈានដល់ដំណើរការចុះបញ្ជីដីធ្លី។ ទោះជាយ៉ាងណាក៏ដោយ ប័ណ្ណកម្មសិទ្ធិសមូហភាពនៅតែជាឧបករណ៍សំខាន់បំផុត ដែលសហគមន៍ជនជាតិដើមភាគតិចអាចប្រើប្រាស់ ដើម្បីបញ្ជាក់ពីសិទ្ធិរបស់ពួកគេក្នុងការប្រឆាំងតទល់នឹងការទន្ទ្រានយកដីពីអ្នកខាងក្រៅ។

---

[2] រាប់បញ្ចូលទាំងប័ណ្ណកម្មសិទ្ធិសហគមន៍ចំនួនបួន កាលពីដើមឆ្នាំ ២០១៧។

[3] ប្រភព៖ មេរៀនដែលទទួលបានអំពីការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់ជនជាតិដើមភាគតិច រៀបចំដោយ GIZ (២០១៦)។

[4] ប្រភព៖ មេរៀនដែលទទួលបានអំពីការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់ជនជាតិដើមភាគតិច រៀបចំដោយ GIZ (២០១៦)។

ប័ណ្ណកម្មសិទ្ធិដីសមូហភាព មានគោលបំណងផ្តល់សិទ្ធិកាន់កាប់ជាអចិន្ត្រៃយ៍ដល់សហគមន៍ទាំងមូល ដោយហេតុថា ដីដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ អាចលក់បានត្រឹមតែទៅឱ្យសមាជិកមកពីសហគមន៍តែមួយប៉ុណ្ណោះ។ ការតម្រូវបែបនេះ ផ្តល់នូវការការពារ ប៉ុន្តែក៏ដាក់កំហិតមិនឱ្យយកប័ណ្ណកម្មសិទ្ធិដីធ្លីនេះទៅប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់ខ្ចីកម្ចី ដែលនាំឱ្យសហគមន៍ ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព មានឱកាសតិចតួច ក្នុងការទទួលបានកម្ចីហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគេ។ មានការរាយការណ៍ថា គ្រឹះស្ថានហិរញ្ញវត្ថុមិនចង់ទទួលយកប័ណ្ណកម្មសិទ្ធិដីសហគមន៍ ដោយដាក់ឈ្មោះភូមិទាំងមូលជាវត្ថុបញ្ចាំឡើយ ហើយគ្រឹះស្ថានទាំងនេះបានលើកឡើងពីបញ្ហាប្រឈមជាច្រើន ដែលធ្វើឱ្យពួកគេមិនអាចទទួលយកប័ណ្ណកម្មសិទ្ធិដីធ្លីដែលកាន់កាប់ជាសមូហភាពបាន ដូចជា អ្នកដែលគួរចុះបញ្ជីជាអ្នកទទួលកម្ចី (សហគមន៍ទាំងមូល គណៈកម្មការគ្រប់គ្រងសហគមន៍ មេភូមិ ឬបុគ្គល ឬក្រុមផ្សេងទៀតនៅក្នុងសហគមន៍) និងរបៀបដែលគ្រឹះស្ថានផ្តល់កម្ចី និងអាចទទួលបានប្រាក់របស់ខ្លួនមកវិញ ប្រសិនបើអ្នកខ្ចីកម្ចីខកខានមិនអាចសងកម្ចីវិញបាន។

ដើម្បីស្វែងយល់បន្ថែមលើការរាយការណ៍ថា សមាជិកសហគមន៍ជនជាតិដើមភាគតិច ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ អាចមានការលំបាកក្នុងការទទួលបានកម្ចី ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានរៀបចំឱ្យមានការស្រាវជ្រាវស៊ីជម្រៅមួយលើសហគមន៍ជនជាតិដើមភាគតិច ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព ដើម្បីប្រៀបធៀបកម្រិតនៃការទទួលបានឥណទានរបស់ពួកគេ ធៀបនឹងប្រជាពលរដ្ឋ ដែលនៅតាមភូមិជនបទទូទៅរបស់ព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមលទ្ធផលរកឃើញទាំងនេះ ការសិក្សានេះបង្ហាញពីអនុសាសន៍ដែលតួអង្គពាក់ព័ន្ធ ដែលចូលរួមផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព ដូចជា អាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទីភ្នាក់ងារសហប្រជាជាតិ (រាប់បញ្ចូលទាំងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផង អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច យកទៅអនុវត្ត។ លើសពីនេះ ការសិក្សានេះក៏បង្ហាញអនុសាសន៍សម្រាប់គ្រឹះស្ថាន និងធនាគារ ឬក្រុមសន្សំប្រាក់ ដែលផ្តល់កម្ចីដល់សមាជិកសហគមន៍ផងដែរ ក្នុងគោលបំណង ដើម្បីធានាយ៉ាងណាឱ្យជនជាតិដើមភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព ពុំត្រូវបានគេផាត់ចេញពីឱកាសសេដ្ឋកិច្ច សម្រាប់អភិវឌ្ឍដីធ្លីរបស់ពួកគេ ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេទៅតាមបំណង ដែលពួកគេចង់បាន បន្ទាប់ពីពួកគេបានទទួលប័ណ្ណកម្មសិទ្ធិសមូហភាពរួចហើយនោះ។

ជាគោលការណ៍ ការសិក្សានេះមានគោលបំណងគ្របដណ្តប់លើសហគមន៍ជនជាតិដើមភាគតិចទាំង ១៨ សហគមន៍ ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព គិតត្រឹមពេលដែលមានការសិក្សានេះ។ ទោះជាយ៉ាងណាក៏ដោយ ការជ្រើសរើសសហគមន៍ជនជាតិដើមភាគតិច ដើម្បីចុះទៅធ្វើការសិក្សា គឺអាស្រ័យទៅលើការសម្រេចចិត្តរបស់ទីប្រឹក្សា។ សហគមន៍ជនជាតិដើមភាគតិច ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពមិនដល់មួយឆ្នាំមុន និងសហគមន៍

ដែលពិបាកចូលទៅដល់នៅរដូវវស្សា ពុំត្រូវបានបញ្ចូលក្នុងការសិក្សានេះឡើយ។ ជាលទ្ធផលមានសហគមន៍ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាពចំនួន ១០ ដែលត្រូវបានបញ្ចូលក្នុងការសិក្សាស្រាវជ្រាវនេះ។

គោលបំណងនៃការសិក្សានេះរួមមាន៖

- ប្រៀបធៀបលទ្ធភាពទទួលបានឱកាសហិរញ្ញវត្ថុរបស់ជាតិដើមភាគតិច ដើម្បីអភិវឌ្ឍន៍ជីវិតរបស់ពួកគេ ដូចជា ការទទួលបានកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ និងលទ្ធភាពចូលរួមក្នុងក្រុមសន្សំប្រាក់ ក៏ដូចជាខ្ចីកម្ចីពីអ្នកចងការប្រាក់ ធៀបជាមួយនឹងប្រជាពលរដ្ឋខ្មែរ ដែលរស់នៅតាមភូមិជនបទធម្មតា ព្រមទាំងធ្វើការពិនិត្យ និងចងក្រងទុកជាឯកសារនូវគោលនយោបាយរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលពាក់ព័ន្ធនឹងការទទួលយកប័ណ្ណកម្មសិទ្ធិដីសមូហភាពជាវត្ថុបញ្ចាំ
- ពិនិត្យលើស្ថានភាពស្ត្រីជនជាតិដើមភាគតិច និងបញ្ហាប្រឈមដែលពួកគេជួបប្រទះ ដើម្បីស្វែងយល់ពីសិទ្ធិរបស់ពួកគេ ជាពិសេសពាក់ព័ន្ធនឹងការគាំទ្រដល់ការលើកកម្ពស់ជីវភាពរស់នៅ
- កំណត់ពីឧបសគ្គផ្នែកសមត្ថភាពរបស់សហគមន៍ជនជាតិដើមភាគតិចជាអ្នកទទួលផល ដែលជាការដាក់កំហិតមិនឱ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ពេញលេញពីកម្ចីនានា
- ផ្តល់អនុសាសន៍ជាក់លាក់ដល់ភាគីអ្នកចូលរួមសំខាន់ៗដែលមានតួនាទីក្នុងការគាំទ្រសហគមន៍ជនជាតិដើមភាគតិចចុះបញ្ជីដីសមូហភាពអាចយកទៅអនុវត្តបាន។

## ២.២ វិធីសាស្ត្រ

ក្នុងការរៀបចំការសិក្សានេះ ទីប្រឹក្សាបានធ្វើការពិនិត្យល្អិតល្អន់លើឯកសារពាក់ព័ន្ធនានាស្តីពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ នៅតំបន់ជនបទក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍ណែនាំ និងកម្រងសំណួរ សម្រាប់ការសម្ភាសត្រូវបានរៀបចំឡើង ដោយសហការជាមួយនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅកម្ពុជា។ កម្រងសំណួរទាំងនេះត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ១-៣។ ការសម្ភាស និងការពិភាក្សាក្រុមគោលដៅ ត្រូវបានធ្វើឡើងជាមួយនឹងតំណាងសហគមន៍ជនជាតិដើមភាគតិច គ្រួសារនីមួយៗ ក៏ដូចជាអ្នកផ្តល់សេវាហិរញ្ញវត្ថុ។

ជារួម មានការចុះជួបសហគមន៍ជនជាតិដើមភាគតិចចំនួន ១០។ ក្នុងសហគមន៍ជនជាតិដើមភាគតិចទាំងនេះ មានការរៀបចំការពិភាក្សាក្រុមជាមួយនឹងសមាជិកគណៈកម្មការសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាជាមួយនឹងតំណាងភូមិ និងចាស់ព្រឹទ្ធាចារ្យក្នុងភូមិ។ លើសពីនេះ ការសម្ភាសតាមខ្នងផ្ទះ ក៏ត្រូវបានរៀបចំធ្វើឡើងផងដែរ (សូមមើលឧបសម្ព័ន្ធទី ៦)។ គួរឱ្យសោកស្តាយ ដោយសារការសិក្សានេះធ្វើឡើងនៅរដូវវស្សា ការចុះទៅកាន់សហគមន៍ទាំងនេះជួបនឹងការលំបាកខ្លាំង។ លើសពីនេះ ដោយសារតែពេលធ្វើការសិក្សានេះចំពេលរដូវបង្កបង្កើនផលផងនោះ ប្រជាពលរដ្ឋនៅតំបន់ជនបទរាប់បញ្ចូលទាំងជនជាតិដើមភាគតិចផង មានការមមាញឹកខ្លាំងជាមួយនឹងការងារស្រែចម្ការ

របស់ពួកគេ។ ជនជាតិដើមភាគតិចជាច្រើនគ្រួសារមានផ្ទះតូចៗនៅជិតកន្លែងធ្វើស្រែចម្ការរបស់ពួកគេ ហើយពួកគេស្នាក់នៅជិតកន្លែងធ្វើស្រែចម្ការទាំងនោះ ក្នុងរយៈពេលវែង។ ដូច្នេះ ទីប្រឹក្សាពុំអាចជួបជាមួយអ្នកភូមិទាំងនេះ ដើម្បីសម្ភាសបានឡើយ។ សរុបមានប្រជាពលរដ្ឋចំនួន ៨២ គ្រួសារត្រូវបានសម្ភាស ហើយគ្រប់ដៃគូទាំងអស់ ដែលមានពេលឱ្យសម្ភាស បានចែករំលែកពីទស្សនៈយល់ឃើញ និងបទពិសោធន៍របស់ពួកគេជាចំហ។

ដោយសារតែសំណាកគំរូរបស់គ្រួសារជនជាតិដើមភាគតិច ដែលត្រូវបានសម្ភាសមានទំហំតូច គេពុំអាចទាញចេញនូវសេចក្តីសន្និដ្ឋានជាលក្ខណៈស្ថិតិ ពាក់ព័ន្ធនឹងអត្រានៃការជាប់បំណុលរបស់សហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានអង្កេតនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកទៅតាមការពិភាក្សាក្រុម ការសម្ភាសតាមខ្នងផ្ទះ និងការសម្ភាសជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ក៏ដូចជា ជាមួយអ្នកចងការប្រាក់ គេអាចទាញចេញនូវទិដ្ឋភាពទូទៅអំពីកម្រិតនៃការជាប់បំណុលរបស់ជនជាតិដើមភាគតិច ធៀបជាមួយនឹងប្រជាពលរដ្ឋខ្មែរបាន។

តារាងទី ១ តារាងសង្ខេបបង្ហាញពីសហគមន៍ជនជាតិដើមភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព (គិតត្រឹមខែកញ្ញា ឆ្នាំ ២០១៧)[5]

| ល.រ | ទីតាំង | | | | ឈ្មោះសហគមន៍ | ក្រុមជាតិពន្ធុ | ចំនួនសមាជិក | ចំនួនគ្រួសារ |
|---|---|---|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឃុំ | ភូមិ | | | | |
| ១ | រតនគិរី | អូរជុំ | អូរជុំ | ល្អឺនក្រែន | ល្អឺនក្រែន | ទំពួន | 493 | 135 |
| ២ | រតនគិរី | កូនមុំ | តឺន | ឡាអិន | ឡាអិន | ទំពួន | 828 | 214 |
| ៣ | រតនគិរី | អូរជុំ | ប៉ូយ | ក្រឡា | ក្រឡា | គ្រឹង | 758 | 205 |
| ៤ | រតនគិរី | អូរជុំ | អូរជុំ | ល្អឺនជង | ល្អឺនជង | ទំពួន | 486 | 96 |
| ៥ | រតនគិរី | អូរជុំ | អូរជុំ | ពីរ | ពីរ | គ្រឹង | 680 | 165 |
| ៦ | រតនគិរី | អូរជុំ | ប៉ូយ | តាង៉ាច | តាង៉ាច | គ្រឹង | មិនដឹង | មិនដឹង |
| ៧ | រតនគិរី | អូរជុំ | ប៉ូយ | កងកុយ | កងកុយ | គ្រឹង | មិនដឹង | មិនដឹង |
| ៨ | រតនគិរី | អូរជុំ | ប៉ូយ | ក្រេះ | ក្រេះ | គ្រឹង | មិនដឹង | មិនដឹង |
| ៩ | រតនគិរី | អូរជុំ | ប៉ូយ | កាន់ឈឹង | កាន់ឈឹង | គ្រឹង | មិនដឹង | មិនដឹង |
| | សរុប | ២ ស្រុក | ៣ ឃុំ | ៩ ភូមិ | ៩ សហគមន៍ | | (3245) | (815) |
| ១០ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | អូររណា | អូររណា | ពូង | 373 | 80 |
| ១១ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | អូររណា | អូររណា | ពូង | 123 | 27 |
| ១២ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | ហ្គាទី | ហ្គាទី | ពូង | 215 | 45 |
| ១៣ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | ស្រែខ្ទុម | ស្រែខ្ទុម | ពូង | 404 | 93 |

[5] ព័ត៌មានលម្អិតអាចរកបានក្នុងឧបសម្ព័ន្ធទី ៤។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៤ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | ស្រែល្វី | ស្រែល្វី | ព្នង | 127 | 31 |
| ១៥ | មណ្ឌលគិរី | អូររាំង | សែនមនោរម្យ | អណ្តូងក្រឡឹង | អណ្តូងក្រឡឹង | ព្នង | 453 | 102 |
| ១៦ | មណ្ឌលគិរី | សែនមនោរម្យ | រមនា | ពូត្រុំ | ពូត្រុំ | ព្នង | 875 | 116 |
| | **សរុប** | **៣ ស្រុក** | **៤ ឃុំ** | **៧ ភូមិ** | **៧ សហគមន៍** | | **2570** | **494** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៧ | ក្រចេះ | សំបូរ | អូរគ្រៀង | ពន្ទជា | ពន្ទជា | ព្នង | 546 | 132 |
| ១៨ | ក្រចេះ | សំបូរ | អូរគ្រៀង | អូរកក់ | អូរកក់ | ព្នង | 129 | 37 |
| | **សរុប** | **១ ស្រុក** | **១ ឃុំ** | **២ ភូមិ** | **២ សហគមន៍** | | **675** | **169** |
| | | | | | | | | |
| | **សរុបរួម** | **៦ ស្រុក** | **៨ ឃុំ** | **១៨ ភូមិ** | **១៨ សហគមន៍** | | **(6490)** | **(1478)** |

**តារាងទី ២ សង្ខេបសហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានសិក្សា**

| **ល.រ** | **ទីតាំង** | | | | **ឈ្មោះសហគមន៍** | **ក្រុមជាតិពន្ធុ** |
|---|---|---|---|---|---|---|
| | **ខេត្ត** | **ស្រុក** | **ឃុំ** | **ភូមិ** | | |
| ១ | រតនគិរី | អូរជុំ | អូរជុំ | ល្អឺនក្រែន | ល្អឺនក្រែន | ទំពួន |
| ២ | រតនគិរី | កូនមុំ | តឺន | ឡាអិន | ឡាអិន | ទំពួន |
| ៣ | រតនគិរី | អូរជុំ | អូរជុំ | ល្អឺនជង | ល្អឺនជង | ទំពួន |
| ៤ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | អូររណោ | អូររណោ | ព្នង |
| ៥ | មណ្ឌលគិរី | កែវសីមា | ស្រែព្រះ | អូរប្រា | អូរប្រា | ព្នង |
| ៦ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | ស្រែខ្ទុម | ស្រែខ្ទុម | ព្នង |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | ស្រែល្វី | ស្រែល្វី | ព្នង |
| ៨ | មណ្ឌលគិរី | អូររាំង | សែនមនោរម្យ | អណ្ដូងក្រឡឹង | អណ្ដូងក្រឡឹង | ព្នង |
| ៩ | មណ្ឌលគិរី | សែនមនោរម្យ | រមនា | ពូត្រុំ | ពូត្រុំ | ព្នង |
| ១០ | ក្រចេះ | សំបូរ | អូរគ្រៀង | ពន្ធជា | ពន្ធជា | ព្នង |

នៅក្នុងសហគមន៍ជនជាតិដើមភាគតិចមួយ មានអ្នកចងការប្រាក់ឯកជនម្នាក់ស្ម័គ្រចិត្តឆ្លើយសំណួរពាក់ព័ន្ធនឹងការផ្ដល់កម្ចីចងការដល់អ្នកភូមិ។ លើសពីនេះ ក៏មានការសម្ភាសដាច់ដោយឡែកជាមួយនឹងសមាជិកគណៈកម្មការ និងប្រធានក្រុមសន្សំជាច្រើននាក់ ក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលមានការបង្កើតក្រុមសន្សំប្រាក់ផងដែរ។

បន្ថែមពីលើការចុះប្រមូលព័ត៌មានដល់មូលដ្ឋាន តាមសហគមន៍ជនជាតិដើមភាគតិច ក៏មានការសម្ភាសជាមួយនឹងតំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងខេត្តទាំងបី ពាក់ព័ន្ធនឹងគោលនយោបាយ និងបទពិសោធន៍របស់ពួកគេ ក្នុងការផ្ដល់កម្ចីដល់សមាជិកសហគមន៍ជនជាតិដើមភាគតិច ធៀបនឹងសហគមន៍ជនជាតិខ្មែរ។ នៅតាមទីរួមខេត្តនីមួយៗ ក៏មានការសម្ភាសជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារធំៗ ដែលធ្វើការងារជាមួយសហគមន៍ជនបទផងដែរ។

បន្ទាប់ពីទីប្រឹក្សាបានរៀបចំព្រាងរបាយការណ៍នេះរួច សេចក្ដីព្រាងនេះត្រូវបានដាក់ជូនក្រសួង និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីផ្ដល់ជាយោបល់។ OHCHR បានបញ្ចូលយោបល់ពាក់ព័ន្ធ ដែលមានការផ្ទៀងផ្ទាត់បញ្ជាក់ត្រឹមត្រូវ ទៅក្នុងសេចក្ដីព្រាងចុងក្រោយនៃរបាយការណ៍នេះ។

# ៣. សាវតារ

## ៣.១ សហគមន៍ជនជាតិដើមភាគតិច និងសិទ្ធិដីធ្លីរបស់ពួកគេ

មូលដ្ឋានគតិយុត្តិ ដើម្បីផ្តល់ការទទួលស្គាល់ដល់សិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិជាតិដើមភាគតិចត្រូវបានដាក់ចេញក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១[6]។ ព្រះរាជាណាចក្រកម្ពុជាប្រើប្រាស់វិធីសាស្ត្រផ្អែកតាមសហគមន៍ ដើម្បីផ្តល់ឱ្យសហគមន៍ជនជាតិដើមភាគតិចនូវសិទ្ធិដីធ្លីសម្រាប់ប្រើប្រាស់ជាសមូហភាព។ ខុសពីម្ចាស់ដីឯកជន ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីឯកជនរបស់ខ្លួន ដោយប្រើប្រាស់ដំណើរការចេញប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធ ឬដាច់ដោយដុំ សមាជិកសហគមន៍ជនជាតិដើមភាគតិច ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ពុំត្រូវបានអនុញ្ញាតឱ្យលក់ដីរបស់ពួកគេ (លើកលែងតែសម្រាប់លក់ឱ្យសមាជិកសហគមន៍ដូចគ្នា ឬប្រើប្រាស់ដីសហគមន៍នេះជាវត្ថុបញ្ចាំឡើយ។

ផ្អែកតាមបទពិសោធន៍ ដែលទទួលបានក្នុងអំឡុងពេលចុះបញ្ជីសាកល្បងសហគមន៍ជនជាតិដើមភាគតិចចំនួនបី ដែលត្រូវបានកំណត់អត្តសញ្ញាណដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីកាលពីឆ្នាំ ២០០៤[7] ក្របខ័ណ្ឌគតិយុត្តិដែលកំពុងចូលជាធរមាននេះ ត្រូវបានអនុវត្តតាមរយៈ "គោលនយោ-បាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា" ក្នុងឆ្នាំ ២០០៩។ ក្របខ័ណ្ឌគតិយុត្តិនេះត្រូវបានចែងលម្អិតបន្ថែមទៀត ដោយអនុក្រឹត្យលេខ ៨៣ ស្តីពី "នីតិវិធីស្តីពីការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច" (ឆ្នាំ ២០០៩)។ អនុក្រឹត្យនេះអនុញ្ញាតឱ្យមានការផ្ទេរដីឯកជនរបស់រដ្ឋ ដល់សហគមន៍ជនជាតិដើមភាគតិច។ បន្ថែមពីលើសិទ្ធិសមូហភាពដែលកំពុងមានស្រាប់ ដូចជាសិទ្ធិតាំងទីលំនៅ សិទ្ធិធ្វើកសិកម្ម និងការបម្រុងទុកដីសម្រាប់កសិកម្មពនេចរ អនុក្រឹត្យនេះក៏ផ្តល់ឱ្យសហគមន៍ជនជាតិដើមភាគតិចនូវសិទ្ធិប្រើប្រាស់ដីកប់សព និងដីអារក្សរបស់ពួកគេផងដែរ។ ខណៈពេលដែលប្រភេទនៃការប្រើប្រាស់ដីដទៃទៀតពុំមានកំណត់ទំហំ ផ្ទៃដីអារក្ស និងផ្ទៃដីសម្រាប់កប់សពត្រូវបានកំហិតត្រឹមតែ ៧ ហិចតា សម្រាប់សហគមន៍នីមួយៗតែប៉ុណ្ណោះ។ ដូច្នេះ ដីរបស់សហគមន៍ជនជាតិដើមភាគតិចទាំងអស់ ដែលបំពេញលក្ខណៈសម្បត្តិសមស្រប ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដី ត្រូវបានបែងចែកជាប្រាំប្រភេទ រួមមាន ដីលំនៅដ្ឋាន ដីកសិកម្មឬវាលស្រែ ដីបម្រុង (សម្រាប់កសិកម្មពនេចរ ឬសម្រាប់បែងចែកទៅឱ្យគ្រួសារថ្មីៗ នាពេលអនាគត) ដីកប់សព និងព្រៃអារក្ស។ ចំណុចគួរឱ្យកត់សម្គាល់ ផ្ទៃដីនេះពុំបានរាប់បញ្ចូលព្រៃដែលមានទំហំធំ តំបន់សម្រាប់ប្រមូលអនុផលព្រៃឈើ ឬស្ទឹងបឹងបួរនោះឡើយ។ ជាធម្មតា ប័ណ្ណកម្មសិទ្ធិដីសមូហភាពបញ្ចូលប្រភេទក្បាលដីផ្សេងៗ ដូចបែងចែកជាប្រាំប្រភេទខាងលើនេះ ចន្លោះពី ២០ ទៅ ៧០ ក្បាលដី។

[6] ច្បាប់ភូមិបាល ឆ្នាំ ២០០១ (មាត្រា ២៣ កថាខណ្ឌ ១) ឱ្យនិយមន័យសហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។

[7] សហគមន៍ជនជាតិដើមភាគតិចក្នុងតំបន់សាកល្បង៖ ល្មីនក្រែន និងឡាអិន ក្នុងខេត្តរតនគិរី និងអណ្តូងក្រឡឹង ក្នុងខេត្តមណ្ឌលគិរី។

ជំហានដ៏សំខាន់មួយ ដើម្បីឱ្យសហគមន៍ជនជាតិដើមភាគតិច អាចទទួលបានសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព ត្រូវបានសម្រេចតាមរយៈការអនុម័តលើសារាចរណ៍អន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្ន ដែលចេញដោយក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីឆ្នាំ ២០០១។ វិធានការការពារបណ្តោះអាសន្ន ដែលចេញដោយអភិបាលខេត្ត ហាមឃាត់មិនឱ្យមានការលក់ ជួល ទន្រ្ទាន ឬផ្ទេរដី ដែលទាមទារដោយសហគមន៍ជនជាតិដើមភាគតិចនោះឡើយ។ វិធានការនេះក៏ផ្តល់ឱ្យសហគមន៍ជនជាតិដើមភាគតិច នូវសិទ្ធិប្រើប្រាស់វិធានការតាមផ្លូវច្បាប់ ដើម្បីការពារសិទ្ធិប្រពៃណីរបស់ពួកគេផងដែរ។ វិធានការការពារអាចប្រកាសបានតែដោយអភិបាលខេត្ត បន្ទាប់ពីមានការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសហគមន៍ ទៅកាន់មន្ទីររៀបចំដែនដីនគរូបនីយកម្មសូរិយោដី និងសំណង់ តាមខេត្តសាមីតែប៉ុណ្ណោះ។

ដំណើរការ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពបែងចែកជាបីដំណាក់កាលសំខាន់ៗ ដែលពាក់ព័ន្ធនឹងក្រសួងផ្សេងៗគ្នា ឆ្លងកាត់តាមជំហាន ដូចខាងក្រោម៖

ជំហានទី ១ ស្វ័យអត្តសញ្ញាណកម្ម ការវាយតម្លៃ និងការកំណត់ពីជនជាតិដើមភាគតិច ដោយក្រសួងអភិវឌ្ឍន៍ជនបទ

ជំហានទី ២ ការរៀបចំលក្ខន្តិកៈ និងការចុះបញ្ជីជានីតិបុគ្គលបន្ទាប់ពីបានទទួលការយល់ព្រមពីក្រសួងមហាផ្ទៃ

ជំហានទី ៣ ការចុះបញ្ជីដី ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

មានជនជាតិភាគតិចប្រមាណជា ៤៥៥ សហគមន៍[8] កំពុងមានវត្តមាននៅកម្ពុជា ដែលក្នុងនោះ ១៤១ សហគមន៍បានទទួលការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ និង ១២៨ សហគមន៍ត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ (គិតត្រឹមខែ តុលា ឆ្នាំ ២០១៨)។

គិតត្រឹមចុងឆ្នាំ ២០១៦ មានជនជាតិដើមភាគតិចសរុប ៤៩ សហគមន៍បានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លី ដែលក្នុងនោះមានពាក្យសុំចំនួន ៤៣ ត្រូវបានទទួលយក (ពាក្យសុំចំនួន ៣ ត្រូវបានបដិសេធចោល ក្នុងខេត្តកំពង់ស្ពឺ និង ៣ ទៀតត្រូវបានបដិសេធចោល ក្នុងខេត្តព្រះវិហារ)។ ជនជាតិដើមភាគតិចចំនួន ៤៣ សហគមន៍បានទទួលវិធានការការពារបណ្តោះអាសន្ន។ គិតត្រឹមខែ តុលា ឆ្នាំ ២០១៨ មានសហគមន៍ជនជាតិដើមភាគតិចចំនួន ២៤ ក្នុងខេត្តចំនួន ៤ គឺខេត្តរតនគិរីមានចំនួន១៣សហគមន៍ ខេត្តមណ្ឌលគិរីមានចំនួន៦សហគមន៍ ខេត្តស្ទឹងត្រែងចំនួន១សហគមន៍ និងខេត្តក្រចេះមានចំនួន៤សហគមន៍ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ខ្លួន។

[8] បើតាមការប៉ាន់ប្រមាណដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារជាមួយនឹងសហគមន៍ជនជាតិដើមភាគតិច។

## ៣.២ លទ្ធភាពទទួលបានឥណទាននៅតាមតំបន់ជនបទ

កន្លងមក ការទទួលបានឥណទាននៅតាមតំបន់ជនបទធ្វើឡើង តាមរយៈប្រភពមិនផ្លូវការ។ អ្នកចងការប្រាក់ឯកជន និងសាច់ញាតិ បំពេញតួនាទីយ៉ាងសំខាន់។ ដោយសារតែអ្នកចងការប្រាក់ឯកជនទាមទារការប្រាក់ខ្ពស់ពេក ដែលជារឿយៗអាចមានរហូតដល់ ២០% ក្នុងមួយខែ សម្រាប់កម្ចីរយៈពេលខ្លី កម្ចីទាំងនេះត្រូវការចំណាយខ្ពស់ ហើយត្រូវបានប្រើប្រាស់តែសម្រាប់ករណីបន្ទាន់តែប៉ុណ្ណោះ។ លើសពីនេះមានប្រជាពលរដ្ឋ ដែលរស់នៅជនបទតិចគ្រួសារប៉ុណ្ណោះ ដែលមានលទ្ធភាពផ្តល់វត្ថុបញ្ចាំ ដើម្បីអាចទទួលបានកម្ចីពីធនាគារផ្លូវការបាន។

ស្ថានភាពនេះមានការប្រែប្រួលគួរឱ្យកត់សម្គាល់។ បច្ចុប្បន្ននេះ វិស័យធនាគារផ្លូវការបានពង្រីកខ្លួនដល់តំបន់ជនបទ ដែលអាចផ្តល់ឱ្យប្រជាពលរដ្ឋកម្ពុជា ដែលរស់នៅតាមតំបន់ជនបទនូវលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានសេវាហិរញ្ញវត្ថុ។

បច្ចុប្បន្ននេះ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានសាខានៅគ្រប់ទីរួមខេត្តទាំងអស់ គ្រប់ទីរួមស្រុកទាំងអស់ និងសូម្បីតែនៅតាមឃុំធំៗមួយចំនួន។

ជាទូទៅ គ្រួសារនៅតំបន់ជនបទមានជម្រើសទទួលបានសេវាហិរញ្ញវត្ថុពីប្រភពផ្សេងៗជាច្រើន ជាពិសេសៈ

- ធនាគារ / គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ក្រុមសន្សំភូមិ
- អ្នកចងការប្រាក់ឯកជន
- សាច់ញាតិ / មិត្តភក្តិ / អ្នកជិតខាត
- អង្គការមិនមែនរដ្ឋាភិបាល
- ឈ្មួញ

វិស័យធនាគារនៅកម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គិតត្រឹមឆ្នាំ ២០១៦ ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជចំនួន ៣៧ ធនាគារឯកទេសចំនួន ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧០ (ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលអាចទទួលប្រាក់បញ្ញើបានចំនួន ៧) ប្រតិបត្តិករឥណទានជនបទចំនួន ១៧០ ក្រុមហ៊ុនភតិសន្យាចំនួន ១២ ក្រុមហ៊ុនការិយាល័យឥណទានចំនួន ១ អ្នករៀបចំឯកសារជាភាគីទី៣ ចំនួន ៨ ការិយាល័យតំណាងធនាគារបរទេសចំនួន ៧ និងអ្នកប្តូរប្រាក់ចំនួន ២.២២១ នាក់[9]។

ក្នុងឆ្នាំ ១០១២ ការិយាល័យឥណទានកម្ពុជា (CBC) ត្រូវបានបង្កើតឡើងជាការិយាល័យឥណទានឯកជន ដែលទទួលបានការគាំទ្រពេញទំហឹងពីធនាគារជាតិនៃកម្ពុជា (NBC) សមាគមធនាគារនៅកម្ពុជា (ABC) សមាគមមី

[9] ប្រភពៈ របាយការណ៍ប្រចាំ ២០១៦ នៃធនាគារជាតិនៃកម្ពុជា។

ក្រុហិរញ្ញវត្ថុកម្ពុជា (CMA) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីផ្តល់ការគាំទ្រដល់វិស័យធនាគារកម្ពុជា។ តួនាទីមួយ ក្នុងចំណោមតួនាទីជាច្រើនរបស់ការិយាល័យនេះ គឺការបង្កើតនូវប្រព័ន្ធទិន្នន័យស្តីពីកម្ចីឯកជន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រើប្រាស់ប្រព័ន្ធទិន្នន័យ ដើម្បីត្រួតពិនិត្យភាពអាចជឿទុកចិត្តបានរបស់អតិថិជន ក៏ដូចជាប្រវត្តិខ្ចីកម្ចីរបស់ពួកគេ។

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ បានបន្តពង្រីកប្រតិបត្តិការរបស់ខ្លួនដល់តំបន់ជនបទ ហើយស្របពេលជំណាលគ្នាធ្វើឱ្យមានការងាកចេញពីការរកសេវាពីអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ទៅវិស័យផ្លូវការវិញ។ ឥទ្ធិពលរបស់អ្នកចងការប្រាក់ឯកជនមានការថយចុះយ៉ាងច្រើន។ បច្ចុប្បន្ននេះ សូម្បីតែប្រជាពលរដ្ឋនៅតំបន់ជនបទក៏អាចមានលទ្ធភាពល្អប្រសើរក្នុងការទទួលបានសេវាជានាផ្លូវការផងដែរ។ នេះគឺជាអ្វីដែលកើតមានឡើង ដោយសារតែគ្រប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលផ្តល់កម្ចីដល់អ្នកភូមិតាមតំបន់ជនបទទាំងអស់ សុទ្ធតែមានភ្នាក់ងារជិះម៉ូតូចុះមកដល់តាមភូមិតែម្តង។

ក្រុមសន្សំភូមិត្រូវបានបង្កើតឡើងនៅតាមភូមិជាច្រើននៅកម្ពុជា។ ក្រុមសន្សំភូមិបំពេញនាទីជាស្ថាប័នផ្តល់កម្ចីខ្នាតតូចនៅកម្រិតភូមិ ដែលត្រូវបានបង្កើតឡើងដោយអ្នកភូមិខ្លួនឯង (ភាគច្រើនទទួលបានការគាំទ្រដំបូងៗពីគម្រោង ឬអង្គការមិនមែនរដ្ឋាភិបាល)។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែក្រុមសន្សំនេះតម្រូវឱ្យសមាជិកដាក់ប្រាក់សន្សំក្នុងចំនួនមួយជាក់លាក់ ប្រាក់បញ្ញើជារួមនៅមានកម្រិតតិចតួច ដែលធ្វើឱ្យកម្រិតនៃការផ្តល់ឥណទានក៏មានកម្រិតទាបផងដែរ។ ជាធម្មតា សំណើសុំខ្ចីកម្ចី គឺច្រើនជាងចំនួនប្រាក់ដែលក្រុមអាចផ្តល់ជូនបាន។ ដូច្នេះ ក្រុមសន្សំភូមិជារឿយៗពុំអាចផ្តល់កម្ចីក្នុងចំនួនដែលត្រូវការឱ្យចំពេលដែលគេត្រូវការនោះឡើយ។ លើសពីនេះ កម្ចីពីក្រុមសន្សំភូមិនេះត្រូវបានប្រើប្រាស់ជាកម្ចីខ្នាតតូចសម្រាប់គ្រួសារ និងសម្រាប់ប្រើប្រាស់ក្នុងស្ថានភាពបន្ទាន់ជាជាងសម្រាប់យកទៅអភិវឌ្ឍន៍ដីធ្លី និងសម្រាប់ការវិនិយោគពិតប្រាកដ។

កន្លងមក អង្គការមិនមែនរដ្ឋាភិបាលបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឥណទានខ្នាតតូច។ ដោយសារតែរដ្ឋាភិបាលកម្ពុជាមានគោលបំណងធ្វើនិយ័តកម្មលើវិស័យធនាគារ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានចុះបញ្ជីជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះអង្គការដទៃទៀតកំពុងផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនជាងមុនលើសកម្មភាពអភិវឌ្ឍន៍សហគមន៍ ប៉ុន្តែលែងផ្តល់កម្ចីទៀត។

ឈ្មួញបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់សាច់ប្រាក់ដល់កសិករនៅតាមតំបន់ជនបទរបស់ព្រះរាជាណាចក្រកម្ពុជា។ សម្រាប់ដំណាំដែលអាចប្តូរជាសាច់ប្រាក់បាន ជារឿយៗឈ្មួញម៉ៅ "ដើមឈើ" ឬ "ស្រែចម្ការ" ទាំងមូលសម្រាប់ប្រមូលផលមុនរដូវប្រមូលផលមកដល់។ ក្នុងករណីមួយចំនួន ពួកគេទិញយកផលដែលប្រមូលបានទាំងអស់តែម្តងមុនពេលប្រមូលផលដោយធ្វើការកំណត់តម្លៃមួយថេរ ហើយពេលខ្លះផ្តល់ប្រាក់ដំបូងខ្លះជាការធានាថា កសិផលដែលប្រមូលបានត្រូវតែលក់ទៅឱ្យពួកគេ។ ការធ្វើបែបនេះ ជាការផ្ទេរហានិភ័យនៃការខកខានពុំបានប្រមូលផលពីកសិករ ទៅឱ្យឈ្មួញ។ ប៉ុន្តែ ក្នុងពេលជាមួយគ្នា វាក៏កាត់បន្ថយប្រាក់ចំណូលដែលទទួលបានពីស្រែចម្ការផងដែរ ដោយសារតែជា

រឿយៗតម្លៃដែលផ្តល់ដោយឈ្មួញនេះ គឺទាបជាងតម្លៃលើទីផ្សារ។ លើសពីនេះ ឈ្មួញមួយចំនួនក៏បានផ្តល់ជាកម្ចីសម្រាប់ទិញគ្រាប់ពូជ ជី និងថ្នាំកសិកម្មផងដែរ។ ជារឿយៗ កម្ចីត្រូវបានសងតាមរយៈការលក់ដំណាំទៅឱ្យឈ្មួញដែលផ្តល់កម្ចី។ ការអនុវត្តបែបនេះផ្តល់ឱ្យកសិករនូវសាច់ប្រាក់តិចតួចតែប៉ុណ្ណោះ សម្រាប់វិនិយោគក្នុងផលិតកម្មកសិកម្មរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ចំនួនប្រាក់ដែលផ្តល់ដោយឈ្មួញនេះ អាចជួយឱ្យកសិករដោះស្រាយបញ្ហាខ្វះប្រាក់ចំណូលពីរដូវមួយទៅរដូវមួយទៀតបាន។ ទោះជាយ៉ាងណាក៏ដោយ ចំនួនប្រាក់ទាំងមូលគឺតិចតួចពេក ដែលមិនអាចយកទៅធ្វើការវិនិយោគធំដុំបាន។

## ៣.៣ បំណុល និងការជាប់បំណុលនៅកម្ពុជា

ពុំមានការសិក្សា ឬការអង្កេតស៊ីជម្រៅច្រើន ត្រូវបានធ្វើឡើងអំពីបញ្ហាបំណុល និងបញ្ហាជាប់បំណុលនៅកម្ពុជាឡើយ។ បើតាមការអង្កេតសង្គម សេដ្ឋកិច្ចឆ្នាំ ២០១៥ មានគ្រួសារកម្ពុជា ដែលត្រូវបានសាកសួរ តែប្រហែលជា ៣៨% តែប៉ុណ្ណោះដែលរាយការណ៍ថា ពួកគេជាប់បំណុលក្នុងឆ្នាំ ២០១៥។ នៅតំបន់ជនបទរបស់ព្រះរាជាណាចក្រកម្ពុជា ៤៣% នៃគ្រួសារដែលត្រូវបានសាកសួរបានលើកឡើងថាកំពុងជាប់បំណុលគេ បើធៀបនឹងក្រោម ១០% នៃគ្រួសារនៅទីក្រុងភ្នំពេញ។ ជារួមចំនួនគ្រួសារដែលជាប់បំណុលមានការកើនឡើង ២២% បើធៀបនឹងឆ្នាំមុន។

លើសពីនេះ ចំនួនប្រាក់កម្ចីដែលមិនទាន់សងគិតជាមធ្យមក៏មានការកើនឡើងផងដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសនៅតំបន់ជនបទ ចំនួនប្រាក់កម្ចីដែលនៅមិនទាន់សងមានការកើនឡើងទ្វេដង ចន្លោះពីឆ្នាំ ២០១១ ដល់ ឆ្នាំ ២០១៥។

**តារាងទី ៣ ចំនួនប្រាក់កម្ចី ដែលមិនទាន់សង គិតជាមធ្យម**[10]

| | | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| ប្រទេសកម្ពុជា (ជារួម) | គិតជាពាន់រៀល | ២.២៦៤ | ២.៧៦២ | ៣.៩៥២ | ៤.០៤៣ | ៥.១៥៧ |
| | *សមមូលជាដុល្លារសហរដ្ឋអាមេរិក* | *៥៦៦* | *៦៩១* | *៩៨៨* | *១.០១១* | *១.២៨៩* |
| ទីក្រុងភ្នំពេញ | គិតជាពាន់រៀល | ៦.៤៨៨ | ៣.៨០១ | ៥.៣៩៤ | ៦.៥៨២ | ១០.២៧០ |

[10] ប្រភព៖ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៥ ដែលធ្វើឡើងដោយក្រសួងផែនការ/វិទ្យាស្ថានជាតិស្ថិតិ (២០១៦)។

| | | | | | | |
|---|---|---|---|---|---|---|
| | *សមមូលជាដុល្លារសហរដ្ឋអាមេរិក* | *១.១២២* | *៩៥០* | *១.៣៤៩* | *១.៦៤៦* | *២.៥៦៨* |
| តំបន់ប្រជុំជនដទៃទៀត | គិតជាពាន់រៀល | ៤.៦២២ | ៦.៧៧១ | ៩.៨៥៧ | ៦.៨៩៦ | ៨.៨៧៣ |
| | *សមមូលជាដុល្លារសហរដ្ឋអាមេរិក* | *១.១៥៦* | *១.៦៩៣* | *២.៤៦៤* | *១.៧២៤* | *២.២១៨* |
| តំបន់ជនបទដៃទៀត | គិតជាពាន់រៀល | ១.៩១៣ | ២.២៧៤ | ៣.៣៦៣ | ៣.៦០៩ | ៤.៦០០ |
| | *សមមូលជាដុល្លារសហរដ្ឋអាមេរិក* | *៤៧៨* | *៥៦៩* | *៨៤១* | *៩០២* | *១.១៥០* |

ជារួម អង្គការមិនមែនរដ្ឋាភិបាលបំពេញតួនាទីយ៉ាងសំខាន់ក្នុងនាមជាអ្នកផ្តល់កម្ចី។ ដោយហេតុថា កាលពីពេលថ្មីៗនេះមានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានចុះបញ្ជីជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វិស័យធនាគារផ្លូវការជាអ្នកផ្តល់កម្ចីភាគច្រើននៅតំបន់ជនបទក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១៥ ដោយសារតែរដ្ឋាភិបាលកម្ពុជាមានគោលលបំណងរៀបចំវិស័យធនាគារឱ្យក្លាយជាវិស័យដែលមានលក្ខណៈផ្លូវការ និងធ្វើនិយ័តកម្មលើវិស័យនេះ ភាគរយនេះទំនងជានឹងមានការកើនឡើងបន្ថែមទៀតក្នុងឆ្នាំ ២០១៦ និង ២០១៧។

ប្រភពនៃកម្ចីរបស់ប្រជាពលរដ្ឋតាមតំបន់ជនបទនៅកម្ពុជាត្រូវបានបង្ហាញដោយសង្ខេប ក្នុងតារាងខាងក្រោម៖

**តារាងទី ៤ បំណុលដែលមិនទាន់សង គិតជាមធ្យមបែងចែកទៅតាមប្រភពកម្ចីក្នុងតំបន់ជនបទនៅកម្ពុជា (គិតជាភាគរយ)**[11]

| ប្រភពកម្ចី | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|
| សាច់ញាតិនៅក្នុងប្រទេសកម្ពុជា | ១៨,២ | ១៦,៣ | ១០,៤ | ១១,១ | ៥,៩ |
| សាច់ញាតិនៅក្រៅប្រទេស | ១,៦ | ០,៥ | ០,៩ | ០,៨ | ១,៦ |
| មិត្តភក្តិ / អ្នកជិតខាង | ៦,៣ | ៥,៤ | ៣,៤ | ៣,៧ | ១,៧ |
| អ្នកចងការប្រាក់ | ១៣,៩ | ១៩,៤ | ១៤,៨ | ១១,៨ | ១១,៣ |
| ឈ្មួញ | ១,៥ | ០,៨ | ១,៤ | ១,៩ | ១,២ |
| ម្ចាស់ដី | ០,១ | ០,១ | ០,០ | ០,០ | ០,០ |
| និយោជក់ | ០,១ | ០,១ | ០,៣ | ០,៨ | ០,១ |

[11] ប្រភព៖ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៥ ដែលធ្វើឡើងដោយក្រសួងផែនការ/វិទ្យាស្ថានជាតិស្ថិតិ (២០១៦)។

| | | | | | |
|---|---|---|---|---|---|
| ធនាគារ / គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ១៥,៥ | ២៤,០ | ៣៣,៩ | ៤៧,៩ | ៥៦,៦ |
| អង្គការមិនមែនរដ្ឋាភិបាល | ៤០,៥ | ៣២,១ | ៣៤,២ | ២១,៩ | ២០,៦ |
| ដទៃទៀត | ២,៣ | ១,៣ | ០,៧ | ០,៩ | ១,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

ការទទួលបានកម្ចីតាមរយៈប្រភពក្រៅផ្លូវការ ដូចជាអ្នកចងការប្រាក់ឯកជនមានការថយចុះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែប្រជាពលរដ្ឋនៅតំបន់ជនបទកាន់តែអាចទទួលបានសេវាពីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ដូចជាដោយសារតែអត្រាការប្រាក់ ដែលគិតដោយគ្រឹះស្ថានធនាគារផ្លូវការ បានថយចុះបន្តិចម្តងៗ។ បើតាមធនាគារជាតិនៃកម្ពុជា[12] អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថយចុះពី ៣៦% ក្នុងមួយឆ្នាំក្នុងឆ្នាំ ២០០៦ មកនៅ ២៣,៥% ក្នុងមួយឆ្នាំ ២០១៥។ ក្នុងខែ មីនា ឆ្នាំ ២០១៧ អត្រាការប្រាក់សម្រាប់កម្ចី ដែលផ្តល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់ខ្ពស់បំផុតត្រឹម ១,៥% ក្នុងមួយខែតែប៉ុណ្ណោះ (១៨% ក្នុងមួយឆ្នាំ)។ លើសពីនេះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចាប់ផ្តើមផ្តល់កម្ចីដល់គ្រួសារនីមួយៗ ដោយប្រើប្រាស់ការទទួលខុសត្រូវជាក្រុម ពោលគឺមិនចាំបាច់មានការផ្តល់វត្ថុបញ្ចាំដូចមុនៗ ដូចជាប័ណ្ណកម្មសិទ្ធិដីនោះឡើយ។

ពាក់ព័ន្ធនឹងបញ្ហាជាប់បំណុលរបស់គ្រួសារខ្មែរជនបទនៅជនបទវិញ ការសិក្សារបស់គម្រោងជាច្រើនបង្ហាញពីទិន្នន័យដែលពាក់ព័ន្ធនឹងបញ្ហានេះ។ ដើម្បីប្រើប្រាស់ទិន្នន័យដែលអាចយកមកធ្វើការប្រៀបធៀបគ្នាបាន អ្នករៀបចំរបាយការណ៍នេះបានធ្វើការវាយតម្លៃល្អិតល្អន់លើទិន្នន័យ ដែលអាចទទួលបានពីការអង្កេតដើមគ្រា ជាមួយនឹងគ្រួសារខ្មែរដែលមានជីវភាពក្រីក្រដែលរស់នៅលើដីសម្បទានសង្គមកិច្ច[13]។ សម្រាប់ការសិក្សាដើមគ្រាទាំងពីរនេះ ប្រជាពលរដ្ឋដែលទទួលបានដីចំនួន ២.១៧៣ គ្រួសារ ត្រូវបានសម្ភាសក្នុងទីតាំងដីសម្បទានសង្គមកិច្ចចំនួន ១៧ ក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ក្រចេះ និងត្បូងឃ្មុំ។

មានប្រជាពលរដ្ឋដែលត្រូវបានសម្ភាសក្នុងភាគរយមួយខ្ពស់ បញ្ជាក់ថាកំពុងជាប់បំណុល និងជាប់កម្ចី។

**តារាងទី ៥ សង្ខេបពីបន្ទុកបំណុលរបស់គ្រួសារក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំង ១៧**

| ដីសម្បទានសង្គមកិច្ច | ខេត្ត | ភាគរយនៃគ្រួសារដែលត្រូវបានសម្ភាស ដែលកំពុងជាប់បំណុល និងជាប់កម្ចី |
|---|---|---|
| ទិព្វ ១ | កំពង់ធំ | ៧៤,៦% |
| ទិព្វ ២ | កំពង់ធំ | ៨៥,៧2% |
| ជា | ក្រចេះ | ៦៧,៥% |

[12] ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១៦ នៃធនាគារជាតិនៃកម្ពុជា។

[13] ការអង្កេតដើមគ្រាសម្រាប់គម្រោង ILF ដំណាក់កាលទី I និងដំណាក់កាលទី II (ឯកសារផ្ទៃក្នុង) ធ្វើឡើងដោយ GIZ (២០១៥ & ២០១៦)។

| | | |
|---|---|---|
| ថ្មី | ក្រចេះ | ៥៨,៦% |
| ចំបក់ | ក្រចេះ | ៨៣,៧% |
| ចំបក់-ចង្រ្កង ១ | ក្រចេះ | ៧០,៦% |
| ចំបក់-ចង្រ្កង់ ២ | ក្រចេះ | ៦៨,៨% |
| ដាំ ក្រវៀន | ត្បូងឃ្មុំ | ៦៩,៥% |
| គិរី អភិវឌ្ឍន៍ | កំពង់ឆ្នាំង | ៦៩,៨% |
| ខ្សាច់ ស | កំពង់ឆ្នាំង | ៦៧,៣% |
| ចំបក់ ក្រៀល | កំពង់ឆ្នាំង | ៦៧,៥% |
| សុខ សែនជ័យ | កំពង់ឆ្នាំង | ៧០,៤% |
| ព្រៃធំ | កំពង់ស្ពឺ | ៧៤,១% |
| សុជាតិ | កំពង់ធំ | ៧៨,០% |
| ប្រាំងបាក់ | កំពង់ធំ | ៦៥,៨% |
| សែនសិរីមង្គល | កំពង់ធំ | ៨៣,៨% |
| កំពង់ដំរី/ដំរីផុង | ក្រចេះ | ៦៩,៣% |

## តារាងទី ៦ ចំនួនប្រាក់បំណុលគិតជាមធ្យមក្នុងមួយគ្រួសារ

| ដីសម្បទានសង្គមកិច្ច | ចំនួនប្រាក់បំណុលគិតជាមធ្យមក្នុងមួយគ្រួសារ [គិតជារៀល] | ចំនួនប្រាក់បំណុលគិតជាមធ្យមក្នុងមួយគ្រួសារ [គិតជាដុល្លារ] | ចំនួនបំណុលច្រើនជាងគេក្នុងមួយគ្រួសារ [គិតជារៀល] |
|---|---|---|---|
| ទិពូ ១ | ១.៤០០.៨៣៧ | ៣៥០ | ១៨.០០០.០០០ |
| ទិពូ ២ | ៣.៣១៥.៨០០ | ៨២៩ | ១៨.៤០០.០០០ |
| ដា | ១.៣៧៥.៨០០ | ៣៤៤ | ១២.៥០០.០០០ |
| ថ្មី | ១.០៥៨.២០០ | ២៦៥ | ៤.០០០.០០០ |
| ចំបក់ | ២.១២១.១០០ | ៥៣០ | ១៦.០០០.០០០ |
| ចំបក់-ចង្រ្កង ១ | ២.០៣៨.២៥៣ | ៥១០ | ២០.០០០.០០០ |
| ចំបក់-ចង្រ្កង់ ២ | ២.៤០៦.៣២៨ | ៦០២ | ១០.០០០.០០០ |
| ដាំ ក្រវៀន | ២.០២៥.២៧៧ | ៥០៦ | ១៥.២០០.០០០ |
| គិរី អភិវឌ្ឍន៍ | ៣.២៧៩.១៤៨ | ៨២០ | ៥៨.០០០.០០០ |
| ខ្សាច់ ស | ៤.០៧៤.៥៣៣ | ១.០១៩ | ៦៨.០០០.០០០ |
| ចំបក់ ក្រៀល | ៣.៩១៦.៨៩៦ | ៩៧៩ | ១០៥.០០០.០០០ |

| | | | |
|---|---|---|---|
| សុខ សែនជ័យ | ២.៥៩៤.១៤៣ | ៦៤៩ | ១00.000.000 |
| ព្រែជំ | ២.២៥៨.២៧៩ | ៥៦៥ | ១២0.000.000 |
| សុជាតិ | ៦.៣២២.៥00 | ១.៥៨១ | ៤៨.000.000 |
| ច្រាំងបាក់ | ៣.0៣២.000 | ៧៥៨ | ១0.000.000 |
| សែនសិរីមង្គល | ៣.៣១១.៧៩0 | ៨២៨ | ៣២.000.000 |
| កំពង់ដំរី/ដំរីផុង | ៦.0២២.៧៤៧ | ១.៥0៦ | ៩២.000.000 |

ចំនួនប្រាក់បំណុលគិតជាមធ្យមក្នុងមួយគ្រួសារ បង្ហាញពីការជាប់បំណុលក្នុងកម្រិតមួយខ្ពស់ខ្លាំងក្នុងចំណោមប្រជាពលរដ្ឋដែលជាអ្នកទទួលបានដី។ បើគិតពីអត្រាការប្រាក់បច្ចុប្បន្ន ដែលគិតដោយអ្នកផ្ដល់កម្ចីផ្សេងៗ និងបើធៀបជាមួយនឹងកម្រិតនៃប្រាក់ចំណូលជាក់ស្ដែង គេអាចនិយាយយ៉ាងប្រាកដនិយមថា គ្រួសារភាគច្រើនកំពុងជាប់ក្នុងអន្ទាក់បំណុល។ ក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាស ប្រមាណជា ៣៥% បានលើកឡើងថា ចំណាយប្រចាំខែរបស់ពួកគេលើសពីចំណូលប្រចាំខែរបស់ពួកគេកាលពីខែមុននេះ។

គ្រួសារភាគច្រើនជាប់បំណុលជាមួយនឹងអ្នកផ្ដល់កម្ចីលើសពីមួយ។ កម្ចីភាគច្រើនមានប្រភពពីអ្នកចងការប្រាក់ឯកជន និងគ្រឹះស្ថានដែលផ្ដល់ឥណទានផ្លូវការ។ អត្រាការប្រាក់ដែលគិតដោយអ្នកចងការប្រាក់ឯកជន ជារឿយៗអាចនៅចន្លោះពី ១០-២០% ក្នុងមួយខែ។ អត្រាការប្រាក់ជាមួយធនាគារ និងគ្រឹះស្ថានឥណទាន គឺចន្លោះពី ២-៥% ក្នុងមួយខែ ប៉ុន្តែឥឡូវនេះមានការថយចុះដោយសារតែលិខិតបទដ្ឋានគតិយុត្តិដែលទើបចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

លើសពីនេះការសិក្សាស្ដីពីការជាប់បំណុលនៅកម្ពុជា[14] ដែលត្រូវបានធ្វើឡើងនៅតាមភូមិមួយចំនួន ដែលមានវត្តមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន[15] បានសន្និដ្ឋានថា អតិថិជនប្រមាណ ២២% ក្នុងសំណាកគំរូ ១.៤៨០ គ្រួសារ ពុំអាចសងបំណុលបាន ឬជាប់ជំពាក់បំណុលច្រើនលើសលប់, ៥៦% "អាចសងបាន" ដែលមានន័យថា ការសងបំណុលប្រចាំខែរបស់ពួកគឺស្រូបយកប្រាក់ចំណូលប្រចាំខែរបស់ពួកគេរហូតដល់ ៧៥%។ អ្នកខ្ចីកម្ចី ១២% ត្រូវបានដាក់ចំណាត់ថ្នាក់ថា "ហានិភ័យ" និង ១០% ពុំអាចបែងចែកចំណាត់ថ្នាក់បាន ដោយសារតែពុំមានទិន្នន័យ។

ការសិក្សានេះបានកំណត់ថា ការខ្ចីកម្ចីពីច្រើនប្រភពថាជាកត្តាដ៏សំខាន់មួយ ដែលធ្វើឱ្យប្រជាពលរដ្ឋជាប់បំណុលវ័ណ្ឌក។ ក្នុងចំណោមអ្នកខ្ចីកម្ចីចំនួន ១.៣២៦ នាក់ ក្នុងសំណាកគំរូនេះ ៥៦% មានកម្ចីលើសពីមួយ ២៨% មានកម្ចីចំនួនពីរ ១៣% មានកម្ចីចំនួនបី ៩% មានកម្ចីចំនួនបួន និង ៦% មានកម្ចីលើសពីបួន។

[14] វិទ្យាស្ថានកម្ពុជា ដើម្បីសិក្សាពីការអភិវឌ្ឍ (២០១៣)។ ការសិក្សាពីកត្តាដែលធ្វើឱ្យអ្នកខ្ចីកម្ចីខ្នាតតូចជាប់បំណុលវ័ណ្ឌកនៅកម្ពុជា៖ ការអង្កេតស៊ីជម្រៅលើតំបន់ដែលមានវត្តមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុច្រើន។

[15] ការសិក្សានេះជ្រើសរើសតំបន់សម្រាប់ធ្វើការសិក្សាផ្អែកទៅតាមការគ្របដណ្ដប់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ មានតែភូមិដែលទទួលបានការគ្របដណ្ដប់ទាំងស្រុងដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែប៉ុណ្ណោះ ដែលត្រូវបានវាយតម្លៃ។

# ៤. លទ្ធផលរកឃើញ

## ៤.១ សង្ខេបព័ត៌មានអំពីសហគមន៍ជនជាតិដើមភាគតិចដែលបានចុះទៅ

នៅក្នុងជំពូកនេះ មានការបង្ហាញពីការសង្កេតឃើញសំខាន់ៗមួយចំនួនអំពីសហគមន៍ជនជាតិដើមភាគតិចនីមួយៗ ដែលត្រូវបានចុះជួបក្នុងខែ កក្កដា ឆ្នាំ ២០១៧ ក្នុងអំឡុងពេលនៃការសិក្សានេះ។ ព័ត៌មាននេះជួយឱ្យគេយល់ពីការវាយតម្លៃទូទៅ និងសេចក្តីសន្និដ្ឋានជារួម។

ទិន្នន័យពាក់ព័ន្ធស្តីពីប័ណ្ណកម្មសិទ្ធិដីសមូហភាព ដែលត្រូវបានចេញទៅឱ្យសហគមន៍ជនជាតិដើមភាគតិចទាំង ១៨ ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធទី ៤។

### ខេត្តរតនគិរី

១. សហគមន៍ល្អឺនក្រែន

- មានទីតាំងនៅជិតក្រុងបានលុង (៨ គីឡូម៉ែត្រ ផ្លូវស្រួលធ្វើដំណើរ ផ្លូវលំប្រវែង ១.៥ គីឡូម៉ែត្រ)
- មានគណៈកម្មការសហគមន៍ ដែលមានភាពរឹងមាំ មានសាមគ្គីភាព និងភាពចុះសម្រុងគ្នាខ្ពស់ ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិចនេះ
- ផ្ទៃដីដែលស្ថិតនៅក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺនៅដដែល ពុំមានទំនាស់ជាមួយអ្នកខាងក្រៅ ពុំមានការទន្ទ្រានយកដី មានទំនាស់តិចតួចមួយចំនួននៅក្នុងព្រំប្រទល់ដី ដែលអាចដោះស្រាយបានសះជានៅក្នុងមូលដ្ឋានផ្ទាល់
- ដីបម្រុងត្រូវបានបែងចែកដល់សមាជិកសហគមន៍ជនជាតិដើមភាគតិច ពុំមានដីដែលនៅសល់សម្រាប់ចែកទៅឱ្យគ្រួសារថ្មីៗឡើយ
- សហគមន៍ជនជាតិដើមភាគតិចពេញចិត្តខ្លាំងជាមួយនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាព
- សមាជិកបានលើកឡើងថា ប្រសិនបើពុំមានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះទេ ពួកគេប្រហែលជាត្រូវបាត់បង់ដីធ្លី និងសហគមន៍ទាំងមូលរបស់ពួកគេជាមិនខាន
- សមាជិកសហគមន៍ជនជាតិដើមភាគតិចពុំមានបំណងលក់ដីទៅឱ្យអ្នកខាងក្រៅឡើយ
- លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្នកចងការប្រាក់ឯកជន ក្រុមសន្សំភូមិ សាច់ញាតិលក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការទទួលប្រាក់កក់ជាមុនពីឈ្មួញ ដែលមកទិញកសិផលពីពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - មានសាលាបឋមសិក្សានៅក្នុងភូមិនេះ ដែលបើកដំណើរការធម្មតា

- ការផ្គត់ផ្គង់ទឹក៖ មានអណ្តូងមួយចំនួន និងទឹកអូ ស្ទឹង
- សេវាសុខភាព៖ មណ្ឌលសុខភាពស្រុក មន្ទីរពេទ្យខេត្ត
- អគ្គិសនី៖ មានអគ្គិសនីប្រើប្រាស់តាំងពីពីរខែមុនពេលចុះទៅមកម្លេះ

## ២. សហគមន៍ឡាអិន

- មានទីតាំងនៅមិនឆ្ងាយប៉ុន្មានពីក្រុងបានលុង (២៦ គីឡូម៉ែត្រ ផ្លូវងាយស្រួលទៅមក នៅសល់កំណាត់ផ្លូវលំ ៥ គីឡូម៉ែត្រ និងផ្លូវកំពុងសាងសង់)
- សហគមន៍នេះមានដីសមូហភាព ១.២១៨,៥៦ ហិចតា ដែលក្នុងនោះផ្ទៃដី ៧៣៦ ហិចតា គឺជាផ្ទៃដីបម្រុងសម្រាប់ធ្វើកសិកម្ម
- ការដឹកនាំសហគមន៍មានកម្រិតខ្សោយខ្លាំង និងមានភាពចុះសម្រុងគ្នាក្នុងសង្គមក្នុងកម្រិតមួយទាប មានបញ្ហាសង្គមជាច្រើន (ឧទាហរណ៍ ការញៀនស្រាជាដើម)
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច
- មានការទន្ទ្រានយកដីពីភូមិជិតខាង
- ដីសក្ការៈមួយផ្នែកត្រូវបានប្រើប្រាស់ជាដីសម្រាប់ធ្វើកសិកម្ម
- មេភូមិជាប់ពាក់ព័ន្ធនឹងការលក់ដីទៅអ្នកខាងក្រៅ (តែទោះយ៉ាងណាទង្វើនេះមិនត្រូវបានគាំទ្រដោយអាជ្ញាធរឃុំទេ)
- សមាជិកសហគមន៍ជនជាតិដើមភាគតិចនៅពេញចិត្តជាមួយនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាព ប្រសិនបើពុំមានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះទេ ពួកគេអាចនឹងបាត់បង់ដីទាំងអស់
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (គ្រួសារប្រមាណពី ៧០-៨០% ជាប់កម្ចីក្រោមគម្រោងខ្ចីជាក្រុមជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនមួយ) សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋរចនាសម្ព័ន្ធសង្គម
    - សាលាបឋមសិក្សាទើបតែនឹងសាងសង់ដោយអង្គការ KfW
    - ការផ្គត់ផ្គង់ទឹក៖ មានការលំបាក មានអណ្តូងមួយចំនួន និងទឹកទន្លេ
    - សេវាសុខភាព៖ មណ្ឌលសុខភាពស្រុក មន្ទីរពេទ្យខេត្ត
    - ពុំបានភ្ជាប់ជាមួយបណ្តាញអគ្គិសនីឡើយ

## ៣. សហគមន៍ល្មីនជង

- មានទីតាំងនៅជិតក្រុងបានលុង (ចម្ងាយ ១២ គីឡូម៉ែត្រ ផ្លូវទៅមកស្រួល នៅសល់ផ្លូវលំកំណាត់ចុងក្រោយ ៥ គីឡូម៉ែត្រ)

- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច
- មានការទន្ទ្រានដីមួយចំនួនលើដីបម្រុងទុក (ពុំដឹងពីក្រឡាផ្ទៃ ប៉ុន្តែត្រូវបានប៉ាន់ប្រមាណថាតិចជាង ១០%)
- សមាជិកសហគមន៍ជនជាតិដើមភាគតិចនៅតែពេញចិត្តជាមួយនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្នកចងការប្រាក់ឯកជន ក្រុមសន្សំភូមិ សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - សាលាបឋមសិក្សាមាននៅក្នុងភូមិនេះ និងកំពុងបើកដំណើរការជាធម្មតា
    - ការផ្គត់ផ្គង់ទឹក៖ អណ្តូងមួយចំនួន និងទឹកអូ ស្ទឹង
    - សេវាសុខភាព៖ មណ្ឌលសុខភាពស្រុក មន្ទីរពេទ្យខេត្ត
    - ពុំបានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនីឡើយ

## ខេត្តមណ្ឌលគិរី

៤. អូររណោ

- មានទីតាំងនៅក្នុងស្រុកកែវសីម៉ា (៥ គីឡូម៉ែត្រពីផ្លូវជាតិ) ជាប់ព្រំប្រទល់ជាមួយនឹងតំបន់ការពារ
- គណៈកម្មការសហគមន៍ខ្សោយខ្លាំង បែកបាក់សាមគ្គី និងភាពចុះសម្រុងគ្នាក្នុងសង្គមរបស់សមាជិកដែលជាជនជាតិដើមភាគតិច
- មានអ្នកភូមិតែមួយចំនួនតូចតែប៉ុណ្ណោះ ដែលនៅបន្តជាសមាជិកសកម្មនៅក្នុងសហគមន៍ជនជាតិដើមភាគតិចនេះ
- បើតាមអ្នកភូមិដែលត្រូវបានសម្ភាស មេភូមិធ្វើការប្រឆាំងនឹងផលប្រយោជន៍របស់សហគមន៍ជនជាតិភាគតិច
- ការទន្ទ្រានដីជាទ្រង់ទ្រាយធំមកលើដីបម្រុងទុកទាំងមូល (ជាង ២០០ ហិចតា)
- អ្នកភូមិ ដែលជាជនជាតិដើមភាគតិច កំពុងទន្ទ្រានយកដីក្នុងតំបន់ការពារបរិស្ថានដែលនៅជិតនោះ (ប្រមាណ ២០ គ្រួសារ)
- អូររណោ គឺជាសហគមន៍ជនជាតិដើមភាគតិចតែមួយគត់ ដែលមានប័ណ្ណកម្មសិទ្ធិជាសមូហភាពដែលកំពុងរង់ចាំដំណើរការក្តីនៅតុលាការ ដោយក្រុមមេធាវី វិន្ត្ន ជាអ្នកដាក់ពាក្យបណ្តឹងទៅកាន់តុលាការឧទ្ធរណ៍ក្នុងទីក្រុងភ្នំពេញ។ អធិបញ្ញារបស់សាលាដំបូង និងដែលទទួលបានការបញ្ជាក់ពីសាលាឧទ្ធរណ៍កាត់ក្តីឱ្យសហគមន៍ជាអ្នកឈ្នះ ប៉ុន្តែពុំត្រូវបានអនុវត្តឡើយកន្លងមក។

- សមាជិកសហគមន៍ជនជាតិដើមភាគតិចស្ទើរតែទាំងអស់ចង់បានការចេញប័ណ្ណកម្មសិទ្ធិដីបុគ្គល។ កន្លងមក មានការដាក់សំណើទៅកាន់រដ្ឋបាលឃុំឱ្យលប់ចោលសហគមន៍ជនជាតិដើមភាគតិច និងប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - មានសាលាបឋមសិក្សានៅក្នុងភូមិនេះ និងបើកដំណើរការជាធម្មតា
    - ការផ្គត់ផ្គង់ទឹក៖ ទឹកអណ្តូង
    - សេវាសុខភាព៖ មណ្ឌលសុខភាពនៅស្រែខ្ទុម ឬមន្ទីរពេទ្យអូររាំង
    - ភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនី

### ៥. អូរព្រា

- មានទីតាំងក្នុងស្រុកកែវសីម៉ា (១៤ គីឡូម៉ែត្រពីផ្លូវធំ ផ្លូវពិបាកខ្លាំង ស្ពានកំពុងសាងសង់ ផ្លូវរាំងមិនអាចឆ្លងកាត់បានត្រង់កន្លែងដែលមានកម្ពស់ទឹកជ្រៅ) ជាប់ព្រំប្រទល់ជាមួយនឹងតំបន់ការពារ
- គណៈកម្មការសហគមន៍នៅខ្សោយ នៅមានសាមគ្គីភាព និងភាពស៊ីសង្វាក់គ្នាក្នុងចំណោមសមាជិកជាជនជាតិដើមភាគតិច
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកក្នុងសហគមន៍ជនជាតិដើមភាគតិច
- ការទន្ទ្រានដី ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងតំបន់ការពារជុំវិញពីសំណាក់ភូមិដែលនៅជិតខាង ភាគច្រើនជាការទន្ទ្រានយកដីបម្រុងទុក និងមានការទន្ទ្រានយកដីចម្ការមួយចំនួន
- មានការគាំទ្រពីអង្គការអភិរក្សសត្វព្រៃ (WCS) មន្ទីរបរិស្ថាន និងអង្គការជនជាតិដើមភាគតិចកម្ពុជា ក្នុងការធ្វើការអង្កេតដីធ្លី ដើម្បីកំណត់ពីផែនទីដែលបង្ហាញពីទំហំនៃការទន្ទ្រានយកដី ដែលមានប័ណ្ណកម្មសិទ្ធិដីសហគមន៍
- សហគមន៍ជនជាតិដើមភាគតិចចង់បានប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - មានសាលាបឋមសិក្សានៅក្នុងភូមិនេះ ដែលបើកដំណើរការជាធម្មតា
    - ការផ្គត់ផ្គង់ទឹក៖ ទឹកអណ្តូង
    - សេវាសុខភាព៖ មណ្ឌលសុខភាពស្រែខ្ទុម
    - ពុំបានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនីឡើយ

### ៦. ស្រែខ្ទុម

- មានទីតាំងក្នុងស្រុកកែវសីម៉ា (៨ គីឡូម៉ែត្រពីផ្លូវធំ ពិបាកចូលទៅដល់ ស្ពានកំពុងសាងសង់ ផ្លូវវាងមិនអាចឆ្លងកាត់បាន ត្រង់កន្លែងដែលមានកម្ពស់ទឹកជ្រៅ)
- គណៈកម្មការសហគមន៍នៅខ្សោយ នៅមានសាមគ្គីភាព និងភាពស៊ីសង្វាក់គ្នាមួយចំនួនក្នុងចំណោមសាមជិកជាជនជាតិដើមភាគតិច
- មិនមែនអ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិចនេះឡើយ
- មានការទន្ទ្រានដីដែលស្ថិតនៅក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាពមួយចំនួនពីសំណាក់អ្នកភូមិមកពីភូមិអូររណា ពាក្យបណ្តឹងត្រូវបានដាក់ទៅកាន់ឃុំរួចរាល់
- ដីបម្រុងត្រូវបានបែងចែកស្មើគ្នាទៅឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិច ជាវិធានការការពារ ដើម្បីបង្ការមិនឱ្យមានការទន្ទ្រានយកដីបន្ថែមទៀត
- ដីព្រៃកប់សព និងដីព្រៃអារក្សពុំមានការប្រែប្រួលឡើយ មានការលក់ដីមួយចំនួនក្នុងចំណោមសមាជិក និងទៅឱ្យអ្នកខាងក្រៅ (ការលក់ដីដែលពុំមានចុះបញ្ជីត្រឹមត្រូវ)
- សមាជិកភាគច្រើននៃសហគមន៍ជនជាតិដើមភាគតិចចង់បានប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈឯកជន ដើម្បីអាចការពារសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ តទល់នឹងការទន្ទ្រានយកដី
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (គ្រួសារភាគច្រើនជាប់កម្ចីជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) អ្នកចងការប្រាក់ ក្រុមសន្សំភូមិ សាច់ញាត់ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
  - សាលាបឋមសិក្សាកំពុងត្រូវបានសាងសង់
  - ការផ្គត់ផ្គង់ទឹក៖ ទឹកភ្លៀង
  - សេវាសុខភាព៖ មណ្ឌលសុខភាពនៅស្រែខ្ទុម
  - បានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនី

### ៧. ស្រែល្វី

- មានទីតាំងក្នុងស្រុកកែវសីម៉ា (១០ គីឡូម៉ែត្រពីផ្លូវធំ ផ្លូវមិនអាចចូលទៅតាមឡានបានឡើយ)
- គណៈកម្មការសហគមន៍នៅខ្សោយ ពុំមានការពង្រឹងបទបញ្ជាផ្ទៃក្នុង
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច
- ពុំមានការទន្ទ្រានយកដីពីអ្នកខាងក្រៅ ដីបម្រុងទុកត្រូវបានកាន់កាប់ដោយសមាជិកសហគមន៍ជនជាតិដើមភាគតិច ពុំមានដីដែលសល់សម្រាប់ចែកទៅឱ្យគ្រួសារថ្មីឡើយ ពុំមានការប៉ះពាល់ដីព្រៃកប់សព និងដីព្រៃសក្ការៈឡើយ

- សហគមន៍ជនជាតិដើមភាគតិចចង់បានប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - មានសាលាបឋមសិក្សានៅក្នុងភូមិនេះដែលបើកដំណើរការជាធម្មតា
    - ការផ្គត់ផ្គង់ទឹក៖ ទឹកអណ្តូង
    - សេវាសុខភាព៖ មណ្ឌលសុខភាពនៅក្នុងភូមិអូររណា
    - ពុំមានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនីឡើយ

## ៨. អណ្តូងក្រឡឹង

- មានទីតាំងមិនឆ្ងាយប៉ុន្មានពីក្រុងសែនមនោរម្យឡើយ (៤ គីឡូម៉ែត្រពីផ្លូវធំ ផ្លូវ ឡានពុំអាចចូលដល់នៅរដូវវស្សា)
- គណៈកម្មការសហគមន៍មានភាពរឹងមាំ មានសាមគ្គីភាព និងភាពចុះសម្រុងគ្នាខ្ពស់ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច
- មានការទន្ទ្រានយកដីមួយចំនួនពីអ្នកខាងក្រៅ
- ពុំមានការលក់ដីទៅឱ្យអ្នកខាងក្រៅឡើយ
- មានទំនាស់ដីធ្លីផ្ទៃក្នុងមួយចំនួន មេភូមិ និងគណៈកម្មការបំពេញតួនាទីសំខាន់ក្នុងការដោះស្រាយទំនាស់នានា
- សហគមន៍ជនជាតិដើមភាគតិចចង់បានប័ណ្ណកម្មសិទ្ធិដីសមូហភាពដើម្បីការពារដីធ្លីរបស់ពួកគេ
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - មានសាលាបឋមសិក្សានៅក្នុងភូមិនេះ ដែលបើកដំណើរការជាធម្មតា
    - សេវាសុខភាព៖ ពុំមានប៉ុស្តិ៍សុខភាពឡើយ
    - ការផ្គត់ផ្គង់ទឹក៖ ពុំមានព័ត៌មាន
    - ពុំត្រូវបានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនី

## ៩. ពូត្រាំ

- មានទីតាំងនៅជិតក្រុងសែនមនោរម្យ (៦ គីឡូម៉ែត្រពីសែនមនោរម្យ ផ្លូវលំល្អ)

- "ភូមិដំរី" ទទួលបានការគាំទ្រពីអង្គការឈ្មោះ ELIE (Elephant Livelihood Initiative Environment)
- គណៈកម្មការសហគមន៍មានភាពរឹងមាំ មានសាមគ្គីភាព និងភាពចុះសម្រុងគ្នាខ្ពស់ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច
- មានការទន្ទ្រានយកដីពីអ្នកខាងក្រៅ
- ពុំមានការលក់ដីទៅឱ្យអ្នកខាងក្រៅឡើយ បន្ទាប់ពីមានប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ទទួលរងសម្ពាធជាច្រើនពីអ្នកខាងក្រៅ ដែលចង់ទិញដី ដែលស្ថិតនៅក្រោមប័ណ្ណកម្មសិទ្ធិដីសហគមន៍នេះ។ គេឃើញមានផ្លាក "ដីសម្រាប់លក់" មួយចំនួននៅក្នុងភូមិនេះ
- សហគមន៍ជនជាតិដើមភាគតិចចង់បានប័ណ្ណកម្មសិទ្ធិដីសហគមន៍ ដើម្បីការពារដី (មេភូមិប្រៀបធៀបប័ណ្ណកម្មសិទ្ធិដីជាសមូហភាពជាមួយនឹងសត្វពាហនៈដែរ៖ ប្រសិនបើពុំដាក់នៅក្នុងរបងទេ ពួកវានឹងរត់អស់។ មនុស្សមានចំនួនកើនឡើង ប៉ុន្តែដីពុំកើនឡើងឡើយ
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ សាច់ញាតិ លក់ដី (ក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច) ការបង់ប្រាក់ជាមុនពីឈ្មួញដែលមកទិញកសិផលរបស់ពួកគេ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
    - មានសាលាបឋមសិក្សានៅក្នុងភូមិនេះ និងបើកដំណើរការជាធម្មតា
    - សេវាសុខភាព៖ ក្នុងក្រុងសែនមនោរម្យ
    - ការផ្គត់ផ្គង់ទឹក៖ ទឹកអណ្តូង
    - ផ្នែកខ្លះត្រូវបានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនី

**ខេត្តក្រចេះ**

១០. ពន្ធជា

- មានទីតាំងក្នុងស្រុកសំបូរ ដែលស្ថិតនៅតាមបណ្តោយទន្លេមេគង្គ (ពិបាកនឹងទៅដល់នៅរដូវវស្សា)
- គណៈកម្មការសហគមន៍មានភាពរឹងមាំ មានសាមគ្គីភាព និងភាពស៊ីសង្វាក់គ្នាខ្លាំងក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច
- អ្នកភូមិទាំងអស់សុទ្ធតែជាសមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច
- ពុំមានការទន្ទ្រានយកដីពីអ្នកខាងក្រៅឡើយ
- ពុំមានទំនាស់ដីធ្លីឡើយ
- ដីមានសក្តានុពលតិចតួច ដូច្នេះមិនសូវមានតម្រូវការ
- ដីដែលស្ថិតនៅក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាព ពុំមានការប្រែប្រួល

- សហគមន៍ជនជាតិដើមភាគតិចចង់បានប័ណ្ណកម្មសិទ្ធិដីសហគមន៍ ដើម្បីការពារដីរបស់ពួកគេ
- ការទទួលបានសេវាហិរញ្ញវត្ថុ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាច់ញាតិ
- ហេដ្ឋារចនាសម្ព័ន្ធសង្គម
  - មានសាលាបឋមសិក្សានៅក្នុងភូមិនេះ និងបើកដំណើរការជាធម្មតា
  - ការផ្គត់ផ្គង់ទឹក៖ អណ្តូងមួយចំនួន ទឹកទន្លេ
  - សេវាសុខភាព៖ ប៉ុស្តិ៍សុខភាពនៅភូមិដែលនៅជិតនោះ (៣ គីឡូម៉ែត្រ) មណ្ឌលសុខភាពនៅអូរគ្រៀង
  - ពុំបានភ្ជាប់ជាមួយនឹងបណ្តាញអគ្គិសនីឡើយ

## ៤.២ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់កម្ចីដល់សហគមន៍ជនជាតិដើមភាគតិច

តំណាងមកពីសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៩ ត្រូវបានសម្ភាសសម្រាប់ការសិក្សានេះ (សូមមើលតារាងទី ៧)។ ប្រធានសាខា អនុប្រធានសាខា ឬមន្ត្រី អតិថិជនភាគច្រើនមានឆន្ទៈក្នុងការចូលរួមឆ្លើយសំណួរដោយចំហ និងក្នុងលក្ខណៈស្ថាបនាខ្ពស់។ មានតែនៅក្នុងករណីមួយចំនួនតូចតែប៉ុណ្ណោះ ដែលមានការបដិសេធមិនព្រមផ្តល់ចម្លើយ ដោយសារមូលហេតុពាក់ព័ន្ធនឹងការរក្សាការសម្ងាត់។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានសម្ភាសទាំងអស់ សុទ្ធតែបានផ្តល់កម្ចីដល់សមាជិករបស់សហគមន៍ជនជាតិដើមភាគតិច។ មន្ត្រីឥណទានចល័តចុះទៅតាមសហគមន៍ជនជាតិដើមភាគតិច ដោយសារមានការប្រកួតប្រជែងខ្ពស់ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗ សមាជិកមួយចំនួនរបស់សហគមន៍ជនជាតិដើមភាគតិចបានលើកឡើងពីអាកប្បកិរិយាច្រឡោងខាងរបស់មន្ត្រីឥណទានចល័ត របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន។ ភូមិទាំង ១០ ដែលត្រូវបានចុះទៅសម្រាប់ការសិក្សានេះ បានរាយការណ៍ថាភ្នាក់ងារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើននាក់បានចុះទៅកាន់ភូមិរបស់ពួកគេជាប្រចាំ ហើយនៅក្នុងករណីមួយ ទីប្រឹក្សាអាចសង្កេតឃើញសកម្មភាពរបស់ភ្នាក់ងារទាំងនេះផ្ទាល់តែម្តងនៅក្នុងភូមិ។

គោលនយោបាយផ្តល់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានសម្ភាស ត្រូវបានបង្ហាញដោយសង្ខេបក្នុងតារាងទី ៧។

តារាងទី ៧ សង្ខេបគោលនយោបាយស្តីពីការផ្តល់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានសម្ភាស

| ឈ្មោះ | ទីតាំង | ប្រភេទកម្ចី | ធ្វើសកម្មភាពក្នុងសហគមន៍ជនជាតិដើមភាគតិច | ទទួលយក ប័ណ្ណកម្មសិទ្ធិដីសមូហភាព | អត្រាការប្រាក់ | មានភ្នាក់ងារចុះទៅដល់ភូមិ |
|---|---|---|---|---|---|---|
| ធនាគារស្ថាបនា | បានលុង រតនគិរី | បុគ្គល | មាន | គ្មាន | ១,៥% អាស្រ័យទៅតាមចំនួន | មាន |
| អេអឹមខេ | បានលុង រតនគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| ហត្ថាកសិករ | បានលុង រតនគិរី | បុគ្គល | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| អម្រឹត | បានលុង រតនគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| អេស៊ីលីដា | បានលុង រតនគិរី | បុគ្គល | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| ប្រាសាក់ | បានលុង រតនគិរី | បុគ្គល | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| ក្រេឌីត | បានលុង រតនគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| វិសិនហ្វាន់ | បានលុង រតនគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| អិលអូអិលស៊ី | បានលុង រតនគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| មហានគរ | សែនមនោរម្យ មណ្ឌលគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| អិលអូអិលស៊ី | សែនមនោរម្យ មណ្ឌលគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| ធនាគារស្ថាបនា | សែនមនោរម្យ មណ្ឌលគិរី | បុគ្គល | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |
| ប្រាសាក់ | សែនមនោរម្យ មណ្ឌលគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុងមួយខែ | មាន |

| | | | | | | |
|---|---|---|---|---|---|---|
| អេអឹមខេ | សែនមនោរម្យ មណ្ឌលគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុង មួយខែ | មាន |
| វីសិនហ្វាន់ | សែនមនោរម្យ មណ្ឌលគិរី | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុង មួយខែ | មាន |
| អេអឹមខេ | ក្រុងក្រចេះ ខេត្តក្រចេះ | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុង មួយខែ | មាន |
| ប្រាសាក់ | ក្រុងក្រចេះ ខេត្តក្រចេះ | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុង មួយខែ | មាន |
| អិលអូអិលស៊ី | ក្រុងក្រចេះ ខេត្តក្រចេះ | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុង មួយខែ | មាន |
| ក្រេឌីត | ក្រុងក្រចេះ ខេត្តក្រចេះ | បុគ្គល + ក្រុម | មាន | គ្មាន | ១,៥% ក្នុង មួយខែ | មាន |

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើន ផ្តល់កម្ចីក្រោមគម្រោងទទួលខុសត្រូវជាក្រុម។ កម្ចីទាំងនេះត្រូវបានផ្តល់ទៅដល់មនុស្សជាក្រុម ដោយក្នុងមួយក្រុមមានគ្នាពី ២-៦ នាក់។ គ្រប់សមាជិកក្រុមទាំងអស់ផ្តល់ការធានាឱ្យគ្នាទៅវិញទៅមក។ សមាជិកក្រុមពុំចាំបាច់ដាក់វត្ថុបញ្ចាំ ដូចជា ប័ណ្ណកម្មសិទ្ធិដីនោះទេ ដែលធ្វើបែបនេះផ្តល់លទ្ធភាពឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចអាចទទួលបានកម្ចីប្រភេទនេះបាន។ មានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនតូចតែប៉ុណ្ណោះដែលតម្រូវឱ្យមានការដាក់វត្ថុបញ្ចាំ (ប័ណ្ណកម្មសិទ្ធិដីធ្លី) យ៉ាងហោចណាស់ពីសមាជិកម្នាក់នៅក្នុងក្រុម។ អត្រាការប្រាក់គឺស្រដៀងគ្នាជាមួយនឹងកម្ចីបុគ្គលដែល ពោលគឺ ១,៥% ក្នុងមួយខែ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដែលត្រូវបានសម្ភាសបានលើកឡើងពីការគិតថ្លៃសេវាបន្ថែម សម្រាប់សេវារដ្ឋបាល ឬការរៀបចំឯកសារ។ ជាគោលការណ៍ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ការឯកភាពលើកម្ចី ដោយប្រើរយៈពេលតិចជាង ៥ ថ្ងៃធ្វើការងារ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ កម្ចីដែលផ្តល់ក្រោមគម្រោងទទួលខុសត្រូវជាក្រុម ដែលពុំមានវត្ថុបញ្ចាំ មានចំនួនតិចជាងកម្ចីបុគ្គលដែលតម្រូវឱ្យមានការដាក់វត្ថុបញ្ចាំ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនបានលើកឡើងថា ទំហំកម្ចីធំបំផុតត្រឹម ២,៤ លានរៀល (៦០០ ដុល្លារ) សម្រាប់រយៈពេលជាមធ្យម ១ ឆ្នាំ ក្រោមគម្រោងទទួលខុសត្រូវជាក្រុមនេះ។ ជារឿយៗ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចាប់ផ្តើមជាមួយនឹងកម្ចីក្នុងចំនួនទាប និងបង្កើនប្រាក់កម្ចីជាបន្តបន្ទាប់ បន្ទាប់ពីអ្នកខ្ចីបានទូទាត់សងរួចមក។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនបញ្ជាក់ថា សមាជិកសហគមន៍ជនជាតិដើមភាគតិចទូទាត់សងទាន់ពេលវេលាក្នុងអត្រាមួយខ្ពស់។ ជាទូទៅគេចាត់ទុកសមាជិកសហគមន៍ជនជាតិដើមភាគតិច ថាជាអតិថិជន ដែល "ល្អ"។ ម្យ៉ាងវិញ

ទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានរាយការណ៍ពីបញ្ហាជាច្រើនជាមួយនឹងអតិថិជន ជាជនជាតិខ្មែរ។ ជាពិសេស ដោយសារតែប្រព័ន្ធទិន្នន័យរបស់ការិយាល័យឥណទានកម្ពុជា (Credit Bureau Cambodia) ពុំមានព័ត៌មានពេញលេញជានិច្ចជាកាលនោះ ពេលខ្លះអតិថិជនជនជាតិខ្មែរបានប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណមិនត្រឹមត្រូវ និងដោយសារតែប្រជាពលរដ្ឋខ្មែរ ដែលរស់នៅតាមតំបន់ជនបទ ច្រើនតែផ្លាស់ប្តូរទីកន្លែងស្នាក់នៅពីមួយកន្លែងទៅមួយកន្លែងកន្លែង ហើយអ្នកខ្ចីកម្ចីមួយចំនួនបានរត់គេចខ្លួនមុនពេលសងកម្ចីមកវិញ។

ដោយសារតែភាពចុះសម្រុងគ្នាបានល្អក្នុងចំណោមសមាជិកសហគមន៍ជនជាតិដើមភាគតិច ការទទួលខុសត្រូវជាក្រុមបែបនេះ ត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាត់ទុកថាជាមធ្យោបាយមួយដ៏ល្អ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែអត្រាសងមកវិញពីអ្នកខ្ចីជាជនជាតិខ្មែរ ក្រោមគម្រោងទទួលខុសត្រូវជាក្រុមនេះមានការថយចុះ បច្ចុប្បន្ននេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនកំពុងធ្វើការវាយតម្លៃជម្រើស ដើម្បីផ្អាកគម្រោងផ្តល់កម្ចីជាក្រុមបែបនេះ។ ការសម្រេចចិត្តបែបនេះនឹងបង្កផលប៉ះពាល់ក្នុងកម្រិតមួយខ្ពស់មកលើលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុរបស់សមាជិកសហគមន៍ជនជាតិដើមភាគតិច។ ក្នុងពេលជាមួយគ្នា ខណៈពេលដែលមានការប្រកួតប្រជែងគ្នាខ្លាំងក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការផ្អាកគម្រោងផ្តល់កម្ចីជាក្រុមទាំងស្រុងទំនងជានឹងមិនកើតឡើងឡើយ។

## ៤.៣ លទ្ធភាពរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានសេវាហិរញ្ញវត្ថុ និងបំណុល

ផ្អែកតាមការពិភាក្សាជាក្រុមក្នុងភូមិ ការពិភាក្សាជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការសម្ភាសតាមខ្នងផ្ទះ សមាជិកសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់ជម្រើសខាងក្រោម ដើម្បីទទួលបានឥណទាន (ទៅតាមលំដាប់លំដោយនៃសារៈសំខាន់)៖

- ធនាគារ / គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ក្រុមសន្សំភូមិ
- សាច់ញាតិ / មិត្តភក្តិ / អ្នកជិតខាង
- ឈ្មួញ
- អ្នកចងការប្រាក់ឯកជន

ស្ថានភាពបំណុលជារួមរបស់គ្រួសារដែលត្រូវបានសម្ភាស ត្រូវបានបង្ហាញដោយសង្ខេបក្នុងតារាងខាងក្រោម៖

តារាងទី ៨ កម្រិតនៃការជាប់បំណុលរបស់គ្រួសារ ដែលត្រូវបានសម្ភាសក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលប្រើប្រាស់ជាសំណាកគំរូ

| សហគមន៍ជនជាតិដើមភាគតិច | ភាគរយនៃគ្រួសារដែលត្រូវបានសម្ភាសដែលកំពុងជាប់បំណុល | ភាគរយនៃគ្រួសារដែលត្រូវបានសម្ភាស ដែលជាប់កម្ចីជាច្រើន | ចំនួនទឹកប្រាក់បំណុលគិតជាមធ្យមក្នុងមួយគ្រួសារគិតជាប្រាក់រៀល *(សមមូលជាដុល្លារ)* | ចំនួនទឹកប្រាក់បំណុលច្រើនបំផុតក្នុងមួយគ្រួសារ គិតជារៀល *(សមមូលជាដុល្លារ)* | អ្នកផ្តល់កម្ចី |
|---|---|---|---|---|---|
| ល្មីនក្រែន | ១០០% | ១០០% | ៣.៦០០.០០០ *(៩០០)* | ៤.៥០០.០០០ *(១.១២៥)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ អ្នកចងការប្រាក់ |
| ឡាអិន | ១០០% | ៤០% | ៣.៨៨០.០០០ *(៩៧០)* | ៦.០០០.០០០ *(១.៥០០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| ល្មីនជង | ១០០% | ៥០% | ២.៥០០.០០០ *(៦២៥)* | ៣.០០០.០០០ *(៧៥០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ |
| អូរណោ | ៥០% | ០% | ២.០០០.០០០ *(៥០០)* | ២.០០០.០០០ *(៥០០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ |
| អូរប្រា | ១០០% | ០% | ២.០០០.០០០ *(៥០០)* | ២.០០០.០០០ *(៥០០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| ស្រែខ្ទុម | ៨០% | ៨០% | ៧.៦២៥.០០០ *(១.៩០៦)* | ១៣.០០០.០០០ *(៣.២៥០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ |
| ស្រែល្វី | ១០០% | ១៤,៣% | ១.៨៥៧.០០០ *(៤៦៤)* | ២.៥០០.០០០ *(៦២៥)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ |
| អណ្តូងក្រឡឹង | ១០០% | ០% | ៣.០០០.០០០ *(៧៥០)* | ៣.០០០.០០០ *(៧៥០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| ពូត្រុំ | ៤៥% | ០% | ៤.៦០០.០០០ *(១,១៥០)* | ១២.០០០.០០០ *(៣.០០០)* | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមសន្សំភូមិ |
| ពន្ទដា | ០% | ០% | - | - | - |

ដោយសារសំណាកគំរូសម្រាប់ការសិក្សានេះមានទំហំតូច គេមានការលំបាកក្នុងការភ្ជាប់ទិន្នន័យដែលប្រមូលបាននេះជាមួយនឹងប្រជាជនទាំងអស់ក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានសម្ភាស។ ទោះជាយ៉ាងណាក៏

ដោយ ការពិភាក្សាក្រុមជាមួយតំណាងមកពីគណៈកម្មការជនជាតិដើមភាគតិច និងតំណាងភូមិបានបញ្ជាក់ពីចំណាប់អារម្មណ៍ជារួម។ នៅក្នុងភូមិភាគច្រើន គ្រួសារដែលជាប់បំណុលមានចន្លោះពី ៧០-៨០%។ ភូមិពន្ធជា គឺជាករណីលើកលែងដ៏ធំមួយ ដោយសារតែមានអ្នកខ្ចីកម្ចីតិចនាក់តែប៉ុណ្ណោះ ខណៈពេលដែលនៅភូមិពូត្រុំវិញ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការព្យាយាមកាត់បន្ថយចំនួនកម្ចីតាមរយៈការចែករំលែកព័ត៌មាន ដោយគណៈកម្មការសហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែឥឡូវនេះកំពុងស្ថិតនៅក្រោមសម្ពាធខ្លាំងពីភ្នាក់ងាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ដូចដែលបានមើលឃើញដោយទីប្រឹក្សាផ្ទាល់)។

ជារួម និងស្រដៀងគ្នាជាមួយតំបន់ដទៃទៀតនៃប្រទេសកម្ពុជាដែរ បញ្ហាបំណុលកំពុងមានការកើនឡើង។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានយុទ្ធសាស្ត្របង្កើនចំនួនទឹកប្រាក់កម្ចី បន្ទាប់ពីអ្នកខ្ចីកម្ចីបានទូទាត់បំណុលដោយជោគជ័យរួចមក។ អ្នកជាប់បំណុលភាគច្រើនគឺជាអតិថិជនលើកដំបូងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៉ុន្តែមានអ្នកខ្ចីកម្ចីមួយចំនួនគឺជាអ្នកខ្ចីលើកទី ២ ឬលើកទី ៣ ដែលបានបង្កើនចំនួនទឹកប្រាក់កម្ចីរបស់ខ្លួន។

ដោយសារតែប្រជាពលរដ្ឋដែលរស់នៅតាមជនបទជាច្រើនគ្រួសារ ក្នុងនោះរាប់បញ្ចូលទាំងសមាជិកសហគមន៍ជនជាតិដើមភាគតិចផង ពុំមានប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ប្រើប្រាស់ជាវត្ថុបញ្ចាំ ដើម្បីទទួលបានកម្ចីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានឆ្លើយតបចំពោះបញ្ហានេះ និងផ្តល់កម្ចីជាក្រុម ដោយប្រើប្រាស់គម្រោងទទួលខុសត្រូវជាក្រុម។ តំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើន ដែលត្រូវបានសម្ភាសដឹងពីនីតិវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព និងការបំរុងប្រយ័ត្នពិសេសចំពោះប័ណ្ណកម្មសិទ្ធិដីបុគ្គល ដែលបង្ហាញដោយសមាជិកសហគមន៍ជនជាតិដើមភាគតិច។ ពុំមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាមួយបានរាយការណ៍ពីការបន្លំប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដើម្បីទទួលបានប្រាក់កម្ចីនោះឡើយ។

ទោះជាយ៉ាងណាក៏ដោយ សមាជិកមួយចំនួនរបស់សហគមន៍ជនជាតិដើមភាគតិចមានប្លង់ទន់សម្រាប់ដីដែលពុំត្រូវបានគ្របដណ្តប់ដោយប័ណ្ណកម្មសិទ្ធិដីជាសមូហភាព។ ទោះជាយ៉ាងណាក៏ដោយ ការចេញប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធពុំទាន់ត្រូវបានធ្វើឡើង នៅក្នុងតំបន់ដែលជាប់នឹងសហគមន៍ជនជាតិដើមភាគតិចទាំង ១០ ដែលត្រូវបានសិក្សាឡើយ។

លិខិតបទដ្ឋានគតិយុត្តិ កំណត់អត្រាការប្រាក់ខ្ពស់បំផុតត្រឹម ១,៥% ក្នុងមួយខែ ដែលធ្វើឱ្យប្រជាពលរដ្ឋ ដែលរស់នៅតាមជនបទកាន់តែមានលទ្ធភាពការខ្ចីកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ លើសពីនេះ មន្ត្រីឥណទានចល័ត ដែលចុះតាមភូមិរបស់សហគមន៍ជនជាតិដើមភាគតិច និងដោយសារតែការផ្តល់កម្ចីលឿនមិនសាំញ៉ាំ (ត្រូវការពេលមិនដល់មួយសប្តាហ៍) បានជួយបើកចំហវិស័យធនាគារផ្លូវការសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទ និងកាត់បន្ថយឥទ្ធិពលរបស់អ្នកចងការប្រាក់ឯកជន។ មានការរាយការណ៍ថា អ្នកចងការប្រាក់ឥឡូវនេះគិតការប្រាក់ត្រឹម ៤-៥% ក្នុងមួយខែតែប៉ុណ្ណោះ សម្រាប់កម្ចីបន្ទាន់រយៈពេលខ្លី។

យ៉ាងហោចណាស់ក៏មានក្រុមសន្សំភូមិមួយដែរ នៅក្នុងសហគមន៍ជនជាតិដើមភាគតិចចំនួន ៨ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចទាំង ១០។ ក្រុមសន្សំប្រាក់ភូមិទាំងអស់ សុទ្ធតែមានសកម្មភាពរស់រវើកក្នុងការផ្ដល់កម្ចីដល់សមាជិករបស់ខ្លួន ហើយនៅក្នុងករណីមួយចំនួន ពួកគេថែមទាំងផ្ដល់កម្ចីដល់អ្នកដែលមិនមែនជាសមាជិកក្រុមដោយគិតអត្រាការប្រាក់ខ្ពស់។ អត្រាការប្រាក់ធម្មតាគឺ ២% សម្រាប់សមាជិក និង ៣% សម្រាប់អ្នកដែលមិនមែនជាសមាជិក។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីភាគច្រើនប្រាក់សន្សំនៅក្នុងក្រុមនេះ គឺពុំគ្រប់គ្រាន់សម្រាប់ឆ្លើយតបចំពោះគ្រប់សំណើសុំខ្ចីកម្ចីទាំងអស់របស់សមាជិកក្រុមឡើយ។

ប្រជាពលរដ្ឋតាមគ្រួសារបានលើកឡើងថា នៅក្នុងករណីបន្ទាន់មានការខ្ចីកម្ចីជាទ្រង់ទ្រាយតូចពីសាច់ញាតិ អ្នកជិតខាង ឬមិត្តភក្ដិ។ ជាធម្មតាកម្ចីរយៈពេលខ្លីបែបនេះ ត្រូវបានផ្ដល់ដោយពុំមានគិតការប្រាក់ឡើយ។ មានតែកម្ចីក្នុងទឹកប្រាក់ច្រើនក្នុងរយៈពេលវែងតែប៉ុណ្ណោះ ដែលគេត្រូវតែបង់ការប្រាក់។ យ៉ាងណាមិញ នៅតាមសហគមន៍ ដែលមានការបែកបាក់សាមគ្គីគ្នា សូម្បីតែសាច់ញាតិក៏ទាមទារឱ្យមានការបង់ការប្រាក់សម្រាប់គ្រប់ប្រភេទកម្ចីទាំងអស់ដោយមិនគិតពីចំនួនទឹកប្រាក់កម្ចីឡើយ។

## ៤.៤ ការទទួលបានសេវាហិរញ្ញវត្ថុសម្រាប់ស្ត្រី

កម្ចីភាគច្រើនត្រូវបានខ្ចីរួមគ្នាដោយប្ដី និងប្រពន្ធ បើទោះបីជានៅក្នុងករណីភាគច្រើនប្ដីជាអ្នកចុះហត្ថលេខាលើឯកសារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ដោយ។ គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ផ្ដល់កម្ចីឱ្យទាំងស្រីទាំងប្រុស។ ពុំមានការរើសអើងលើស្ត្រីណាមួយត្រូវបានសង្កេតឃើញឡើយ។ លើសពីនេះក្នុងចំណោមគ្រួសារដែលត្រូវបានសម្ភាស កម្ចីជាក្រុមមួយចំនួន ក៏ត្រូវបានខ្ចីដោយក្រុមដែលមានសមាជិកសុទ្ធតែជាស្ត្រីផងដែរ។

កម្ចីភាគច្រើនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍដីធ្លី ការទិញឧបករណ៍ គ្រាប់ពូជ ជី និងថ្នាំកសិកម្ម។ លើសពីនេះប្រជាពលរដ្ឋជាច្រើនគ្រួសារក៏ប្រើប្រាស់កម្ចីសម្រាប់សង់ផ្ទះ និងឱ្យកូនបន្តការសិក្សាផងដែរ។

កម្ចីពីក្រុមសន្សំប្រាក់ភូមិ ជារឿយៗ ត្រូវបានប្រើប្រាស់គោលបំណងទូទៅនៅក្នុងគ្រួសារ។ ជារឿយៗ ស្ត្រីចូលរួមយ៉ាងសកម្មក្នុងសកម្មភាពពាណិជ្ជកម្មនានា។ ស្ត្រីច្រើនមានហាងលក់គ្រឿងទេសតូចៗ និងជាអ្នកចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចយ៉ាងសកម្ម។

ជាទូទៅ ពុំមានសញ្ញាដែលបង្ហាញថា ស្ត្រីទទួលរងចាញ់ប្រៀបពាក់ព័ន្ធនឹងការទទួលបានសេវាហិរញ្ញវត្ថុឡើយ។ ស្ត្រីចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាក្រុម ហើយនៅក្នុងការសម្ភាសនានា ពួកគេបានចែករំលែកគំនិតយល់ឃើញ និងបទពិសោធន៍របស់ពួកគេជាចំហ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីជាច្រើននាក់បានលើកឡើងថា កំពុងរងបន្ទុកបំណុលខ្ពស់ ដោយសារការបាត់បង់ប្ដី ឬដោយសារប្ដីញៀនស្រា។

## ៤.៥ ហានិភ័យដែលនាំឱ្យមានបញ្ហាជាប់បំណុល

នៅក្នុងករណីភាគច្រើនសមាជិកសហគមន៍ជនជាតិដើមភាគតិច នៅតែមានការប្រុងប្រយ័ត្នពាក់ព័ន្ធនឹងការខ្ចីកម្ចី។ ពួកគេជាច្រើននាក់នៅតែជាអ្នកខ្ចីកម្ចីលើកដំបូង ហើយពុំមានបទពិសោធន៍ច្រើនជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេកំពុងសង្កេតមើលភូមិខ្មែរ ដែលនៅជិតខាងយ៉ាងយកចិត្តទុកដាក់។ គ្រួសារដែលត្រូវបានសម្ភាសជាច្រើនបានរាយការណ៍ពីករណីគ្រួសារជនជាតិខ្មែរត្រូវបាត់បង់ដី ដោយសារតែបញ្ហាជាប់បំណុលវ័ណ្ឌក។ ដូច្នេះ គ្រួសារដែលត្រូវបានសម្ភាសភាគច្រើន នៅតែចាត់ទុកការដាក់កំហិតដោយប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលគេមិនអាចយកមកប្រើប្រាស់ជាវត្ថុបញ្ចាំបាន ថាជាគុណសម្បត្តិមួយ។ ពួកគេគាំទ្រគំនិតដែលថា បើទោះបីជាបន្ទុកបំណុលមានកម្រិតខ្ពស់យ៉ាងណាក៏ដោយ ពួកគេនឹងមិនបាត់ដី ដោយសារធនាគាររឹបអូសឡើយ។

នេះមានន័យថា ជាទូទៅ ការយល់ដឹងអំពីហានិភ័យពាក់ព័ន្ធនឹងកម្ចី និងពាក់ព័ន្ធនឹងបំណុល គឺមានជាទូទៅ។ ដោយឡែក ភ្នាក់ងាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងធ្វើការព្យាយាម និងដាក់សម្ពាធក្នុងកម្រិតមួយខ្ពស់។ បច្ចុប្បន្ននេះបន្ទុកបំណុលរបស់សមាជិកសហគមន៍ជនជាតិដើមភាគតិចនៅមានកម្រិតទាប បើធៀបនឹងអ្នកភូមិជាជនជាតិខ្មែរ។ ហើយពួកគេភាគច្រើនមានចំណូលថេរពីដំណាំ ដែលពួកគេដាំដុះ ដែលអាចលក់ជាសាច់ប្រាក់បាន (ដូចជា ស្វាយចន្ទី ដំឡូងមី ជាដើម)។ ទោះជាយ៉ាងណាក៏ដោយ ការខូចខាតដំណាំនឹងបង្កើនបន្ទុកបំណុល ក៏ដូចជាហានិភ័យនៃការជាប់បំណុលវ័ន្តករបស់ពួកគេជាមិនខាន។

សម្រាប់សមាជិកមួយ ការខ្ចីបំណុលជាក្រុមជារៀងរាល់ឆ្នាំបានក្លាយជាទម្លាប់ទៅហើយ ជាពិសេសនៅតាមសហគមន៍ដែលពឹងអាស្រ័យស្ទើតែទាំងស្រុងលើការដាំដុះដំណាំ។ នេះគឺជាឥទ្ធិពលនៃទម្លាប់ខ្ចីកម្ចី។ ប្រជាពលរដ្ឋចង់បានប្រាក់យកមកប្រើប្រាស់ភ្លាម ដោយមិនចាំបាច់រងចាំដល់ពេលប្រមូលផល ដែលធ្វើម្តងក្នុងមួយឆ្នាំ។ ស្រដៀងគ្នានឹងភូមិខ្មែរដែរ ការខ្ចីកម្ចីជាច្រើនប្រភពកំពុងបង្កឱ្យមានហាននិភ័យខ្ពស់បំផុត ដែលនាំឱ្យមានបញ្ហាជាប់បំណុលវ័ណ្ឌក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវាយតម្លៃពីស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារនីមួយៗ មុនពេលនឹងផ្តល់កម្ចី និងពិនិត្យលើភាពអាចជឿទុកចិត្តបានរបស់គ្រួសារទាំងនោះ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់ការិយាល័យឥណទានកម្ពុជា (CBC)។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះនៅមិនទាន់មានដំណើរការប្រកបដោយប្រសិទ្ធភាព ១០០% នៅឡើយទេ។

ស្រដៀងគ្នានឹងគ្រួសារខ្មែរដែរ បញ្ហាសុខភាពគឺជាមូលហេតុចម្បងមួយទៀត ដែលនាំឱ្យមានបញ្ហាជាប់ បំណុលវ័ណ្ឌក។ ការធានារ៉ាប់រងសុខភាព ពុំត្រូវបានអនុវត្តជាទូទៅឡើយ។ ឥឡូវនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនកំពុងផ្សព្វផ្សាយពីគម្រោងធានារ៉ាប់រងសុខភាព ភ្ជាប់ជាមួយនឹងការផ្តល់កម្ចីនៅក្នុងភូមិមួយក្នុងចំណោមភូមិដែលត្រូវបានចុះទៅប្រមូលព័ត៌មាន (ភូមិពូត្រុំ) អង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ E.L.I.E (គំនិតផ្តួចផ្តើមលើកស្ទួយជីវភាពរស់នៅ និងបរិស្ថានដំរី) កំពុងរ៉ាប់រងចំណាយលើការថែទាំសុខភាពទាំងអស់របស់គ្រួសារជនជាតិដើមភាគតិច។ ជំនួយនេះជួយកាត់បន្ថយបន្ទុកយ៉ាងច្រើនរបស់គ្រួសារទាំងនេះ។

# ៥. សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋានខាងក្រោមនេះ អាចទាញចេញពីការសម្ភាសនានាជាមួយតំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ដូចជាពីការសម្ភាស ឬការពិភាក្សា និងការសង្កេតផ្ទាល់ក្នុងភូមិទាំង ១០។

## ៥.១ អំពីស្ថានភាពក្នុងសហគមន៍ជនជាតិដើមភាគតិចពាក់ព័ន្ធនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាព ការប្រើប្រាស់ដី និងទំនាស់ដីធ្លី៖

- ភូមិ និងស្ថានភាពជាក់លាក់ក្នុងភូមិមានការប្រែប្រួលខុសៗគ្នាខ្លាំង។ ដូចឃើញក្នុងសេចក្តីសង្ខេបក្នុងជំពូក ៤.១ ភូមិមួយចំនួនបានគ្រប់គ្រងធនធានដីធ្លីរបស់ខ្លួន ដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាពបានយ៉ាងល្អ ពុំជួបប្រទះនឹងបញ្ហាទន្ទ្រានយកដី និងបានបញ្ចៀសមិនឱ្យមានការលក់ដីដែលខុសច្បាប់។ ភូមិដទៃទៀតកំពុងឈានទៅរកការរំលាយសហគមន៍ជនជាតិដើមភាគតិចចោល បានបាត់បង់ប្រមាណ ៧០% នៃធនធានដីធ្លីរបស់ខ្លួន និងកំពុងប្រឈមនឹងបញ្ហាសង្គមសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។

- កត្តាសំខាន់ៗ ដែលកំណត់ "ជោគជ័យ" ឬ "បរាជ័យ" របស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗក្នុងការថែរក្សាអត្តសញ្ញាណរបស់ពួកគេ និងការពារធនធានដីធ្លីរបស់ពួកគេរួមមាន (ទៅតាមលំដាប់លំដោយនៃសារៈសំខាន់)៖
  - ក) ការដឹកនាំរបស់សហគមន៍ និងភាពចុះសម្រុងគ្នាក្នុងសង្គម, តួនាទីនៃប្រពៃណី និងអត្តសញ្ញាណវប្បធម៌ (ឧទាហរណ៍ល្អ៖ ភូមិល្មឺនក្រែន និងអណ្តូងក្រឡឹង, ឧទាហរណ៍មិនល្អ៖ ភូមិអូររណា
  - ខ) ការគាំទ្ររយៈពេលវែងពីអង្គការមិនមែនរដ្ឋាភិបាលណាមួយលើគ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍសហគមន៍ (ឧទាហរណ៍វិជ្ជមាន ភូមិពូត្រុំ)
  - គ) ភាពទាក់ទាញនៃធនធានដីធ្លីរបស់ពួកគេចំពោះការវិនិយោគពីខាងក្រៅ និងការទិញដីពីអ្នកខាងក្រៅ (ដីមានជីជាតិ ជម្រាលភ្នំ ចម្ងាយពីក្រុង ឬផ្សារ។ល។) (ឧទាហរណ៍៖ ភូមិល្មឺនជង)
  - ឃ) ឥទ្ធិពលរបស់សហគមន៍ខ្មែរ ដែលនៅជិតខាង តាមរយៈការសុំទិញដី ការទន្ទ្រានដី ប៉ុន្តែឥទ្ធិពលនេះក៏បង្ហាញឱ្យឃើញពីឧទាហរណ៍នៃការអភិវឌ្ឍយ៉ាងឆាប់រហ័ស ដោយសារតែភាពអាចរកបាននូវកម្ចីជាបុគ្គល ឬកម្ចីជាក្រុម (ឧទាហរណ៍មិនល្អ៖ ភូមិអូររណា)

- ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចទាំង ១០ ដែលត្រូវបានចុះទៅ និងសម្ភាស មានសហគមន៍ចំនួនពីរជឿជាក់យ៉ាងមុតមាំលើអត្ថប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិដីសមូហភាព និងបានការពារបុព្វហេតុរបស់ខ្លួនបានយ៉ាងល្អ (ភូមិល្មឺនក្រែន និងអណ្តូងក្រឡឹង) សហគមន៍ ៣ ផ្សេងទៀត ក៏ជឿជាក់លើអត្ថប្រយោជន៍ដែលបានពីប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះផងដែរ ប៉ុន្តែជួបប្រទះនឹងបញ្ហាប្រឈមផ្ទៃក្នុងមួយ

ចំនួន ពីសំណាក់បុគ្គលខ្លះ ដែលចង់បានប័ណ្ណកម្មសិទ្ធិដីឯកជនជាង ឬមានបំណងចង់ធ្វើការលក់ដី (ភូមិល្មឺនជង ស្រែល្វី និងពន្ធជា) សហគមន៍ ៣ ទៀតកំពុងជួបប្រទះនឹងបញ្ហាប្រឈមសំខាន់ៗ ដោយសារតែការទន្ទ្រានយកដី និង/ឬការលក់ដី (ភូមិឡាអិន អូរប្រា និងពូត្រុំ) ខណៈពេលដែលសហគមន៍ដែលនៅសេសសល់ ២ ទៀត បានលើកឡើងយ៉ាងជាក់ច្បាស់ថា ពួកគេមិនពេញចិត្តជាមួយនឹងប័ណ្ណកម្មសិទ្ធិដីសមូហភាពឡើយ ហើយពួកគេចង់បានប័ណ្ណកម្មសិទ្ធិដីឯកជនវិញ ដើម្បីឱ្យពួកគេអាចមានឱកាសខ្ចីកម្ចីជាលក្ខណៈបុគ្គល និងអាចលក់ដីរបស់ពួកគេនៅពេលដែលចាំបាច់ (ភូមិអូរណោ និងភូមិស្រែខ្ទុម)។

- បើទោះបីជាអ្នកភូមិភាគច្រើននៅផ្តល់ការគាំទ្រ ដល់គំនិតចង់បានប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់ធនធានដីធ្លីជាសមូហភាពរបស់ពួកគេយ៉ាងណាក៏ដោយ ដោយសារតែពួកគេគិតថាប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះអាចផ្តល់ឱ្យពួកគេនូវសិទ្ធិកាន់កាប់ដីធ្លីបានជាប់លាប់ ដៃគូដែលត្រូវបានសម្ភាសភាគច្រើននៅតែផ្តល់ពិន្ទុឱ្យប័ណ្ណកម្មសិទ្ធិដីឯកជនខ្ពស់ជាងប័ណ្ណកម្មសិទ្ធិដីសមូហភាព។ មូលហេតុមួយ អាចដោយសារតែមានការជួបប្រទះនឹងការទន្ទ្រានយកដីជាច្រើនករណីកន្លងមក ប៉ុន្តែក៏អាចដោយសារតែព្រំប្រទល់សម្រាប់ឡូត៍ដីឯកជនត្រូវបានចុះវាស់វែង ដោយមន្ត្រីកំណត់ព្រំប្រទល់ដោយធ្វើការដាក់សញ្ញាសម្គាល់ និងមានការបង្ហាញយ៉ាងច្បាស់នៅលើឯកសារប័ណ្ណកម្មសិទ្ធិ ដោយឡែកដីដែលស្ថិតនៅក្នុងតំបន់នៃប័ណ្ណកម្មសិទ្ធិដីសមូហភាពវិញ ដែលត្រូវបានបែងចែកទៅឱ្យគ្រួសារពុំត្រូវបានកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់នោះឡើយ។ គ្រួសារជនជាតិព្នងមួយចំនួន មានប័ណ្ណកម្មសិទ្ធិដីឯកជន (ភាគច្រើនតាមរយៈយុទ្ធនាការសរាចរណ៍ ០០១) ឬប័ណ្ណកាន់កាប់ ("ប្លង់ទន់") ដែលចេញដោយរដ្ឋបាលឃុំសម្រាប់ដីកាន់កាប់ដោយបុគ្គលនៅខាងក្រៅភូមិរបស់ពួកគេ។ ជាទូទៅគ្រួសារទាំងនេះចាត់ទុកថាខ្លួនឯងមានសំណាង ហើយជារឿយៗតែងតែយកប័ណ្ណកម្មសិទ្ធិដីនេះយកទៅប្រើប្រាស់ ដើម្បីខ្ចីកម្ចីជាលក្ខណៈបុគ្គលក្នុងចំនួនទឹកប្រាក់ច្រើន។

- កន្លងមក មានករណីដាក់សំណើសុំប័ណ្ណកម្មសិទ្ធិដីឯកជន (សម្រាប់កាន់កាប់) ក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្របដណ្តប់របស់ប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅកាន់រដ្ឋបាលឃុំ។ នៅក្នុងករណីមួយចំនួននីតិវិធីខុសច្បាប់បែបនេះត្រូវបានបដិសេធចោលដោយមន្ត្រីឃុំ ប៉ុន្តែនៅក្នុងករណីមួយចំនួនមានការចេញប្លង់ទន់បន្ទាប់ពីមានការផ្តល់ប្រាក់រួច។

- សហគមន៍ជនជាតិដើមភាគតិចចំនួនពីរ (ក្នុងឃុំអូរណោ និងស្រែខ្ទុម) បានដាក់សំណើទៅកាន់រដ្ឋបាលឃុំ ដើម្បីលុបចោលសហគមន៍ជនជាតិដើមភាគតិចរបស់ពួកគេ និងសុំឱ្យមានការបែងចែកដីដែលនៅសេសសល់ដល់សមាជិកបច្ចុប្បន្ននៅក្នុងសហគមន៍។ ដោយសារតែដំណើរការដែលមាន ៣ ជំហាន (សូមមើលជំពូក ៣.១) ការលុបចោលសហគមន៍ជនជាតិដើមភាគតិចពុំអាចធ្វើបានដោយក្រុមប្រឹក្សាឃុំ

ឡើយ។ ឃុំបានជូនដំណឹងទៅដល់អ្នកភូមិថា ពួកគេគួរប្រមូលស្នាមម្រាមដៃអ្នកភូមិទាំងអស់បន្ទាប់មកដាក់សំណើទៅកាន់ក្រសួងមហាផ្ទៃវិញ។

- សហគមន៍ជនជាតិដើមភាគតិចយ៉ាងហោចណាស់ចំនួន ៤ ជួបប្រទះនឹងបញ្ហាទន្ទ្រានយកដី ដែលស្ថិតនៅក្រោមប័ណ្ណកម្មសិទ្ធិដីសហគមន៍។ ពុំមានសហគមន៍ណាមួយបានទទួលការគាំទ្រពីរដ្ឋបាលឃុំ ដែលទទួលខុសត្រូវ ឬរដ្ឋបាលមូលដ្ឋាននៅកម្រិតផ្សេងទៀត ឬពីនគរបាលឡើយ។ ក្នុងករណីចំនួនពីរ អង្គការមិនមែនរដ្ឋាភិបាល (WCS និង CIPO) បានចូលរួមវាស់វែងផ្ទៃដីដែលមានទំនាស់នេះ ហើយនៅក្នុងករណីមួយការិយាល័យមេធាវីមួយបានដាក់បណ្តឹងទៅតុលាការឧទ្ធរណ៍ (ករណីឃុំអូររណា)។ ពុំមានករណីទន្ទ្រានយកដីណាមួយត្រូវបានដោះស្រាយចប់រួចរាល់ឡើយ គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ។
- ដីដែលត្រូវបានបម្រុងទុកសម្រាប់បែងចែក និងប្រើប្រាស់នាពេលអនាគត ដែលជាផ្នែកមួយនៃប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលត្រូវបានចេញកន្លងមក នៅក្នុងករណីភាគច្រើនត្រូវបានបំប្លែងជាដីកសិកម្ម តែប៉ុន្មានឆ្នាំបន្ទាប់ពីបានទទួលប័ណ្ណកម្មសិទ្ធិដីជាសមូហភាព។ នៅក្នុងករណីចំនួន ៣ សហគមន៍ជនជាតិដើមភាគតិចបានបែងចែកដីទៅដល់សមាជិករបស់ខ្លួន។ ក្នុងភូមិចំនួន ៤ ផ្ទៃដីបម្រុងទាំងមូលត្រូវបានទន្ទ្រានយកដោយអ្នកមកពីខាងក្រៅ និងនៅក្នុងករណីមួយចំនួនត្រូវបានទន្ទ្រានយកដោយសមាជិកសហគមន៍ជនជាតិដើមភាគតិចមួយចំនួន។ មានភូមិតែ ២ ប៉ុណ្ណោះ ដែលនៅមានដីបម្រុងទុកខ្លះសម្រាប់បែងចែកនាពេលអនាគត។ ការគ្រប់គ្រងដីបម្រុងទុក គឺជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗនានាសម្រាប់សហគមន៍ជនជាតិដើមភាគតិចក្នុងគណៈកម្មការរបស់សហគមន៍ទាំងនេះ។ នៅក្នុងសហគមន៍ក៏មានលើកឡើងពីករណីប្រើបំពានអំណាចជាច្រើនផងដែរ។

## ៥.២ អំពីការផ្តល់កម្ចី

- ដូចគ្នានឹងកន្លែងផ្សេងទៀតនៅក្នុងតំបន់ជនបទនៅព្រះរាជាណាចក្រកម្ពុជាដែរ អ្នកភូមិជាជនជាតិដើមភាគតិចបានងាកទៅរកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីទទួលបានកម្ចីនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដោយសារតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ទទួលយក ឬជំរុញឱ្យមានការខ្ចីកម្ចីជាក្រុម លទ្ធភាពទទួលបានកម្ចីរបស់ប្រជាពលរដ្ឋ រាប់បញ្ចូលទាំងសមាជិកសហគមន៍ជនជាតិដើមភាគតិចផង មានការកើនឡើងគួរឱ្យកត់សម្គាល់។ អត្រាការប្រាក់ បានថយចុះចាប់តាំងពីឆ្នាំ ២០១៥ មក ហើយអត្រាសងកម្ចីជាក្រុមក៏មានកម្រិតខ្ពស់ផងដែរ ដោយសារតែការរៀបចំឱ្យសមាជិកក្រុមទទួលខុសត្រូវ។ នៅក្នុងសហគមន៍ជនជាតិដើមភាគតិចទាំងអស់ដែលបានចុះទៅ ពុំមានបញ្ហាខកខានក្នុងការសងបំណុលវិញឡើយ កន្លងមក បើទោះបីជាសមាជិកខ្ចីកម្ចីជាក្រុមក្នុងករណីមួយចំនួនតូច ត្រូវខ្ចីប្រាក់ពីសមាជិកសហគមន៍ដូចគ្នា នៅពេលដែលដល់ពេលត្រូវសងកម្ចីវិញយ៉ាងណាក៏ដោយ។

- សេវារបស់អ្នកចងការប្រាក់ដែលគិតអត្រាការប្រាក់ខ្ពស់ត្រូវបានប្រើប្រាស់សម្រាប់បន្ទាន់ពិតប្រាកដតែប៉ុណ្ណោះ។ សារៈសំខាន់របស់អ្នកចងការប្រាក់ត្រូវបានកាត់បន្ថយ។ អ្នកភូមិច្រើនខ្ចីកម្ចីរយៈពេលខ្លីពីសាច់ញាតិ និងអ្នកជិតខាង ដែលពេលខ្លះក៏គិតការប្រាក់ ហើយពេលខ្លះក៏ពុំគិតការប្រាក់ អាស្រ័យទៅលើកម្រិតនៃសាមគ្គីភាពគ្នា និងការចុះសម្រុងគ្នារបស់សហគមន៍។

- សហគមន៍ជនជាតិដើមភាគតិចភាគច្រើនដែលបានចុះទៅ មានក្រុមសន្សំដែលនៅដំណើរការល្អមួយក្រុម ឬច្រើនក្រុម។ ទោះជាយ៉ាងណាក៏ដោយ ក្រុមសន្សំប្រាក់ជាទូទៅទទួលរងផលប៉ះពាល់ដោយសារការគិតអត្រាការប្រាក់ទាប ដែលធ្វើឱ្យពួកគេអាចផ្តល់កម្ចីតិចតួចតែប៉ុណ្ណោះសម្រាប់អ្នកខ្ចីម្នាក់ ហើយជារឿយៗតែងជួបប្រទះនឹងបញ្ហាគ្រប់គ្រងផ្ទៃក្នុង។ នៅក្នុងភូមិជាច្រើនចំនួនសមាជិកដែលនៅសកម្មក្នុងក្រុមសន្សំមានការថយចុះ។ អត្រាការប្រាក់ដែលគិតដោយក្រុមសន្សំ គឺស្រដៀងគ្នា ឬអាចខ្ពស់ជាងអត្រាការប្រាក់ដែលគិតដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតិចតួច។

- បទបញ្ញាថ្មី ដែលរដ្ឋាភិបាលកម្ពុជាចេញសម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានជួយរៀបចំ និងពង្រឹងវិស័យនេះឡើងវិញ។ ការកំណត់អត្រាការប្រាក់ត្រឹម ១,៥% ក្នុងមួយខែ បានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើន។

- គេពុំអាចកំណត់រកឃើញភាពខុសប្លែកគ្នាធំដុំ រវាងអ្នកភូមិជនជាតិខ្មែររស់នៅតាមតំបន់ជនបទ ដែលពុំមានប័ណ្ណកម្មសិទ្ធិដីធ្លី និងអ្នកភូមិសហគមន៍ជនជាតិដើមភាគតិចដែលមានប័ណ្ណកម្មសិទ្ធិដីសហគមន៍ឡើយ ពាក់ព័ន្ធនឹងកម្ចីជាក្រុម។ ដំណើរការរដ្ឋបាល ការរៀបចំក្រុម អត្រាការប្រាក់ រយៈពេលកម្ចី និងចំនួនប្រាក់កម្ចី គឺដូចគ្នា ឬមានលក្ខណៈស្រដៀងគ្នាខ្លាំង។ បុរស និងស្ត្រីមានឱកាសស្មើភាពគ្នាការស្នើសុំកម្ចីជាក្រុម។ អ្វីដែលស្តែងយ៉ាងច្បាស់នោះ គឺចំនួនប្រាក់កម្ចីដោយពុំមានវត្ថុបញ្ចាំ ដែលផ្តល់ផ្អែកតែតាមការទទួលខុសត្រូវរបស់ក្រុម ជានិច្ចជាកាលតែងមានចំនួនតិចជាងកម្ចីដែលមានការដាក់ប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈបុគ្គលជាវត្ថុបញ្ចាំ។ ខណៈពេលដែលកម្ចីជាក្រុមដែលពុំមានវត្ថុបញ្ចាំ ជាទូទៅត្រូវបានកំហិតត្រឹមប្រាក់ច្រើនបំផុត ២,៤ លានរៀល កម្ចីបុគ្គលដោយមានដាក់វត្ថុបញ្ចាំ (ប័ណ្ណកម្មសិទ្ធិដីធ្លី អាចមានរហូតដល់ ៤-៥ លានរៀល អាស្រ័យទៅតាមការវាយតម្លៃលើដីជាធម្មតា ដែលធ្វើឡើងដោយភ្នាក់ងារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅក្នុងករណីមួយចំនួន ការទទួលបានកម្ចីក្នុងចំនួនតិចតួចបែបនេះអាចធ្វើឱ្យមានការអភិវឌ្ឍដីយឺតៗសន្សឹមៗ និងអាចធ្វើឱ្យរាំងស្ទះដល់ការវិនិយោគជាទ្រង់ទ្រាយធំ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សភាគច្រើនចាត់ទុកថានេះគឺជាគុណសម្បត្តិមួយ ដោយសារតែពួកគេនៅតែអាចរក្សាទុកដីរបស់ពួកគេ។ ការខកខានពុំបានសងកម្ចីនឹងមិនធ្វើឱ្យពួកគេប្រឈមនឹងការបាត់បង់កម្មសិទ្ធិដីធ្លីនោះឡើយ។

## ៥.៣ អំពីការជាប់បំណុល

- ទោះជាយ៉ាងណាក៏ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចប្រជែងគ្នាខ្លាំង ដើម្បីដណ្ដើមអតិថិជនថ្មីៗ ហើយភ្នាក់ងារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកំណត់គោលដៅផ្ទាល់ខ្លួន ដូចជាចំនួនប្រាក់កម្ចីក្នុងមួយខែ ដែលពួកគេត្រូវរកឱ្យបាន ដែលធ្វើឱ្យពួកគេត្រូវផ្សព្វផ្សាយសេវាកម្មរបស់ខ្លួនយ៉ាងសកម្ម។ ដៃគូដែលត្រូវបានសម្ភាសជាច្រើន លើកឡើងថា ប្រជាពលរដ្ឋមានការពិបាកក្នុងការទប់ទល់នឹងបច្ចេកទេសរកទីផ្សាររបស់ពួកគាត់ខ្លាំងណាស់នៅក្នុងរយៈពេលវែង។

- បន្ទាប់ពីសមាជិកណាម្នាក់ក្នុងសហគមន៍ជនជាតិដើមភាគតិចបានចាប់ផ្ដើមកម្ចីជាក្រុមដំបូងរបស់ខ្លួន ពេលនោះនឹងមានការចាប់ផ្ដើមញៀនខ្ចីកម្ចីជាប្រចាំ។ ដំបូង ការទូទាត់សងប្រាក់កម្ចីដំបូងៗបានទៀងទាត់ពេលវេលា ផ្ដល់ឱកាសឱ្យក្រុមអាចខ្ចីប្រាក់ក្នុងចំនួនច្រើនជាងមុននៅក្នុងឆ្នាំទី ២ និងឆ្នាំទី ៣។ ដូច្នេះ អ្នកខ្ចីកម្ចីភាគច្រើនបន្តខ្ចីកម្ចីទៀតបន្ទាប់ពីខ្ចីបានលើកដំបូងរួច។

- សហគមន៍ជនជាតិដើមភាគតិចជាច្រើននាក់ដឹងពីហានិភ័យនៃការជាប់បំណុលក្នុងកម្រិតមួយខ្ពស់។ ជាពិសេសគ្រួសារដែលអាចដាំដំណាំសំខាន់ៗសម្រាប់លក់ប្ដូរជាសាច់ប្រាក់ (ភាគច្រើនស្វាយចន្ទី និងដំឡូងមី) ប្រឈមនឹងការតម្រូវឱ្យសងប្រាក់កម្ចីលើសពីសមត្ថភាពរបស់ពួកគេ ដែលនាំឱ្យពួកគេត្រូវខ្ចីកម្ចីជាច្រើនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗគ្នា។ បំណុលបញ្ចូលគ្នា ដែលមានចំនួនខ្ពស់ជាងគេ ដែលត្រូវបានកត់ត្រាបាន ក្នុងអំឡុងពេលសម្ភាសជាមួយនឹងប្រជាពលរដ្ឋតាមគ្រួសារ គឺ ១២ លានរៀល (៣.០០០ ដុល្លារ) បូកនឹងការប្រាក់ ដែលចំនួននេះគឺកៀកគ្នានឹងចំនួនប្រាក់កម្ចីខ្ពស់ៗ ដែលត្រូវបានកត់ត្រាក្នុងភូមិរបស់ជនជាតិខ្មែរ។ ជាមធ្យមចំនួនប្រាក់បំណុលនេះគឺប្រហាក់ប្រហែលនឹងអ្នកភូមិជនជាតិខ្មែររស់នៅតំបន់ជនបទដែលត្រូវបានសម្ភាសនៅតំបន់សម្បទានដីសង្គមកិច្ចដែរ (សូមមើលជំពូក ៣.៣)។

## ៥.៤ អំពីហេដ្ឋារចនាសម្ព័ន្ធសង្គម

- ពាក់ព័ន្ធនឹងការផ្ដល់ការអប់រំកម្រិតបឋមសិក្សា ការផ្គត់ផ្គង់ទឹកស្អាត និងសេវាសុខភាពវិញ ពុំមានការរកឃើញភាពខុសប្លែកគ្នាធំដុំនោះឡើយ នៅពេលធ្វើការប្រៀបធៀបសហគមន៍ជនជាតិដើមភាគតិចទាំង ១០ ដែលបានចុះទៅសម្រាប់ការសិក្សានេះ ជាមួយនឹងភូមិជិតខាតដែលមានទំហំប្រហាក់ប្រហែលគ្នា។

- ចំណុចដែលគួរឱ្យកត់សម្គាល់គឺអ្នកភូមិជាច្រើននាក់ ដែលត្រូវបានសម្ភាសបានលើកឡើងថា មួយផ្នែកនៃប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ សម្រាប់ការបន្តការអប់រំរបស់កូនៗពួកគេ ដូចជា ការបង់ថ្លៃសាលា ការស្នាក់នៅ ឬការធ្វើដំណើរទៅទីប្រជុំជនដែលនៅជិតនឹងសហគមន៍របស់ពួកគេជាដើម។

# ៦. អនុសាសន៍

## ៦.១ អនុសាសន៍ដល់រដ្ឋាភិបាលនៅថ្នាក់ជាតិ និងរដ្ឋបាលមូលដ្ឋាន

- ពិនិត្យឡើងវិញលើច្បាប់ភូមិបាលឆ្នាំ ២០០១ និងលិខិតបទដ្ឋាន ព្រមទាំងនីតិវិធីបច្ចុប្បន្នសម្រាប់ចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ចាំបាច់ត្រូវមានការបង្កើនភាពបត់បែន និងកាត់បន្ថយដំណើរការដែលស្មុគស្មាញ និងស៊ីពេលយូរ ជាបន្ទាន់។

- អនុវត្តគោលការណ៍នៃការទទួលបានពត៌មានពេញលេញនិងឯកភាពនិងដោយសេរីជាមុន (FPIC) ក្នុងដំណើរការនៃការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព និងផ្តល់ឱ្យសហគមន៍ជនជាតិដើមភាគតិចនីមួយៗនូវជម្រើសជាមូលដ្ឋានចំនួន ៣ ដើម្បីឱ្យពួកគេជ្រើសរើសយកជាជម្រើសណាមួយ។ ចាំបាច់ត្រូវតែមានការពន្យល់ឱ្យបានច្បាស់លាស់ពីលក្ខខណ្ឌ និងការហាមឃាត់នានា ក៏ដូចជាគុណសម្បត្តិ និងគុណវិប្បត្តិនៃជម្រើសនីមួយៗក្នុងចំណោមជម្រើសទាំង ៣។[16]

- បន្តគ្រប់គ្រងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យបានតឹងរឹងពាក់ព័ន្ធនឹងការរៀបចំ និងនីតិវិធីផ្តល់កម្ចីរបស់ស្ថាប័នទាំងនេះ។

- ផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដែលប្រឈមនឹងការទន្ទ្រានយកដីពីអ្នកខាងក្រៅ។ ឆ្លើយតបចំពោះករណីនៅតុលាការឱ្យបានទាន់ពេលវេលា ជួយដល់ការអនុវត្តសាលក្រម ប្រសិនបើពុំមានការចាត់វិធានការជាបន្ទាន់លើករណីទន្ទ្រានយកដីពីអ្នកខាងក្រៅក្នុងតំបន់ ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះទេ ប័ណ្ណកម្មសិទ្ធិដីនឹងបាត់បង់តម្លៃ ក៏ដូចជាភាពពាក់ព័ន្ធរបស់វាចំពោះសមាជិកសហគមន៍

[16] ក) ធនធានដីធ្លីទាំងអស់របស់សហគមន៍ត្រូវបានបញ្ចូលទៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាពតែមួយ។ នេះគឺជាអ្វីដែលកំពុងធ្វើនាពេលបច្ចុប្បន្ននេះ។ ប័ណ្ណកម្មសិទ្ធិដីមូហភាពមិនអនុញ្ញាតឱ្យមានការលក់ដីទៅឱ្យអ្នកខាងក្រៅ និងអាចយកមកប្រើប្រាស់ជាវត្ថុបញ្ចាំបានឡើយ។ ជម្រើយនេះប្រហែលជាមានភាពទាក់ទាញភាគចំពោះសហគមន៍ជនជាតិដើមភាគតិច ដែលមានភាពរឹងមាំ ដែលបានដាក់ចេញនូវវិធានគ្រប់គ្រងយ៉ាងជាក់ច្បាស់រួចទៅហើយ។ សហគមន៍ដែលមានការដឹកនាំរឹងមាំ និងដែលចាត់ទុកថានេះគឺជាជម្រើសដែលល្អបំផុត ដើម្បីការពារដីធ្លី និងទំនៀមទម្លាប់របស់ពួកគេ។

ខ) មានតែប្រភេទដីដែលអាចប្រើប្រាស់តែសមូហភាពតែប៉ុណ្ណោះ ដូចជាដីកប់សព ដីអារក្ស និងអាចដីបម្រុងត្រូវបានចាត់ចំណាត់ថ្នាក់ថាជា "ដីសមូហភាព" និងដាក់បញ្ចូលទៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាព។ រាល់ក្បាលដីដទៃទៀត ដូចជាដីកសិកម្ម វាលស្រែ និងតំបន់លំនៅដ្ឋាន ទទួលបានប័ណ្ណកម្មសិទ្ធិជាដីបុគ្គល ដូច្នេះដីទាំងនេះអាចប្រើប្រាស់ជាវត្ថុបញ្ចាំ ឬអាចលក់ដូរដោយស្របច្បាប់បាន។

គ) រាល់ដីទាំងអស់ដែលអាចទទួលបានប័ណ្ណកម្មសិទ្ធិដីបុគ្គលទទួលបានប័ណ្ណកម្មសិទ្ធិបែបនេះ ពោលគឺដូចគ្នានឹងប័ណ្ណកម្មសិទ្ធិដីដែលចេញដោយប្រើប្រាស់វិធីសាស្ត្រចេញប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធ ដែលអនុវត្តនៅតាមភូមិរបស់ជនជាតិខ្មែរ។ អ្វីដែលស្តែងចេញយ៉ាងច្បាស់ គឺប័ណ្ណកម្មសិទ្ធិបែបនេះអាចនាំឱ្យមានហានិភ័យ ពោលគឺអាចមានការបាត់បង់ដីទៅឱ្យធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងករណីដែលមានការខកខានពុំបានសងកម្ចី ឬនៅពេលដែលមានការលក់ដីទៅឱ្យអ្នកខាងក្រៅ។

ជនជាតិដើមភាគតិចជាមិនខាន។ ការដឹងពីសិទ្ធិកាន់កាប់ដីធ្លីបានទទួលរងផលប៉ះពាល់យ៉ាងធំធេងរួចទៅហើយ ដោយសារតែករណីដែលពុំត្រូវបានដោះស្រាយទាំងនេះ។

### ៦.២ អនុសាសន៍ចំពោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

- បន្តផ្តល់កម្ចីជាក្រុមដល់សមាជិកសហគមន៍ជនជាតិដើមភាគតិច។ កំណត់ឱ្យបានតឹងរឹងនូវចំនួនប្រាក់កម្ចីអតិបរមាត្រឹម ២,៥ លានរៀល ក្នុងសមាជិក្រុមម្នាក់[17]។
- កែលម្អប្រព័ន្ធផ្លោះប្តូរទិន្នន័យរបស់ការិយាល័យឥណទានកម្ពុជា (CBC) ដើម្បីលប់បំបាត់ការផ្តល់កម្ចីច្រើនជងដល់បុគ្គលដដែល ដែលធ្វើជាសមាជិកនៅក្នុងក្រុមកម្ចីផ្សេងៗគ្នា។

### ៦.៣ អនុសាសន៍ចំពោះការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា

- ជួយដល់គណៈកម្មការរៀបចំព្រាងវិសោធនកម្មច្បាប់ភូមិបាល និងជាពិសេសលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច។ លទ្ធផលរកឃើញនៃការសិក្សានេះ អាចមានប្រយោជន៍ខ្លះសម្រាប់ដំណើរការនេះ។
- គាំទ្រដល់យុទ្ធនាការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សហគមន៍ជនជាតិដើមភាគតិច ដែលមាន និងដែលពុំមានប័ណ្ណកម្មសិទ្ធិដីជាសមូហភាព។ សមាជិកជនជាតិដើមភាគតិចចាំបាច់ត្រូវរៀនពីរបៀបប៉ាន់ប្រមាណចំណូលដែលពួកគេមានសម្រាប់ប្រើប្រាស់ និងប៉ាន់ប្រមាណពីសមត្ថភាពខ្ចីកម្ចីរបស់ពួកគេ។ ពួកគេតែមានការយល់ដឹងបន្ថែមទៀតអំពីហានិភ័យនៃការធ្លាក់ចូលទៅក្នុងអន្ទាក់បំណុល។
- ជំរុញឱ្យមានការគាំទ្រដល់ការរក្សាវិធីសាស្ត្រផ្តល់កម្ចីជាក្រុម។ ប្រសិនបើការរៀបចំផ្តល់កម្ចី ដោយឱ្យក្រុមជាអ្នកទទួលខុសត្រូវរួមគ្នាបែបនេះ លែងត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តផ្តល់ឱ្យទៀត សហគមន៍ជនជាតិដើមភាគតិចទាំងអស់ នឹងត្រូវប្រឈមការលំបាកយ៉ាងធំធេងក្នុងការទទួលបានឥណទានសម្រាប់អភិវឌ្ឍសហគមន៍របស់ពួកគេ។

---

[17] គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាក់កំហិតប្រាក់កម្ចីត្រឹម ២,៥ លានរៀល ដោយគិតថា ពួកគេពុំមានសមត្ថភាពវាយតម្លៃសមាជិកក្រុមនីមួយៗឱ្យបានល្អិតល្អន់គ្រប់គ្រាន់ ក៏ដូចជាប្រាក់ចំណូល និងសមត្ថភាពសងបំណុលមកវិញរបស់ពួកគេឡើយ។ លើសពីនេះវាក៏ជាមធ្យោបាយដើម្បីគ្រប់គ្រងហានិភ័យសម្រាប់សមាជិកក្រុមដទៃទៀត ដែលប្រើប្រាស់ការទទួលខុសត្រូវជាក្រុមផងដែរ។

### ៦.៤ អនុសាសន៍ចំពោះអង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រដល់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព និងការអភិវឌ្ឍសហគមន៍

- រៀបចំយុទ្ធនាការបង្កើនការយល់ដឹងផ្នែកហិរញ្ញវត្ថុ ជាផ្នែកមួយនៃសកម្មភាពអភិវឌ្ឍន៍សហគមន៍ ដែលធ្វើឡើងនៅតាមសហគមន៍ជនជាតិដើមភាគតិច។ ជាពិសេសបណ្តុះបណ្តាលសមាជិកគណៈកម្មការសហគមន៍ជនជាតិដើមភាគតិច និងមេភូមិអំពីកម្ចីជាក្រុម។ ហានិភ័យ និងគុណសម្បត្តិនៃកម្ចីបែបនេះ និងទិដ្ឋភាពរួមទូទៅនៃការគ្រប់គ្រងបំណុល។

- ផ្តល់គ្រប់ការគាំទ្រ ដែលចាំបាច់ទាំងអស់នៅក្នុងករណីដែលមានការទន្ទ្រានយកដីនៅក្នុងតំបន់ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងដាក់ពាក្យបណ្តឹងទៅកាន់តុលាការជំនួសឱ្យសហគមន៍ទាំងនេះ។

- បន្តជំរុញឱ្យមានការអនុវត្តដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ប៉ុន្តែត្រូវផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ដល់សហគមន៍ជនជាតិដើមភាគតិចអំពីគុណសម្បត្តិដែលអាចមាន ក៏ដូចជាគុណវិបត្តិ ធៀបនឹងប័ណ្ណកម្មសិទ្ធិដីឯកជន។ កុំលើកទឹកចិត្ត ឬបង្ខំឱ្យសហគមន៍ជនជាតិដើមភាគតិចដែលមានការស្ទាក់ស្ទើរមិនចង់ទទួលយកគំនិតប័ណ្ណកម្មសិទ្ធិដីសមូហភាពទាំងស្រុង ឱ្យដើរតាមទិសដៅនេះ។ មានតែសហគមន៍ដែលមានការដឹកនាំរឹងមាំមានការចុះសម្រុងក្នុងសង្គមបានល្អ និងសាមគ្គីភាពក៏ដូចជាអាចអនុវត្តវិធានគ្រប់គ្រងបានយ៉ាងតឹងរឹងតែប៉ុណ្ណោះ ដែលអាចការពារដីសមូហភាពរបស់ពួកគេនៅក្នុងរយៈពេលវែងបាន។

### ៦.៥ អនុសាសន៍ចំពោះសហគមន៍ជនជាតិដើមភាគតិចទាំង ១០ ដែលត្រូវបានចុះទៅ

- គួរមានការផ្តល់សិទ្ធិអំណាចឱ្យសហគមន៍ជនជាតិដើមភាគតិចនីមួយៗ រិះរកវិធីដោយខ្លួនឯង ដើម្បីដោះស្រាយបញ្ហាដីធ្លីរបស់ពួកគេ។ ប្រសិនបើសហគមន៍ជាច្រើននៅបន្តពឹងអាស្រ័យលើការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយទំនាស់ដីធ្លី ដូចជាការវាស់វែងតំបន់ដែលត្រូវបានទន្ទ្រាន និងការដាក់ពាក្យបណ្តឹងទៅតុលាការជាដើម ការគាំទ្របែបនេះគួរផ្តល់អមមកជាមួយនឹងការកសាងសមត្ថភាពសហគមន៍ជនជាតិដើមភាគតិច ដើម្បីឱ្យសហគមន៍ទាំងនេះអាចការពារផលប្រយោជន៍ និងសិទ្ធិរបស់ខ្លួនដោយខ្លួនឯងបាន។

- គណៈកម្មការសហគមន៍ជនជាតិដើមភាគតិច និងអាជ្ញាធរភូមិគួរបន្តអប់រំផ្សព្វផ្សាយព័ត៌មានអំពីហានិភ័យនៃការខ្ចីកម្ចីជាក្រុមក្នុងចំនួនច្រើនពេកដល់គ្រប់សមាជិកទាំងអស់។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ កម្រងសំណួរសម្រាប់ការសម្ភាសតាមខ្នងផ្ទះ

| |
|---|
| **កម្រងសំណួរសម្រាប់ការសម្ភាសតាមខ្នងផ្ទះ**<br>១. ឈ្មោះអ្នកដែលត្រូវបានសម្ភាស |
| ២. ភេទ |
| ៣. ខេត្ត / ស្រុក/ ឃុំ |
| ៤. ភូមិ |
| ៥. សមាជិករបស់សហគមន៍ជនជាតិដើមភាគតិច — បាទ-ចាស [ ] ទេ [ ] |
| ៦. គ្រួសារមានស្ត្រីជាមេគ្រួសារ [ ] បាទ-ចាស/ ទេ |
| ៧. ចំនួនសមាជិកគ្រួសារ [ ] មនុស្សពេញវ័យ (ចាប់ពី១៨ ឆ្នាំឡើងទៅ) ចំនួនប្រុស/ស្រី<br>[ ] កុមារ (ក្រោម ១៨ឆ្នាំ) ចំនួនកុមារា/កុមារី |

| |
|---|
| **ក. ស្ថានភាពទូទៅ** |
| ១. តើស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកមានការប្រែប្រួលដែរឬទេ ចាប់តាំងពីពេលមានការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពរួចមក? ប្រសិនបើមាន តើមានការផ្លាស់ប្តូរជាក់លាក់អ្វីខ្លះ? តើការផ្លាស់ប្តូរនេះមានទំនាក់ទំនងជាមួយនឹងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ឬកត្តាដទៃទៀត? |

២. តើអ្នកមានអារម្មណ៍សុវត្ថិភាពលើដីរបស់អ្នកដែរឬទេ (ដីស្រែចម្ការ ដីលំនៅដ្ឋាន... )? ប្រសិនបើពុំមានសុវត្ថិភាព ហេតុអ្វី? និងប្រសិនបើមាន ហេតុអ្វី?

៣. តើអ្នក ឬសមាជិកសហគមន៍ដទៃទៀតទទួលរងការទន្ទ្រានដីរបស់អ្នក/ដីរបស់ពួកគេដែរឬទេ? ប្រសិនបើមាន ចាប់តាំងពីពេលណា និងដោយអ្នកណា? នៅតំបន់ណា? តើដីនេះមានប័ណ្ណកម្មសិទ្ធិដែរឬទេ? តើមានការធ្វើសកម្មភាពអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះស្ថានភាពនេះ? ដោយអ្នកណា?

## ខ. ស្ថានភាពសេដ្ឋកិច្ច

១. តើអ្នកមានប័ណ្ណសម្គាល់គ្រួសារក្រីក្រដែរឬទេ? ប្រសើនបើមាន មានចាប់តាំងពីពេលណា? មុន ឬក្រោយពេលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព?

២. តើអ្នកមានប្រភពចំណូលអ្វីខ្លះ? តើអ្នកអាចប៉ាន់ប្រមាណពីភាគរយធៀបនឹងចំណូលសរុបដែរឬទេ?

បច្ចុប្បន្ននេះ

| ប្រភពចំណូល | ចំនួន/ភាគរយ |
|---|---|
| ការដាំដំណាំ | |
| ការចិញ្ចឹមសត្វ | |
| ស៊ីឈ្នួល / ការងារប្រចាំថ្ងៃ | |
| នេសាទ | |
| ប្រាក់ផ្ញើមកឱ្យ | |
| ការទ្រទ្រង់ជីវភាពគ្រួសារ | |

| ដទៃទៀត | |
|---|---|

មុនពេលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព

| ប្រភពចំណូល | ចំនួន/ភាគរយ |
|---|---|
| ការដាំដំណាំ | |
| ការចិញ្ចឹមសត្វ | |
| ស៊ីឈ្នួល / ការងារប្រចាំថ្ងៃ | |
| នេសាទ | |
| ប្រាក់ផ្ញើមកឱ្យ | |
| ការទ្រទ្រង់ជីវភាពគ្រួសារ | |
| ដទៃទៀត | |

២. ប្រសិនបើអ្នកប្រៀបធៀបចំណូលរបស់អ្នកនៅថ្ងៃនេះ ជាមួយនឹងចំណូលរបស់អ្នកមុនពេលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព តើមានការប្រែប្រួលអ្វីខ្លះ? តើអ្នកអាចធ្វើការប៉ាន់ប្រមាណពីការប្រែប្រួលនេះបានដែរឬទេ?

៤. តើបច្ចុប្បន្ននេះអ្នកសន្សំប្រាក់បានតិច ឬច្រើនជាងមុន ឬដូចមុនក្នុងមួយឆ្នាំ បើធៀបនឹងមុនពេលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព? ហេតុអ្វី? តើអ្នកអាចទាយពីភាគរយបានដែរឬទេ?

៥. តើគ្រួសាររបស់អ្នកផលិតកសិផលក្នុងបរិមាណគ្រប់គ្រាន់ ទុកសម្រាប់ខ្លួនឯងដែរឬទេ?

បាទ-ចាស ទេ

៧. តើគ្រួសាររបស់អ្នកជាប់បំណុលដៃរឬទេ ?

ប៉ុន្មាន ?

បាទ-ចាស ទេ

៨. តើគ្រួសាររបស់អ្នកធ្លាប់ជំពាក់ប្រាក់បំណុលដៃរឬទេ មុនពេលមានការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព ?

ចំនួនប៉ុន្មាន ?

ប្រសិនបើមាន តើជំពាក់អ្នកណា/តើអ្នកខ្ចីលុយពីអ្នកណា?

**បច្ចុប្បន្ននេះ**

| ឈ្មោះអ្នកផ្តល់កម្ចី/ឈ្មោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[18] | ចំនួនដំបូង[19] | តើអ្នកខ្ចីលុយនោះនៅពេលណា? | ចំនួនដែលនៅសល់ | អត្រាការប្រាក់ | កាលបរិច្ឆេទសងត្រឡប់វិញ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

**មុនពេលមានការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព**

[18] អ្នកចងការប្រាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ មិត្តភក្តិ/គ្រួសារ/អ្នកជិតខាង ធនាគារស្រូវសហគមន៍ ក្រុមសន្សំប្រាក់សហគមន៍ សហករណ៍កសិកម្ម
[19] រាប់បញ្ចូលប្រាក់ផង និងទ្រព្យសម្បត្តិនានាផង (ស្រូវ កម្លាំងពលកម្ម ។ល។)

| ឈ្មោះអ្នកផ្តល់កម្ចី/ឈ្មោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[20] | ចំនួនដំបូង[21] | តើអ្នកខ្ចីលុយនោះនៅពេលណា ? | ចំនួនដែលនៅសល់ | អត្រាការប្រាក់ | កាលបរិច្ឆេទសងត្រឡប់វិញ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

[20] អ្នកចងការប្រាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ មិត្តភក្តិ/គ្រួសារ/អ្នកជិតខាង ធនាគារស្រូវសហគមន៍ ក្រុមសន្សំប្រាក់សហគមន៍ សហករណ៍កសិកម្ម

[21] រាប់បញ្ចូលប្រាក់ផង និងទ្រព្យសម្បត្តិនានាផង (ស្រូវ កម្លាំងពលកម្ម ។ល។)

៩. សូមរៀបរាប់ពីដំណើរការ ដើម្បីទទួលបានកម្ចីម្តងមួយៗ? តើមានអ្នកម្នាក់មកជួបអ្នក (ឧទាហរណ៍ អ្នកចងការប្រាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារ) ឬអ្នកត្រូវទៅជួបពួកគេ? តើអ្នកដឹងពីការអាចខ្ចីកម្ចីបានតាមរបៀបណា? តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានប្រាក់កម្ចី? អ្នកណាជាអ្នកចុះហត្ថលេខា? តើវាត្រូវការពេលយូរប៉ុណ្ណា? តើអ្នកពេញចិត្តជាមួយនឹងដំណើរការនេះដែរឬទេ?

១០. តើអ្នកប្រើអ្វីជាវត្ថុបញ្ចាំ?

១១. តើបច្ចុប្បន្ននេះ អ្នកបង់ការប្រាក់ខ្ពស់ជាងមុន ឬទាបជាងមុន ឬដូចមុន ធៀបនឹងមុនពេលមានប័ណ្ណកម្មសិទ្ធិសមូហភាព?

១២. តើអ្នកមានលទ្ធភាពបង់អត្រាការប្រាក់ដែរឬទេ? (តើអ្នកកំពុងជួប ឬតើអ្នកបានជួបការលំបាកក្នុងការសងបំណុលដែរឬទេ កន្លងមក ក្នុងករណីដែលអ្នកមិនអាចសងបំណុលបានទាំងស្រុង តើនឹងមានអ្វីកើតមានឡើង?)

១៣. ប្រសិនបើអ្នកប្រៀបធៀបស្ថានភាពរបស់អ្នកជាមួយនឹងអ្នកជិតខាងជាជនជាតិខ្មែរ តើអ្នកគិតថា អ្នកមានឱកាសដូចគ្នាក្នុងការទទួលបានសេវាហិរញ្ញវត្ថុ ឬឱកាសល្អប្រសើរជាង ឬតើអ្នកមានការលំបាកជាងពួកគេដែរឬទេ ក្នុងនាមអ្នកភូមិជនជាតិដើមភាគតិច? ហេតុអ្វី?

១៤. តើអ្នកយកប្រាក់កម្ចីមកធ្វើអ្វីខ្លះ?

គ. ការឆ្លុះបញ្ចាំង

១. តើអ្វីទៅជាការផ្លាស់ប្តូរធំជាងគេសម្រាប់គ្រួសាររបស់អ្នក បន្ទាប់ពីមានការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព?

២. បើប្រៀបធៀបជាមួយនឹងមុនពេលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព តើស្ថានភាពរបស់អ្នកបានល្អប្រសើរ ឬអន់ថយជាងមុន ?

| អន់ថយច្រើនជាងមុន | អនថយតិចតួចជាងមុន | ដូចគ្នា | ល្អប្រសើរតិចតួចជាងមុន | ល្អប្រសើរឆ្ងាយជាងមុន |
|---|---|---|---|---|
| | | | | |

ហេតុអ្វី ?

៣. តើអ្នកនៅចង់បានប័ណ្ណកម្មសិទ្ធិសមូហភាពទៀត ឬអ្នកចង់បានប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈបុគ្គលវិញ ?

ហេតុអ្វី ?

៥. តើអ្នកមានសំណូមពរ/គំនិតអ្វីខ្លះ អំពីការអភិវឌ្ឍសហគមន៍ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់អ្នកនាពេលអនាគត ?

១៥. តើអ្នក ឬគ្រួសារ/សហគមន៍របស់អ្នកទទួលបានជំនួយពីខាងក្រៅ ឧទាហរណ៍ពីអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋានដែរឬទេ ? ប្រសិនបើបាន តើជាជំនួយប្រភេទអ្វី ?

# ឧបសម្ព័ន្ធទី ២ គោលការណ៍ណែនាំស្តីពីការសម្ភាសក្នុងកិច្ចប្រជុំភូមិ/ការពិភាក្សាក្រុមគោលដៅ

| គោលការណ៍ណែនាំស្តីពីការសម្ភាសក្នុងកិច្ចប្រជុំភូមិ/ការពិភាក្សាក្រុមគោលដៅ |
|---|
| ព័ត៌មានជាមូលដ្ឋាន<br>១. ខេត្ត/ស្រុក |
| ២. ឃុំ |
| ៣. ភូមិ |
| ៤. កាលបរិច្ឆេទ |
| ៥. ចំនួនអ្នកចូលរួម (សូមមើលបញ្ជីឈ្មោះអ្នកចូលរួមដែលភ្ជាប់មកជាមួយ)<br>ចំនួនប្រុស/ស្រី |

| ក. រចនាសម្ព័ន្ធសហគមន៍ជនជាតិដើមភាគតិច |
|---|
| ១. ចំនួនសមាជិកសហគមន៍ជនជាតិដើមភាគតិច (គ្រួសារ និងមនុស្ស)<br>២. ចំនួនគ្រួសារ និងមនុស្សសរុប<br>៣. កាលបរិច្ឆេទនៃការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព |

៤. ក្រឡាផ្ទៃដីដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាព

៥. ការប្រើប្រាស់ដី ដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាប (បច្ចុប្បន្ននេះធៀបនឹងអតីតកាល)

៦. ការផ្ទេរដី

ខ. សន្តិសុខក្នុងការកាន់កាប់ដីធ្លី និងទំនាស់

១. ស្ថានភាពទូទៅ

២. ទំនាស់ដីធ្លី/ការទន្ទ្រានយកដីធ្លី (ប្រសិនបើមាន៖ តើនៅកន្លែងណាក្នុងសហគមន៍របស់អ្នក? តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីដោះស្រាយទំនាស់ការទន្ទ្រានយកដីនេះ/ទាំងនេះ? តើអ្នកទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិលដែរឬទេ? បើសិនបើបាន អង្គការមួយណា?)

៣. ការដោះស្រាយទំនាស់

៤. តួនាទីរបស់អ្នកពាក់ព័ន្ធក្នុងទំនាស់ និងការដោះស្រាយទំនាស់

៥. ការប្រៀបធៀបស្ថានភាពមុន និងក្រោយពេលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព

គ. ស្ថានភាពសេដ្ឋកិច្ច

១.ការមានធនធានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍ដីធ្លី?

២. លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុនៅកម្រិតគ្រួសារ

៣. ប្រភពសេវាហិរញ្ញវត្ថុ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារ អ្នកចងការប្រាក់ ប្រព័ន្ធសន្សំក្នុងសហគមន៍ ការលក់ដី។ល។)

ឃ. ស្ថានភាពទូទៅក្នុងការឈានទៅទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព

១. ការពេញចិត្តរបស់សហគមន៍ជនជាតិដើមភាគតិចជាមួយប័ណ្ណកម្មសិទ្ធិដីសមូហភាព

២. គុណសម្បត្តិ/គុណវិបត្តិនៃប័ណ្ណកម្មសិទ្ធិដីសមូហភាព

៣. ប្រៀបធៀបជាមួយនឹងពេលមុនទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព តើស្ថានភាពដីធ្លីមានភាពល្អប្រសើរជាងមុន ឬអនថយជាងមុន?

| អន់ថយច្រើនជាងមុន | អនថយតិចតួចជាងមុន | ដូចគ្នា | ល្អប្រសើរតិចតួចជាងមុន | ល្អប្រសើរឆ្ងាយជាងមុន |
|---|---|---|---|---|
| | | | | |

4. តើសហគមន៍បានទទួលសេវាសង្គមដទៃទៀត ដូចជាសេវាអប់រំ សេវាថែទាំសុខភាព។ល។ ដែរឬទេ? តើមានកន្លែងផ្តល់សេវាសង្គមអ្វីខ្លះនៅក្នុងតំបន់នេះ? តើសេវាទាំងនោះដំណើរការទៅបានល្អដែរឬទេ?

៥. តើគេគួរអាចធ្វើអ្វីផ្សេងខុសពីនេះ? តើសហគមន៍ចង់កែលម្អអ្វីជាងគេ?

# ឧបសម្ព័ន្ធទី ៣ ការណែនាំសម្រាប់សម្ភាសក្នុងពេលជួបប្រជុំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ

| |
|---|
| ការណែនាំសម្រាប់សម្ភាសពេលប្រជុំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ/អ្នកផ្តល់កម្ចី<br><br>១. ខេត្ត/ស្រុក |
| ២. ឈ្មោះគ្រឹះស្ថាន (ការិយាល័យកណ្តាល ឬសាខាតំបន់) |
| ៣. ឈ្មោះដៃគូសម្ភាស និងមុខតំណែង (ប្រសិនបើបុគ្គលនេះយល់ព្រមឱ្យដាក់ព័ត៌មាននេះ) |
| ៤. កាលបរិច្ឆេទ |

ក. ស្ថានភាពបច្ចុប្បន្ន

១. នីតិវិធីផ្តល់កម្ចីដល់សហគមន៍ជនជាតិដើមភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព (ទ្រឹស្តី និងការអនុវត្តជាក់ស្តែង) (កម្ចីបុគ្គល និងកម្ចីក្រុម)។ តើមានគោលនយោបាយជាផ្លូវការ/លាយលក្ខណ៍អក្សរសម្រាប់ផ្តល់កម្ចីផ្អែកទៅតាមប័ណ្ណកកម្មសិទ្ធិដីសមូហភាពដែរឬទេ? តើមានបានទទួលការណែនាំអំពីបញ្ហានេះពីរដ្ឋាភិបាល/ការិយាល័យកណ្តាលដែរឬទេ? តើអ្នកណាត្រូវចុះហត្ថលេខាបញ្ជាក់តបវិញ?

២. កម្ចីបច្ចុប្បន្នសម្រាប់សហគមន៍ជនជាតិដើមភាគតិច ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព (ស្ថានភាពពាក់ព័ន្ធនឹងសំណើរសុំកម្ចី ចំនួនទឹកប្រាក់ឥណទានសរុបគិតជាមធ្យម ការប្រើប្រាស់កម្ចីដែលត្រូវបានស្នើឡើង វត្ថុបញ្ចាំ អត្រាការប្រាក់ ការទទួលខុសត្រូវបុគ្គលធៀបនឹងការទទួលខុសត្រូវក្រុម។ល។)

៣. បញ្ហាប្រឈម

ខ. ការពិភាក្សាអំពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុសម្រាប់សហគមន៍ជនជាតិដើមភាគតិចធៀបនឹងសហគមន៍ដែលមិនមែនជាសហគមន៍ជនជាតិដើមភាគតិច

១. ភាពខុសប្លែកគ្នាពាក់ព័ន្ធនឹងភាពអាចរកបាន និងការទទួលយកវត្ថុបញ្ចាំ

២. ភាពខុសប្លែកគ្នាពាក់ព័ន្ធនឹងសំណើសុំកម្ចី (តើភ្នាក់ងារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារចុះដល់ភូមិ ឬគ្រាន់តែចាំទទួលសំណើ?) តើមានការផ្តល់ព័ត៌មានដល់អ្នកភូមិក្នុងសហគមន៍ជនជាតិដើមភាគតិចដោយរបៀបណា? (តាមវិទ្យុ តាមការចុះជួបផ្ទាល់ តាមខិតប័ណ្ណ មធ្យោបាយដទៃទៀត ដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិច ឬ? តាមរបៀបដែលសមស្របទៅតាមវប្បធម៌ ឬ?)?

៣. ភាពខុសប្លែកគ្នាពាក់ព័ន្ធនឹងអត្រាការប្រាក់

៤. ភាពខុសប្លែកគ្នាពាក់ព័ន្ធនឹងអត្រាសងមកវិញ

៥. សំណូមពរ និងអនុសាសន៍

៦. តើមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារណាផ្សេងទៀតនៅក្នុងខេត្ត/ស្រុកតែមួយ? តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារទាំងនេះមានឯកទេសពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិចដែរឬទេ?

# ឧបសម្ព័ន្ធទី ៤ សង្ខេបទិន្នន័យអំពីប័ណ្ណកម្មសិទ្ធិដីសមូហភាព

| ល.រ | ខេត្ត | ឈ្មោះសហគមន៍ | ក្រុមជាតិពន្ធុ | ចំនួនសមាជិក | ចំនួនគ្រួសារ | ចំនួនប័ណ្ណកម្មសិទ្ធិដី | | ដីលំនៅដ្ឋាន | | វាលស្រែបច្ចុប្បន្ន | | ចម្ការបច្ចុប្បន្ន | | បម្រុងទុក/ពនាចរ | | ព្រះអារក្ស | | ព្រៃកប់សព | | កាលបរិច្ឆេទនៃការចេញប័ណ្ណកម្មសិទ្ធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចំនួនក្បាលដី | ទំហំ | ចំនួនក្បាលដី | ទំហំ | ចំនួនក្បាលដី | ទំហំ | ចំនួនក្បាលដី | ទំហំ | ចំនួនក្បាលដី | ទំហំ | ចំនួនក្បាលដី | ទំហំ | ចំនួនក្បាលដី | ទំហំ | |
| ១ | រតនគិរី | ល្អឺនក្រែន | ទំពួន | 493 | 135 | 17 | 723.50 | 2 | 10.82 | 0 | 0.00 | 3 | 487.18 | 1 | 158.20 | 1 | 6.30 | 2 | 6.90 | 2012 |
| ២ | រតនគិរី | ឡាអិន | ទំពួន | 828 | 214 | 47 | 1,218.56 | 2 | 11.80 | 4 | 33.24 | 31 | 425.11 | 5 | 735.79 | 1 | 7.00 | 2 | 3.31 | 2011 |
| ៣ | រតនគិរី | ក្រឡា | គ្រឹង | 758 | 205 | 21 | 1,765.98 | 2 | 46.94 | 0 | 0.00 | 8 | 1,449.40 | 8 | 256.95 | 2 | 5.85 | 1 | 6.86 | 25.07.2016 |
| ៤ | រតនគិរី | ល្អឺនជង | ទំពួន | 486 | 96 | 16 | 675.90 | 7 | 15.67 | 0 | 0.00 | 6 | 590.14 | 1 | 60.54 | 1 | 6.97 | 1 | 2.58 | 25.07.2016 |
| ៥ | រតនគិរី | ពីរ | គ្រឹង | 680 | 165 | 23 | 854.86 | 10 | 22.64 | 10 | 824.26 | 0 | 0.00 | 0 | 0.00 | 1 | 1.23 | 2 | 6.73 | 12.10.2016 |
| ៦ | រតនគិរី | តាង៉ាច | គ្រឹង | មិនដឹង | មិនដឹង | 9 | 62.16 | 4 | 21.06 | | | 3 | 498.21 | 1 | 102.31 | 1 | 2.58 | | | 2017 |
| ៧ | រតនគិរី | កងកុយ | គ្រឹង | មិនដឹង | មិនដឹង | 6 | 463..52 | 1 | 3.42 | | | 1 | 453.71 | 2 | 4.06 | 1 | 1.44 | 1 | 0.89 | 2017 |
| ៨ | រតនគិរី | ក្រេះ | គ្រឹង | មិនដឹង | មិនដឹង | 15 | 748.28 | 5 | 93.80 | | | 7 | 650.72 | 1 | 1.23 | 1 | 1.17 | 1 | 0.99 | 2017 |
| ៩ | រតនគិរី | កាន់ឈឹង | គ្រឹង | មិនដឹង | មិនដឹង | 9 | 1,512.14 | 3 | 42.29 | | | 2 | 1,367.80 | 2 | 93.65 | 1 | 6.13 | 1 | 2.26 | 2017 |
| | **សរុប** | **៩ សហគមន៍** | | **3,245** | **815** | **163** | **8,586.90** | **36** | **268.44** | **14** | **857.50** | **61** | **5,922.27** | **21** | **1,412.73** | **10** | **38.66** | **11** | **30.52** | |
| | | | | | | | | | | | | | | | | | | | | |
| ១០ | មណ្ឌលគិរី | អូររណា | ពួង | 373 | 80 | 59 | 648.07 | 15 | 33.44 | 4 | 7.54 | 35 | 365.90 | 3 | 236.83 | 1 | 3.18 | 1 | 1.16 | May 2013 |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១ | មណ្ឌលគិរី | អូរច្រា | ព្នង | 123 | 27 | 27 | 526.09 | 10 | 146.00 | 10 | 55.00 | 4 | 92.48 | 1 | 219.14 | 1 | 6.98 | 1 | 6.49 | 2011 |
| ១២ | មណ្ឌលគិរី | ហ្គាទិ | ព្នង | 215 | 45 | 22 | 482.69 | 8 | 88.19 | 3 | 66.34 | 7 | 263.27 | 1 | 60.65 | 1 | 3.28 | 2 | 0.96 | |
| ១៣ | មណ្ឌលគិរី | ស្រែខ្ទុម | ព្នង | 404 | 93 | 61 | 1,048.48 | 27 | 47.00 | 5 | 183.25 | 20 | 282.13 | 4 | 563.02 | 1 | 2.41 | 4 | 6.67 | 2013 |
| ១៤ | មណ្ឌលគិរី | ស្រែល្វី | ព្នង | 127 | 31 | 13 | 383.84 | 5 | 19.70 | 1 | 33.58 | 4 | 305.23 | 1 | 11.73 | 1 | 6.87 | 1 | 6.73 | 2013 |
| ១៥ | មណ្ឌលគិរី | អណ្តូងក្រឡឹង | ព្នង | 453 | 102 | 37 | 1,424.26 | 10 | 166.94 | 2 | 31.74 | 10 | 636.50 | 9 | 573.33 | 3 | 5.73 | 3 | 10.02 | 2012 |
| ១៦ | មណ្ឌលគិរី | ពូក្រុំ | ព្នង | 875 | 116 | 60 | 1,606.24 | 24 | 79.06 | 0 | 0.00 | 29 | 926.00 | 4 | 593.94 | 1 | 0.76 | 2 | 6.48 | 30.11.2015 |
| | **សរុប** | **៧ សហគមន៍** | | **2,570** | **494** | **279** | **6,119.7** | **99** | **580.33** | **25** | **377.45** | **109** | **2,871.51** | **23** | **2,258.64** | **9** | **29.21** | **14** | **38.51** | |
| | | | | | | | | | | | | | | | | | | | | |
| ១៧ | ក្រចេះ | ពន្ទដា | ព្នង | 546 | 132 | 35 | 597.28 | 14 | 95.73 | 14 | 277.99 | 0 | 0.00 | 6 | 216.77 | 0 | 0.00 | 1 | 6.79 | 02.01.2016 |
| ១៨ | ក្រចេះ | អូរកក់ | ព្នង | 129 | 37 | 21 | 402.04 | 5 | 35.72 | 9 | 59.26 | 0 | 0.00 | 6 | 300.26 | 1 | 6.80 | 0 | 0.00 | 02.01.2016 |
| | **សរុប** | **២ សហគមន៍** | | **675** | **169** | **56** | **999.32** | **19** | **131.45** | **23** | **337.25** | **0** | **0** | **12** | **517.03** | **1** | **6.80** | **1** | **6.79** | |
| | **សរុបរួម** | **១៨ សហគមន៍** | | **6,490** | **1,478** | **498** | **15,706** | **154** | **980.22** | **62** | **1,572.20** | **170** | **8,793.78** | **56** | **4,188.40** | **20** | **74.67** | **26** | **75.82** | |

# ឧបសម្ព័ន្ធទី ៥ ទំហំសំណាកគំរូ

| ល.រ | ទីតាំង | | ឈ្មោះសហគមន៍ | ចំនួនអ្នកចូលរួមក្នុងការពិភាក្សាក្រុម | | ចំនួនគ្រួសារដែលត្រូវបានសម្ភាស |
|---|---|---|---|---|---|---|
| | ខេត្ត | ស្រុក | | ស្រី | ប្រុស | |
| ១ | រតនគិរី | អូរជុំ | ល្មីនក្រែន | ១ | ៦ | ៩ |
| ២ | រតនគិរី | កូនមុំ | ឡាអិន | ២ | ៥ | ៥ |
| ៣ | រតនគិរី | អូរជុំ | ល្មីនជង | ៥ | ១ | ៦ |
| ៤ | មណ្ឌលគិរី | កែវសីមា | អូររណា | ៣ | ៣ | ៩ |
| ៥ | មណ្ឌលគិរី | កែវសីមា | អូរប្រា | - | ២ | ៥ |
| ៦ | មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | ៧ | ៨ | ១៣ |
| ៧ | មណ្ឌលគិរី | កែវសីមា | ស្រែល្វី | ៦ | ៥ | ១១ |
| ៨ | មណ្ឌលគិរី | អូររាំង | អណ្តូងក្រឡឹង | - | ៣ | ៤ |
| ៩ | មណ្ឌលគិរី | សែនមនោរម្យ | ពូត្រុំ | ៣ | ៣ | ១៥ |
| ១០ | ក្រចេះ | សំបូរ | ពន្ធជា | - | ៤ | ៥ |

# ឧបសម្ព័ន្ធទី ៦ ឯកសារយោង


- ADB (2014). Cambodia Country Poverty Analysis
- Baird, I. (2013). ‘Indigenous peoples’ and land: Comparing communal land titling and its implications in Cambodia and Laos
- Cambodian Center for Human Rights (2016). Access to Collective Land Titles for Indigenous Communities in Cambodia
- Cambodia Institute of Development Study (2013). Study on the Drivers of Over-Indebtedness of Microfinance Borrowers in Cambodia: An In-depth Investigation of Saturated Areas
- GIZ (2015 & 2016). Baseline Survey for the Projects ILF I and II (Internal Document)
- GIZ (2016). Lessons Learned on Indigenous Communal Land Titling
- Government of Cambodia (2001). The Land Law
- Ministry of Planning / National Institute of Statistics (2016). Cambodia Socio-Economic Survey 2015
- National Bank of Cambodia (2017). Annual Report 2016
- Sopheap Souk (2014). The Effectiveness of group lending at AMRET Microfinance Institution leading to poverty reduction: A case study of Kandal Stueng District Branch, Kandal Province, Cambodia
- Yin Sopheap (2016). Legal, Policy, and Administrative Evaluation of Indigenous peoples in Cambodia